ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០២៤

លេខៈ ១៩

ឆ្នាំ២០២៥

# អារម្ភកថា

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២៤ សម្រេចបានកំណើន៦% ទាបជាងការព្យាករណ៍ក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចបន្តិចក្នុងអត្រា៦,៦% តែជាអត្រាកំណើនមួយខ្ពស់បើធៀបនឹង៥,០%ក្នុងឆ្នាំ២០២៣កន្លងទៅ ដែលបណ្តាលមកពីការទទួលនូវកម្មវិបាកពីកត្តាសំខាន់ៗចំនួន៣ រួមមាន៖ ទី១-ភាពមិនប្រាកដប្រជានៃបរិការណ៍សកលនិងតំបន់ និងការបន្តអនុវត្តគោលនយោបាយរឹតបន្តឹងរូបិយវត្ថុៈ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមិនខុសពីស្ថានភាពសេដ្ឋកិច្ចសកល និងតំបន់ឡើយ គឺនៅតែត្រូវបានបន្តហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ស្របពេលដែលគោលនយោបាយរឹតបន្តឹងរូបិយវត្ថុក៏នៅតែត្រូវបានបន្តអនុវត្ត ទី២-ការផ្លាស់ប្តូរនូវរបត់គោលនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាម៉េរិកៈ ការផ្លាស់ប្តូរនូវរបត់គោលនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាម៉េរិក បានជំរុញឱ្យមានការស៊ើបអង្កេតដើម្បីដាក់វិធានការពន្ធបន្ថែម (Countervailing Duty Investigation-CVD) លើផលិតកម្មបន្ទះសូឡានៅកម្ពុជាគឺធ្វើឱ្យប៉ះពាល់ទៅលើការបញ្ជាទិញ ត្បិតសហរដ្ឋអាម៉េរិកគឺជាទីផ្សារធំនៃការនាំចេញបន្ទះសូឡារបស់កម្ពុជា ហើយក្រុមហ៊ុនផលិតបន្ទះសូឡាមួយចំនួនធំនៅកម្ពុជាក៏បានផ្អាកដំណើរការផលិតកម្មដោយសារភាពមិនប្រាកដប្រជាខ្ពស់ពីលទ្ធផលនៃការស៊ើបអង្កេត និងការធ្លាក់ចុះយ៉ាងគំហុកនៃការបញ្ជាទិញពីទីផ្សារអាម៉េរិក និង ទី៣-កត្តាបច្ចេកទេសៈ ការផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ២០០០ ទៅឆ្នាំ២០១៤ គឺជាដំណើរការនៃការជំនួសឡើងវិញឆ្នាំគោលចាស់ (ឆ្នាំ២០០០) ដែលបានប្រើប្រាស់សម្រាប់ចងក្រងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ជាង២០ឆ្នាំមកហើយ ជាមួយនឹងឆ្នាំគោលថ្មី(ឆ្នាំ២០១៤) ដើម្បីធ្វើការគណនាថ្លៃថេរ ផ.ស.ស. សម្រាប់វាស់វែងទំហំ និងកំណើនសេដ្ឋកិច្ច។

សេដ្ឋកិច្ចកម្ពុជា គឺត្រូវបានទ្រទ្រង់យ៉ាងសំខាន់៖ វិស័យកសិកម្ម បន្តរក្សាបាននូវស្ថិរភាពកំណើនក្នុងរង្វង់១,០% ដែលជំរុញដោយសកម្មភាពប្រសើរឡើងនៃអនុវិស័យដំណាំ និងអនុវិស័យនេសាទ ខណៈដែលអនុវិស័យចិញ្ចឹមសត្វមានការថមថយ។ វិស័យឧស្សាហកម្មនៅបន្តមានកំណើនល្អក្នុងអត្រា ៩,៩% ក្នុងឆ្នាំ២០២៤ បើទោះបីអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរមានកំណើនថមថយយ៉ាងណាក្តី តែការងើបឡើងវិញលឿនជាងការរំពឹងទុកនៃអនុវិស័យកាត់ដេរដែលមានកំណើនខ្ពស់បានជួយជំរុញកំណើនក្នុងវិស័យនេះ។ អនុវិស័យកាត់ដេរបន្តរក្សាបាននិន្នាការល្អប្រសើរនៃតម្រូវការសកលបើទោះបីស្ថានភាពជារួមនៅបន្តត្រូវបានហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់យ៉ាងណាក្តី។ អនុវិស័យសំណង់បន្តមានកំណើនទាបដោយសារការងើបឡើងវិញយឺតជាងការរំពឹងទុកនៃសំណង់ថ្លៃខ្ពស់ រួមមានអគារពាណិជ្ជកម្ម ជាដើម ដែលពឹងផ្អែកខ្លាំងលើវិនិយោគទុនពីបរទេស ប៉ុន្តែអនុវិស័យនេះនៅបន្តត្រូវបានទ្រទ្រង់ដោយសកម្មភាពសាងសង់លំនៅឋានថ្លៃសមរម្យ និងអគារសហកម្មសិទ្ធិ និងជាពិសេសសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម រួមមាន រោងចក្រ និងឃ្លាំង ជាដើម។ ដោយឡែក អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរមានកំណើនយឺតទាបជាងការរំពឹងទុកដោយសារការថមថយនៃផលិតកម្មបម្រើការនាំចេញ ជាពិសេសបន្ទះសូឡា ដោយសារឥទ្ធិពលជាអវិជ្ជមាននៃការស៊ើបអង្កេតរបស់សហរដ្ឋអាម៉េរិកមកលើក្រុមហ៊ុនផលិតបន្ទះសូឡានៅកម្ពុជា ប៉ុន្តែជារួមនៅបន្តត្រូវបានទ្រទ្រង់ដោយផលិតកម្មបម្រើការនាំចេញ

ផ្សេងៗទៀត ដូចយ៉ាងគ្រឿងបង្គុំអេឡិចត្រូនិក គ្រឿងសង្ហារិម និងសំបកកង់រថយន្ត ជាដើម។ បន្ថែមពីនេះ ផលិតកម្មបម្រើឱ្យទីផ្សារក្នុងស្រុកក៏នៅបន្តរក្សាបានចលនការល្អ ដូចយ៉ាង ឧស្សាហកម្មដំឡើងរថយន្ត ឧស្សាហកម្មចំណីអាហារនិងភេសជ្ជៈ ជាដើម។ វិស័យសេវាកម្មនៅបន្តនិន្នាការកើនឡើងក្នុងអត្រា៤,៣% ដែលបន្តគាំទ្រដោយអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) និងវិស័យគាំទ្រទេសចរណ៍ផ្សេងទៀត ដូចយ៉ាងអនុវិស័យដឹកជញ្ជូន និងស្តុក ជាដើម។ វិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារបន្តមានកំណើនល្អក្នុងអត្រា១៣,២% ដែលបន្តត្រូវបានគាំទ្រដោយនិន្នាការកើនឡើងនៃវំហូរភ្ញៀវទេសចរអន្តរជាតិ និងទេសចរជាតិ ដែលជាលទ្ធផលនៃការស្តារឡើងវិញនូវទំនុកចិត្តក្នុងការធ្វើដំណើររបស់ទេសចរនៅកម្ពុជា តាមរយៈការបន្តជំរុញការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ផលិតផលទេសចរណ៍ សេវាកម្ម បរិស្ថាន និងទីផ្សារគោលដៅទេសចរណ៍សំខាន់ៗក្នុងនិងជុំវិញតំបន់ទេសចរណ៍ ការផ្សព្វផ្សាយកាន់តែទូលំទូលាយពីគោលដៅទេសចរណ៍កម្ពុជាទៅកាន់ឆាកអន្តរជាតិ ការបង្កើនការតភ្ជាប់ជើងហោះហើរត្រង់ពីប្រទេសដែលជាគោលដៅទេសចរណ៍ និងកិច្ចសហប្រតិបត្តិការលក្ខណៈអន្តរក្រសួង និងជាមួយស្ថាប័នឯកជនក្នុងការរៀបចំយុទ្ធសាស្ត្រនានាពាក់ព័ន្ធវិស័យទេសចរណ៍ និងក្នុងការដោះស្រាយបញ្ហាចំពោះមុខ។ អនុវិស័យលក់ដុំ-រាយបន្តកើនឡើងក្នុងអត្រា៣,៩% គាំទ្រដោយការបន្តងើបឡើងវិញជាសន្សឹមៗនៃសកម្មភាពចាយវាយក្នុងស្រុក។

ផ.ស.ស សម្រាប់មនុស្សម្នាក់បានកើនឡើងពី២ ៤៧៧ ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣ មកដល់ប្រមាណ២ ៦៧៥ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៤។ អត្រាអតិផរណាបានថមថយមកត្រឹមប្រមាណ០,៨% ក្នុងឆ្នាំ២០២៤ពីអត្រាប្រមាណ២,១%ក្នុងឆ្នាំ២០២៣ ដោយសារការបន្តធ្លាក់ចុះនៃថ្លៃប្រេងអន្តរជាតិស្របពេលដែលថ្លៃទំនិញផ្សេងៗទៀត បន្តរក្សាបានស្ថិរភាព។ ជាមួយគ្នានេះ អត្រាប្តូរប្រាក់ផ្លូវការបន្តមានស្ថិរភាពជាមធ្យម៤ ០៧០រៀល/ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤ ដោយសារការបន្តធ្លាក់ចុះជាសន្សឹមៗថ្លៃរូបិយប័ណ្ណដុល្លារអាម៉េរិក គួបផ្សំនឹងគោលនយោបាយអន្តរាគមន៍ទីផ្សាររបស់ធនាគារជាតិនៃកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវគោលនយោបាយសំខាន់ៗ រួមមានៈ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាបន្ន ៣-បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញដោយបង្កើនការវិនិយោគដើម្បីបង្កើនតម្លៃបន្ថែមលើមូលដ្ឋានកំណើនសេដ្ឋកិច្ចដែលមានស្រាប់ ព្រមទាំងជំរុញឱ្យមានការវិនិយោគទៅលើប្រភពថ្មីនៃកំណើនដែលមានសក្តានុពលសេដ្ឋកិច្ច និងមានផលិតភាពខ្ពស់ ដើម្បីបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជន និងដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញផង និងជំរុញបង្កើនចំណូលថវិកាជាតិផង ៤-ពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈដោយផ្តោតសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័នតាមរយៈការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ទន្ទឹមគ្នានឹងការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់

សេវាសាធារណៈដោយឈរលើគោលការណ៍សមធម៌ គុណាធិបតេយ្យ និងចីរភាពថវិកា ៥-ជំរុញការបន្តអភិវឌ្ឍធនធានមនុស្ស និងមូលធនមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត រួមទាំងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកម្រិតទី១ជូនយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ ៦-ជំរុញការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាលតាមរយៈការលើកកម្ពស់គុណភាពសេវាសុខាភិបាល គួបផ្សំជាមួយនឹងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជាដែលអាចឆ្លើយតបនឹងគ្រោះអាសន្នដែលអាចកើតមានជាយថាហេតុ ៧-ជំរុញការបន្តកសាងប្រព័ន្ធគាំពារសង្គមតាមរយៈការបន្តពង្រឹងប្រព័ន្ធគាំពារសង្គមចំគោលដៅ និងការធ្វើស្ថាប័នូបនីយកម្មកម្មវិធីជាតិជំនួយសង្គមឱ្យកាន់តែមានប្រសិទ្ធភាព ព្រមជាមួយនឹងការបន្តពង្រឹងវិសាលភាពគ្របដណ្តប់ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនចាស់ជរា គ្រួសារក្រីក្រ និងងាយរងគ្រោះ ព្រមទាំងនិយោជិតដែលស្ថិតនៅក្រៅប្រព័ន្ធ ៨-ពង្រឹងភាពប្រកួតប្រជែង និងការជំរុញពិធកម្មសេដ្ឋកិច្ចកម្ពុជាក្នុងវិស័យសក្តានុពលនានា រួមមានវិស័យកសិកម្ម ដឹកជញ្ជូន និងឡូជីស្ទីក ព្រមទាំងបន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូចនិងមធ្យមដែលជាចន្ទល់កំណើនសេដ្ឋកិច្ចកម្ពុជាតាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីការវិនិយោគថ្មីក្នុងការទាក់ទាញវិនិយោគ និងការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ ព្រមទាំងការកែលម្អបរិយាកាសធុរកិច្ចសំដៅគាំទ្រការស្តារសេដ្ឋកិច្ច និងធានាស្ថិរភាពកំណើន ៩-បង្កើនគុណភាព និងប្រសិទ្ធភាពនៃការវិនិយោគសាធារណៈជាទូទៅ បន្តការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងលើកកម្ពស់ជីវភាពប្រជាជន ក៏ដូចជាការផ្តល់សេវាសាធារណៈផ្សេងៗ ព្រមជាមួយនឹងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតងស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច និងគាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព ១០-បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅទាំងឡាយរបស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ព្រមជាមួយនឹងការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ក៏ដូចជា ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីអភិបាលកិច្ចល្អ គុណភាពនៃសេវាសាធារណៈ និងយុត្តិធម៌សង្គម ឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ១១-ពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ និង១២-គាំទ្រដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤។

ជាក់ស្តែងនៅក្នុងឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធបានខិតខំប្រឹងប្រែងអនុវត្តវិធានការប្រមូលចំណូលដែលនាំឱ្យចំណូលថវិកាថ្នាក់ជាតិឆ្នាំ២០២៤ អនុវត្តបាន

ចំនួន២៧ ៣៨៩ ៧៩៨,៨លានរៀល ត្រូវជា១៤,៥១%នៃ ផ.ស.ស. ហើយស្មើនឹង៩១,៦%នៃច្បាប់ហិរញ្ញវត្ថុ គឺមានការកើនឡើង៤,៨% ធៀបនឹងការអនុវត្តឆ្នាំ២០២៣។

ចំណូលថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០២៤ រួមមាន៖ ចំណូលថវិការបស់រាជធានី ខេត្ត អនុវត្តបានចំនួន ៣ ៣០២ ៩០១,៣ លានរៀល ត្រូវជា១,៧៥%នៃផ.ស.ស. ហើយស្មើនឹង៩២,៥%នៃច្បាប់ហិរញ្ញវត្ថុ គឺមានការថយចុះ២១,០% ធៀបនឹងការអនុវត្តឆ្នាំ២០២៣ ហើយចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន ២ ២០៤ ៦០៧,៤ លានរៀលត្រូវជា១,១៧%នៃ ផ.ស.ស. ហើយស្មើនឹង៩៧,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានការកើនឡើង៣,៧%ធៀបនឹងការអនុវត្តឆ្នាំ២០២៣។

រីឯចំណាយថវិការដ្ឋ (ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ)ឆ្នាំ២០២៤ អនុវត្តបានចំនួន ៣២ ៨៣៥ ៧៣៥,១ លានរៀល ត្រូវជា១៧,៣៩%នៃផ.ស.ស. ហើយស្មើនឹង៩០,៤នៃច្បាប់ហិរញ្ញវត្ថុ។ អនុលោមតាមមាត្រា៧០នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវសារាចរស្តីពីការធ្វើវិចារណកម្មចំណាយ និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ តាមរយៈការបង្អាកចំណាយ ដើម្បីសម្រួលតាមបរិការណ៍ដែលចំណូលសារពើពន្ធមិនអាចសម្រេចបានតាមផែនការកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

ការអនុវត្តចំណាយថវិកាចរន្តជាតិឆ្នាំ២០២៤ សម្រេចបាន៩១,១% នៃច្បាប់ហិរញ្ញវត្ថុ គឺឆ្លុះបញ្ចាំងពីផ្លែផ្កានៃការចូលរួមអនុវត្តសកម្មភាពដែលបានដាក់ចេញនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាដោយផ្តោតលើកត្តាសំខាន់មួយចំនួន ដូចជា៖ (១)-ការគោរពវិន័យថវិកាក្នុងការអនុវត្តថវិកា (២)-ការកាត់សន្សំតាមថ្លៃទីផ្សារជាក់ស្តែង និងការធានាបាននូវគុណភាពនៃទំនិញ និង(៣)-ការពង្រឹងសមត្ថភាពការរៀបចំផែនការថវិការបស់ក្រសួងស្ថាប័ន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្តជំរុញក្រសួង ស្ថាប័នក្នុងការកែលម្អចំណុចខ្វះចន្លោះក្នុងដំណើរការគ្រប់គ្រង និងប្រតិបត្តិការចំណាយរបស់ខ្លួនពាក់ព័ន្ធនឹងភាពត្រឹមត្រូវ អនុលោមភាព និងប្រសិទ្ធភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងអធិការកិច្ចហិរញ្ញវត្ថុ។ ការអនុវត្តចំណាយចរន្ត និងចំណាយវិនិយោគដោយថវិការដ្ឋក៏នៅជួបប្រទះនឹងបញ្ហាប្រឈមដែលត្រូវបន្តកែលម្អ និងពង្រឹង រួមមាន៖ (១)-ការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័នមួយចំនួនក្រោមគណនីទានចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេសនៅមានភាពយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ និងករណីដែលទទួលបានការធានាចំណាយរួចហើយក៏នៅមានភាពយឺតយ៉ាវក្នុងការរៀបចំឯកសារ លិខិតយុត្តិការ ដើម្បីទូទាត់ផងដែរ (២)-ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងរបស់ក្រសួង ស្ថាប័នមួយចំនួននៅមានកម្រិត និង(៣)-ការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នមួយចំនួនមានផលប៉ះពាល់ដល់ការអនុវត្តថវិកា។

ថវិកាឆ្នាំ២០២៤ ត្រូវបានគិតគូរ និងរៀបចំឡើងដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ និងប្រាក់ចំណូលរបស់ប្រជាជន ក៏ដូចជាការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការគាំទ្រដល់ការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវគោលដៅ

សំខាន់នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ ថវិកាឆ្នាំ២០២៤ ក៏ត្រូវបានរៀបចំតម្រង់ទៅបំពេញតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ក្រសួង ស្ថាប័ន ជាពិសេសកិច្ចការកែទម្រង់លើគ្រប់វិស័យសំដៅកសាងមូលដ្ឋានគ្រឹះបន្ថែមក្នុងដំណើរការឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជាដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿង ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងជារដ្ឋអធិបតេយ្យមួយដ៏រឹងមាំដែលគោរពបានយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។

លទ្ធផលទាំងនេះបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងឆន្ទៈនយោបាយមោះមុតអង់អាច ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកបដោយគតិបណ្ឌិតឈ្លាសវៃនិងស្វាហាប់ បានបន្តពូនជ្រំុសមិទ្ធផលដែលសម្រេចបានកន្លងមកកាន់តែមានភាពរឹងមាំល្អប្រសើរថែមទៀត។

ចំពោះចំណាយថវិការាជធានី ខេត្ត អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៩,២% ចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៣,៧% និងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ក៏អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ១៤,៩% ដែរ។

ការគ្រប់គ្រងថវិកាឆ្នាំ២០២៤ គោរពបានទាំងកាលវសាន្ត ទាំងខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលបានគិតគូរ និងរៀបចំឡើង ដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ ប្រាក់ចំណូលរបស់ប្រជាជន ក៏ដូចជាការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការគាំទ្រដល់ការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវគោលដៅសំខាន់នៃ**កម្មវិធីនយោបាយ**របស់រាជរដ្ឋាភិបាលដែលត្រូវបានកំណត់នៅក្នុង**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១**។

លើសពីនេះ ថវិកាឆ្នាំ២០២៤ក៏បានបន្តរក្សាការពារសមិទ្ធផលសង្គមជាតិទាំងឡាយដែលសម្រេចបានកន្លងមក ប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែង ដើម្បីជម្នះ និងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតមានឡើងនាពេលអនាគត ក្នុងស្មារតីធានាឱ្យកម្ពុជាអាចឈរដ៏រឹងមាំ និងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួនក្នុងគ្រប់កាលៈទេសៈ។

រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានដាក់ចេញ ព្រមជាមួយនឹងការបន្តប្រកាន់ខ្ជាប់នូវអភិក្រម ការងារ៥យ៉ាងគឺ **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់** ដើម្បីធានាឱ្យបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ឯករាជ្យ និងអធិបតេយ្យជាតិ ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ក៏ដូចជាដើម្បីទ្រទ្រង់នូវដំណើរស្តារ និងជំរុញកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាឡើងវិញលើគ្រប់វិស័យនៅលើមាគ៌ាឈានឆ្ពោះទៅការកសាងសង្គមកម្ពុជាមួយដ៏រុងរឿងល្បាញល្បី ប្រជាប្រុសស្រីរស់មានសេរីភាព និងសុភមង្គល។

សរុបមក ថវិកាឆ្នាំ២០២៤ អាចត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុង និងក្រៅប្រទេស ដែលត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការអនុវត្ត **គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា**" ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើមនុស្ស សមត្ថភាពស្ថាប័ន ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ច ជាស្នូល ហើយអាចប្រសិទ្ធនាមបានថាជា"**ថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធផលដែលសម្រេចបានដោយលំបាក និងការបន្តបុកគ្រឹះថ្មីៗ ក្នុងការបោះជំហានឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព និងទ្រទ្រង់ដំណើរវិវឌ្ឍតទៅមុខឥតឈប់ឈររបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព ឆ្ពោះទៅចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**"។

តាមការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ព្រមទាំងបទប្បញ្ញត្តិគតិយុត្តនានា។

អាជ្ញាធរសវនកម្មជាតិសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តវិធានការប្រមូលចំណូល និងគ្រប់គ្រងការចំណាយប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពឈ្លាសវៃ។ សមិទ្ធផលទាំងនេះ សរបញ្ជាក់ពីភាពត្រឹមត្រូវ ពីប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងផ្លែផ្កានៃកំណែទម្រង់មុតស្រួច និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះ ជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០២៤ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និង

សម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ ទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ដៃគូរអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា តាមការធ្វើសវនកម្មនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រលាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០២៥

**អគ្គសវនករ**

**បណ្ឌិត សោម គីមសួគ៌**

# មាតិកា

ទំព័រ


**សេចក្តីសង្ខេប** ........ ១

**១. សេចក្តីផ្តើម** ........ ៥

**១.១. លក្ខណៈទូទៅ** ........ ៥

**១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម** ........ ៥

**១.៣. គោលបំណងនៃការផ្សព្វផ្សាយ** ........ ៥

**២. ការគ្រប់គ្រងថវិកា** ........ ៦

**២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា** ........ ៦

**២.២. កិច្ចប្រតិបត្តិការថវិកា** ........ ៧

**៣. លទ្ធផលសវនកម្ម** ........ ១១

**៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ........ ១១

៣.១.១. ការប្រកាសតម្លៃគិតពន្ធលើម៉ូតូនាំចូលមួយចំនួនមានលក្ខណៈពុំទាន់សមស្រប ........ ១១

៣.១.២. ការពុំបានគ្រោងចំណូលពីការជួលអគារ ឬសំណង់ផ្សេងៗនៅក្នុងផែនការចំណូល ........ ១២

៣.១.៣. វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់សមស្រប ........ ១៣

៣.១.៤. វិធានការលើក្រុមហ៊ុនដែលជំពាក់ថ្លៃឈ្នួលអចលនទ្រព្យ ........ ១៤

៣.១.៥. ភាពយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពកិច្ចសន្យាជួលទីតាំង ........ ១៥

៣.១.៦. ការពុំទាន់បញ្ចប់នីតិវិធីនៃការដោះដូរដី ជាថ្នូរនឹងការសាងសង់អគាររដ្ឋបាលថ្មីរបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ........ ១៧

៣.១.៧. ការកត់ត្រាបញ្ជីគណនេយ្យ (គណនីបេឡា) ពុំស្របតាមប្រព្រឹត្តិកម្មគណនី ........ ១៨

៣.១.៨. កង្វះខាតក្នុងការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃការបង់ចំណូលបែងចែក ........ ១៩

៣.១.៩. ភាពយឺតយ៉ាវក្នុងការប្រមូលចំណូលសេវាសាធារណៈ ........ ១៩

៣.១.១០. កង្វះខាតក្នុងការផ្គូផ្គងចំណូលចំណាយសម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូក្នុងក្រសួង ........ ២១

៣.១.១១. ភាពយឺតយ៉ាវក្នុងការបង់ចំណូលចូលថវិកាជាតិ ........ ២២

៣.១.១២. ការពុំបានផ្ទេរចំណូលពីការប្រាក់ចូលថវិកាជាតិ ........ ២៣

៣.១.១៣. ការបង្វែរចំណូលចូលថវិកាជាតិ និងការរៀបចំសលាកបត្រចំណូលថវិកាជាតិសម្រាប់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត ........ ២៤

៣.១.១៤. កង្វះខាតក្នុងការអនុវត្តនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូល ........ ២៥

៣.១.១៥. ការប្រមូលកម្រៃសេវាសាធារណៈរបស់រដ្ឋមិនស្ថិតនៅក្រោមអនុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាល ........ ២៦

៣.១.១៦. កង្វះខាតក្នុងការពង្រឹងយន្តការ និងវិធានការតឹងរឹងចំពោះយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ........ ២៦

៣.១.១៧. ការបំបែកបណ្ណចំណាយដោយពុំធ្វើនីតិវិធីលទ្ធកម្ម ........ ២៧

៣.១.១៨. ការមិនមានរបាយការណ៍ ឬកំណត់ហេតុក្នុងការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក ........ ២៨

៣.១.១៩. ការអនុវត្តវិធីសាស្ត្រលទ្ធកម្មមិនស្របទៅនឹងវិធីសាស្ត្រក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ........ ២៩

៣.១.២០. ការចំណាយប្រាក់បេសកកម្មក្រៅប្រទេស(ក្រៅអាស៊ាន)មុនគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........................................................................................៣០
៣.១.២១. ការពុំបានទូទាត់ប្រាក់បេសកកម្មចូលគណនីបៀវត្សតាមប្រព័ន្ធធនាគារ.................................៣១
៣.១.២២. ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃតាមសារព័ត៌មានពុំបានពេញលេញ.......... ៣២
៣.១.២៣. ភាពយឺតយ៉ាវក្នុងការស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង........................................................................................................៣២
៣.១.២៤. ការមិនទាន់ស្កេន ឬទាញបញ្ចូលឯកសារភ្ជាប់ចូលក្នុងប្រព័ន្ធFMISសម្រាប់មុខងារលទ្ធកម្មពេញលេញ........................................................................................................៣៣
៣.១.២៥. ភាពយឺតយ៉ាវក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនទទួលការដើម្បីគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព........................................................៣៤
៣.១.២៦. ការយកប្រតិបត្តិការចំណាយឆ្នាំ២០២៣មកទូទាត់តណទានថវិកាឆ្នាំ២០២៤........................៣៥
៣.១.២៧. ភាពយឺតយ៉ាវក្នុងការបង់ប្រាក់ ឬបង្វែរសាច់ប្រាក់បុរេប្រទានដែលនៅសល់.......................... ៣៧
៣.១.២៨. ការប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដែលមិនមានប៉ាតង់ស្របតាមកម្មវត្ថុនៃដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ........................................................................................................ ៣៨
៣.១.២៩. ភាពយឺតយ៉ាវក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង.................................................... ៣៩
៣.១.៣០. កង្វះខាតក្នុងការទុកពេលវេលាសម្រាប់បណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម...............................៤០
៣.១.៣១. ការប្រគល់ទទួលទំនិញពុំបានត្រឹមត្រូវស្របតាមនីតិវិធីនៃកិច្ចលទ្ធកម្ម..........................៤១
៣.១.៣២. កង្វះខាតក្នុងការប្រមូលសក្ខីបត្រគាំទ្រការចំណាយប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត... ៤២
៣.១.៣៣. អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារគ្រប់គ្រាន់...................................៤២
៣.១.៣៤. ការធ្វើបច្ចុប្បន្នភាពទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារពុំទាន់បានសមស្របតាមលិខិតបទដ្ឋានគតិយុត្ត........................................................................ ៤៣
៣.១.៣៥. កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ.................................................៤៤
៣.១.៣៦. ការមិនទាន់បែងចែក និងវិភាជន៍តណទានថវិកាឱ្យបានពេញលេញទៅឱ្យអង្គភាពថវិកា....៤៥
៣.១.៣៧. ការយកសក្ខីបត្រចំណាយថវិការជ្ជទេយ្យបុរេប្រទានមកទូទាត់ពុំទាន់បានត្រឹមត្រូវ..................៤៥
៣.១.៣៨. កង្វះខាតក្នុងការរៀបចំរបាយការណ៍ចំណាយថវិការបស់អង្គភាពថវិកា.................................. ៤៦
៣.១.៣៩. ការធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព និងគុណភាពការងារសំណង់ និងលិខិតបញ្ចប់ការងាររបស់វិស្វករ ឬអ្នកបច្ចេកទេស................................................................................................៤៧
**៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**................................................................... ៤៨
៣.២.១. ការប្រមូលពន្ធមធ្យោបាយដឹកជញ្ជូន.........................................................................៤៨
៣.២.២. ការដាក់ផែនការសម្រាប់ការប្រមូលចំណូលពន្ធអចលនទ្រព្យ...........................................៤៩
៣.២.៣. ភាពយឺតយ៉ាវក្នុងការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានា................ ៥០
៣.២.៤. ការរក្សាទុកសំណុំឯកសារដែលអង្គភាពរដ្ឋ ទទួលការមិនបានពេញលេញ.............................. ៥១
៣.២.៥. កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង........................... ៥២
៣.២.៦. ការទុករយៈពេលសម្រាប់ប្តឹងតវ៉ាលទ្ធកម្ម........................................................................ ៥៣
៣.២.៧. ភាពមិនទាន់ពេញលេញនៃការបង្កើតរបាយការណ៍ចេញពីប្រព័ន្ធ FMIS.................................៥៣

៣.២.៨. បំណុលភាស៊ីត្រូវទារ ..... ៥៤
៣.២.៩. ភាពយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំគោល (ឆ្នាំ២០២៤) ..... ៥៥
៣.២.១០. ការពុំបានកត់ត្រាទ្រព្យសម្បត្តិចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ..... ៥៦
៣.២.១១. ភាពយឺតយ៉ាវក្នុងការរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ..... ៥៧
**៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម ..... ៥៩**
៤.១. ការចេញលិខិតរំលឹកប្រកាសពន្ធ ..... ៥៩
៤.២. វឌ្ឍនភាពនៃការជំរុញការចុះបញ្ជីសហគ្រាសតាមលទ្ធផលអង្កេត ..... ៥៩
៤.៣. ការផ្ទេរក្រុមហ៊ុន សហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ..... ៥៩
៤.៤. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ..... ៦០
៤.៥. ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន ..... ៦០
៤.៦. ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ក្រុមហ៊ុន សហគ្រាសមួយចំនួន ..... ៦១
៤.៧. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ..... ៦១
៤.៨. ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២៤ ..... ៦២
៤.៩. ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើមដែលទទួលបានការអនុគ្រោះព្បន្ធ ឬលើកលែងពន្ធអាំករនៅមានកម្រិត ..... ៦៣
៤.១០. ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ..... ៦៤
៤.១១. ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ..... ៦៥
៤.១២. ការប្រមូលពន្ធលើថ្លៃឈ្នួលចលន និងអចលនទ្រព្យ ..... ៦៥
៤.១៣. ការកត់ត្រាប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ..... ៦៥
៤.១៤. ការប្រមូលពន្ធលើអចលនទ្រព្យ ..... ៦៦
៤.១៥. ការមិនទាន់បានប្រមូលចំណូលពីកម្រៃសេវាសាធារណៈមួយចំនួន ..... ៦៧
៤.១៦. ការទូទាត់ និងការកត់ត្រាចំណាយ ..... ៦៧
៤.១៧. ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ..... ៦៩
៤.១៨. ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនពុំបានធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ ..... ៧០
៤.១៩. ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម ..... ៧១
៤.២០. ការកត់ត្រាចំណាយមិនទាន់បានត្រឹមត្រូវទៅនឹងអនុគណនីនៅក្នុងប្រកាសស្តីពីចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ ..... ៧១
៤.២១. កង្វះខាតក្នុងការប្រមូលផ្តុំគម្រោងកិច្ចលទ្ធកម្មដាក់ជាឡូត៍លទ្ធកម្ម ..... ៧៣
៤.២២. ភាពយឺតយ៉ាវក្នុងការកំណត់ទុនដំបូងនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ..... ៧៣
៤.២៣. ការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាក្រុមហ៊ុនពុំទាន់ត្រឹមត្រូវ...... ..... ៧៤
៤.២៤. ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការលទ្ធកម្ម ..... ៧៥
៤.២៥. ការវាយតម្លៃ និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដេញថ្លៃឈ្នះដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ៧៥
៤.២៦. ការពុំទាន់បានធ្វើរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋានជូនអាជ្ញាធរសវនកម្មជាតិ ..... ៧៦
៤.២៧. ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាចំណាយប្រចាំឆ្នាំ ..... ៧៦
៤.២៨. ការពុំបានរៀបចំតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់ទុកវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ..... ៧៦

៤.២៩. កង្វះខាតក្នុងការចាត់តាំងរដ្ឋទេយ្យករត្រួតពិនិត្យលើការចំណាយថវិកាបុរេប្រទាន និងពុំបានរក្សាទុកសក្ខីប័ត្រចំណាយថវិកា ..... ៧៧
៤.៣០. ការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅថ្ងៃដែលកិច្ចសន្យាចូលជាធរមាន ..... ៧៧
៤.៣១. ការចុះថ្ងៃខែលើសេចក្តីប្រកាសស្តីពីក្រុមសីលធម៌លទ្ធកម្មក្រោយថ្ងៃវាយតម្លៃប្រគល់កិច្ចសន្យា ..... ៧៨
៤.៣២. បំណុលតឹងទារពីកម្រៃសេវាចេញលិខិតអនុញ្ញាតសាងសង់ ..... ៧៨
៤.៣៣. កង្វះយន្តការចំពោះម្ចាស់សំណង់ដែលបានទទួលលិខិតអនុញ្ញាតសាងសង់រួច មិនព្រមមកធ្វើការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន ..... ៧៩
៤.៣៤. ការអនុវត្តតួនាទីរបស់អង្គភាពថវិកាមិនទាន់ពេញលេញ ..... ៨០
៤.៣៥. ការស្នើសុំទូទាត់ប្រាក់បុរេប្រទានពុំមានសក្ខីបត្រភ្ជាប់មកជាមួយ ..... ៨០
៤.៣៦. ភាពយឺតយ៉ាវក្នុងការដោះស្រាយចុះបញ្ជីម៉ាក ..... ៨១
៤.៣៧. ការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានមិនអស់លទ្ធភាព ..... ៨១
៤.៣៨. ការទារបំណុលសារពើពន្ធនៅមានកម្រិត ..... ៨២
៤.៣៩. ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល(ឆ្នាំ២០២៤) ..... ៨៣
៤.៤០. ភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ..... ៨៤
**៥. សេចក្តីសន្និដ្ឋាន ..... ៨៥**

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២៤

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេប ដូចខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិឆ្នាំ២០២៤ អនុវត្តបានចំនួន២៧ ៣៨៩ ៧៩៨,៨លានរៀល ត្រូវជា ១៤,៥១%នៃ ផ.ស.ស. ហើយស្មើនឹង៩១,៦%នៃច្បាប់ហិរញ្ញវត្ថុ គឺមានការកើនឡើង៤,៨% ធៀបនឹងការអនុវត្តឆ្នាំ២០២៣។ ភាពមិនប្រាកដប្រជាខ្ពស់នៃបរិការណ៍ខាងក្រៅ ដូចជា៖ការអូសបន្លាយសង្គ្រាមនៅអ៊ុយក្រែន និងនៅមជ្ឈឹមបូព៌ា បានបង្កផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ខ្សែច្រវាក់ផ្គត់ផ្គង់ជាអន្តរជាតិ។ បន្ថែមលើនេះ ភាពតានតឹងខាងភូមិសាស្ត្រនយោបាយស្របជាមួយនឹងការកើនឡើងនៃនិន្នាការពហុប៉ូល និងការបែងចែកប្លុកសេដ្ឋកិច្ចនិងពាណិជ្ជកម្មបាននិងកំពុងកាត់បន្ថយនូវការចូលរួមក្នុងចរន្តសកលភាវូបនីយកម្ម។ ការប្រែប្រួលនៃលំហូរពាណិជ្ជកម្ម និងការវិនិយោគ ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ រួមជាមួយនឹងភាពមិនច្បាស់នៅក្នុងទីផ្សារហិរញ្ញវត្ថុបានធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មជាសកល និងបញ្ហាប្រឈមក្នុងស្រុកមួយចំនួន បានបង្កផលប៉ះពាល់ដល់មូលដ្ឋានប្រមូលចំណូលពី វិស័យមួយចំនួន។ វិស័យដែលជាចន្ទល់កំណើនសេដ្ឋកិច្ចជាតិ ត្រូវទទួលបានការអនុគ្រោះ និងលើកលែងពន្ធច្រើន រួមមាន វិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈវិស័យដែលជាប្រភពចំណូលធំសម្រាប់ចំណូលសារពើពន្ធក្នុងស្រុកសម្រេចបានកំណើនទាប ពិសេសវិស័យហិរញ្ញវត្ថុ វិស័យអចលនទ្រព្យ និងវិស័យសំណង់។ តាមលទ្ធផលនៃការធ្វើសវនកម្មលើចំណូលបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើង ថែមទៀតដូចមានបង្ហាញក្នុងចំណុចទី៣.លទ្ធផលសវនកម្ម។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **៣១ ០៣៨ ២០៦,២** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ៨,៨% ហើយស្មើនឹង**១៦,៨៤%** នៃផ.ស.ស ហើយបានថយចុះ**១១,០%** ធៀបនឹងការអនុវត្តឆ្នាំ២០២៣។ អនុលោមតាមមាត្រា៧០នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវសារាចរស្តីពីការធ្វើវិចារណកម្មចំណាយ និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤តាមរយៈការបង្អកចំណាយ ដើម្បីសម្របតាមបរិការណ៍ដែលចំណូលសារពើពន្ធ មិនអាចសម្រេចបានតាមផែនការកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ ការអនុវត្តសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាដោយផ្តោតលើកត្តាសំខាន់មួយចំនួន ដូចជា៖ (១)-ការគោរពវិន័យថវិកាក្នុងការអនុវត្តថវិកា (២)-ការកាត់សន្សំតាមថ្លៃទីផ្សារជាក់ស្តែងនិងការធានាបាននូវគុណភាពនៃទំនិញ និង(៣)-ការពង្រឹងសមត្ថភាពការរៀបចំផែនការថវិការបស់ក្រសួងស្ថាប័ន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្តជំរុញក្រសួង ស្ថាប័នក្នុងការកែលម្អចំណុចខ្វះចន្លោះក្នុងដំណើរការគ្រប់គ្រង និងប្រតិបត្តិការចំណាយរបស់ខ្លួនពាក់ព័ន្ធនឹងភាពត្រឹមត្រូវ អនុលោមភាព និងប្រសិទ្ធភាព តាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងអធិការកិច្ចហិរញ្ញវត្ថុ។

ថវិកាឆ្នាំ២០២៤ ត្រូវបានគិតគូរ និងរៀបចំឡើងដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ និងប្រាក់ចំណូលរបស់ប្រជាជន ក៏ដូចជាការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការគាំទ្រដល់ការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវគោលដៅសំខាន់នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។

ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវគោលនយោបាយសំខាន់ៗ រួមមាន៖ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យមប្រកបដោយបរិយាបន្ន ៣-បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញដោយបង្កើនការវិនិយោគដើម្បីបង្កើនតម្លៃបន្ថែមលើមូលដ្ឋានកំណើនសេដ្ឋកិច្ចដែលមានស្រាប់ ព្រមទាំងជំរុញឱ្យមានការវិនិយោគទៅលើប្រភពថ្មីនៃកំណើនដែលមានសក្តានុពលសេដ្ឋកិច្ច និងមានផលិតភាពខ្ពស់ ដើម្បីបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជន និងដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញផង និងជំរុញបង្កើនចំណូលថវិកាជាតិផង ៤-ពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈដោយផ្តោតសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័នតាមរយៈការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ទន្ទឹមគ្នានឹងការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាព

នៃការផ្ដល់សេវាសាធារណៈដោយឈរលើគោលការណ៍សមធម៌ គុណាធិបតេយ្យ និងចីរភាពថវិកា ៥-ជំរុញការបន្តអភិវឌ្ឍធនធានមនុស្ស និងមូលធនមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត រួមទាំងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកម្រិតទី១ជូនយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ ៦-ជំរុញការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាលតាមរយៈការលើកកម្ពស់គុណភាពសេវាសុខាភិបាលគួបផ្សំជាមួយនឹងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជាដែលអាចឆ្លើយតបនឹងគ្រោះអាសន្នដែលអាចកើតមានជាយថាហេតុ ៧-ជំរុញការបន្តកសាងប្រព័ន្ធគាំពារសង្គមតាមរយៈការបន្តពង្រឹងប្រព័ន្ធគាំពារសង្គមចំគោលដៅ និងការធ្វើស្ថាប័នូបនីយកម្មកម្មវិធីជាតិជំនួយសង្គមឱ្យកាន់តែមានប្រសិទ្ធភាព ព្រមជាមួយនឹងការបន្តពង្រឹងវិសាលភាពគ្របដណ្តប់ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនចាស់ជរា គ្រួសារក្រីក្រ និងងាយរងគ្រោះ ព្រមទាំងនិយោជិតដែលស្ថិតនៅក្រៅប្រព័ន្ធ ៨-ពង្រឹងភាពប្រកួតប្រជែង និងការជំរុញពិធកម្មសេដ្ឋកិច្ចកម្ពុជាក្នុងវិស័យសក្តានុពលនានា រួមមានវិស័យកសិកម្ម ដឹកជញ្ជូន និងឡូជីស្ទីក ព្រមទាំងបន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូចនិងមធ្យមដែលជាចន្ទល់កំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីការវិនិយោគថ្មីក្នុងការទាក់ទាញវិនិយោគ និងការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ ព្រមទាំងការកែលម្អបរិយាកាសធុរកិច្ចសំដៅគាំទ្រការស្តារសេដ្ឋកិច្ច និងធានាស្ថិរភាពកំណើន ៩-បង្កើនគុណភាព និងប្រសិទ្ធភាពនៃការវិនិយោគសាធារណៈជាទូទៅ បន្តការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងលើកកម្ពស់ជីវភាពប្រជាជន ក៏ដូចជាការផ្តល់សេវាសាធារណៈផ្សេងៗ ព្រមជាមួយនឹងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតងស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច និងគាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព ១០-បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅទាំងឡាយរបស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ព្រមជាមួយនឹងការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីអភិបាលកិច្ចល្អ គុណភាពនៃសេវាសាធារណៈ និងយុត្តិធម៌សង្គម ឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ១១-ពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ និង១២-គាំទ្រដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌអាណត្តិទី៤។ ទោះបីជាបានគិតគូរ

រៀបចំ និងអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចមានបង្ហាញក្នុងចំណុចទី៣.លទ្ធផលសវនកម្ម។

**ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**៣ ៣០២ ៩០១**,**៣** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៧**,**៥**% និងចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្ត អនុវត្តបានចំនួន **៣ ២៤៤ ០៧៥**,**៨** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៩**,**២**%។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តចំនួន**២ ២០៤ ៦០៧**,**៤** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**២**,**៩**% និងចំណាយថវិការបស់រដ្ឋបាល ក្រុង ស្រុក អនុវត្តបានចំនួន**២ ១៨៦ ៩៥៣**,**៣** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣**,**៧**%។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តចំនួន**១ ៣៣៤ ៣៨២**,**១** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **០**,**៣**% និងចំណាយថវិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបានចំនួន**១ ១៣១ ៣១៨**,**៣**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**១៤**,**៩**%។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចមានបង្ហាញក្នុងចំណុចទី៣.លទ្ធផលសវនកម្ម។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ច អនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជិកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថាន សាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះ រាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុ បន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទាន ផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តី ព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍ សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ ២០២៤ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាល រាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និង រៀបចំរបាយការណ៍សរុបចំនួន១០៣ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវ បានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃ ព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើ មូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការ អនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រម ទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តី សន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែក ជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការ

ការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះសំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតិយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០២៤ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២២៣/០២២ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- អនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យ១៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៤ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| សរុបចំណូល (I.១ + II.១) | **២៩ ៨៩៥ ៩៨០,០** | **២៧ ៣៨៩ ៧៩៨,៨** | **៩១,៦%** |
| សរុបចំណាយ (I.២ + II.២) | **៣៤ ០៤៨ ៤៨៦,៧**[*] | **៣១ ០៣៨ ២០៦,២** | **៩១,២%** |
| ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ | | **-៣ ៦៤៨ ៤០៧,៤** | |
| **I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ** | | | |
| **I.១.ចំណូលថវិកា** | **២៩ ២៦៧ ២៥៣,០** | **២៦ ១១២ ៥៦៩,៥** | **៨៩,២%** |
| ចំណូលចរន្ត (១+២) | ២៨ ៨៣៦ ៤៧៧,០ | ២៥ ៧១៧ ៨១២,២ | ៨៩,២% |
| ១. ចំណូលសារពើពន្ធ | ២៥ ៧៥៩ ០៦១,០ | ២២ ៥២៥ ៩៨១,៩ | ៨៧,៤% |
| ២. ចំណូលមិនមែនសារពើពន្ធ | ៣ ០៧៧ ៤១៦,០ | ៣ ១៩១ ៨៣០,៣ | ១០៣,៧% |
| ៣. ចំណូលផ្សេងៗ | ៤៣០ ៧៧៦,០ | ៣៩៤ ៧៥៧,៣ | ៩១,៦% |
| +ចំណូលផ្សេងៗក្នុងប្រទេស | ៣៦៣ ១២៦,០ | ៣៣៤ ៣៦៤,០ | ៩២,១% |
| +ហិរញ្ញប្បទានឥតសំណង | ៦៧ ៦៥០,០ | ៦០ ៣៩៣,៣ | ៨៩,៣% |
| **I.២. ចំណាយថវិកា** | **២៧ ៨៤០ ៦១០,៧** | **២៥ ៥០៤ ៥១២,១** | **៩១,៦%** |
| ១. ចំណាយចរន្ត | ២៣ ៧៦០ ៨៨៨,៧ | ២១ ៦៥៦ ៧៨២,៧ | ៩១,១% |
| ២. ចំណាយមូលធន | ៤ ០៧៩ ៧២២,០ | ៣ ៨៤៧ ៧២៩,៤ | ៩៤,៣% |
| **II.កិច្ចប្រតិបត្តិការចំណូល និងចំណាយថវិកាថ្នាក់ជាតិដែលបានអនុវត្តមិនឆ្លងកាត់រតនាគារជាតិ** | | | |
| II.១.ចំណូលផ្សេងៗសម្រាប់គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៦២៨ ៧២៧,០ | ១ ២៧៧ ២២៩,៣ | ២០៣,១% |
| II.២.ចំណាយមូលធនសម្រាប់គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៦ ២០៧ ៨៧៦,០ | ៥ ៥៣៣ ៦៩៤,១ | ៨៩,១% |

**<u>កំណត់សម្គាល់៖</u>** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២៤ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

---

(*)តួលេខនេះ បានដកចេញនូវឥណទានវិចារណកម្មចំណាយចំនួន ១ ៣៣៧ ៧៤៧លានរៀល និងបានបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន ៨៤៨ ៧៩០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៤ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **សរុបចំណូលថវិកា** | **៣ ៥៧២ ៦១៤,៦** | **៣ ៣០២ ៩០១,៣** | **៩២,៥%** |
| **សរុបចំណាយថវិកា** | **៣ ៥៧២ ៦១៤,៦** | **៣ ២៤៤ ០៧៥,៨** | **៩០,៨%** |
| **អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ** | | **៥៨ ៨២៥,៥** | |
| **I. ចំណូលថវិកា** | **៣ ៥៧២ ៦១៤,៦** | **៣ ៣០២ ៩០១,៣** | **៩២,៥%** |
| ក្នុងនោះចំណូលចរន្ត (១+២) | ២ ៤៥៣ ៣០០,០ | ២ ២៥៣ ៧៥៥,២ | ៩១,៩% |
| ១. ចំណូលសារពើពន្ធ | ២ ២១៤ ៧២១,០ | ១ ៩៤៦ ៦១៥,៦ | ៨៧,៩% |
| ២. ចំណូលមិនមែនសារពើពន្ធ | ២៣៨ ៥៧៩,០ | ៣០៧ ១៣៩,៧ | ១២៨,៧% |
| ៣. ចំណូលផ្សេងៗ | ១ ១១៩ ៣១៤,៦ | ១ ០៤៩ ១៤៦,០ | ៩៣,៧% |
| - ឧបត្ថម្ភពីថ្នាក់ជាតិ | ៩៩៤ ៨២៩,០ | ៩៤០ ០០៧,០ | ៩៤,៥% |
| • ឧបត្ថម្ភដល់រដ្ឋបាលរាជធានី ខេត្ត | ២២ ៥៧០,០ | ២២ ៥៧០,០ | ១០០,០% |
| • ការប្រគល់មុខងារអប់រំ | ៨៤ ៤២២,០ | ៨១ ២៨១,០ | ៩៦,៣% |
| • ការប្រគល់មុខងារសុខាភិបាល | ៨៨៧ ៨៣៧,០ | ៨៣៦ ១៥៦,០ | ៩៤,២% |
| - ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១២៤ ៤៨៥,៦ | ១០៩ ១៣៩,០ | ៨៧,៧% |
| **II. ចំណាយថវិកា** | **៣ ៥៧២ ៦១៤,៦** | **៣ ២៤៤ ០៧៥,៨** | **៩០,៨%** |
| ១. ចំណាយចរន្ត | ៣ ០២៨ ៨០១,២ | ២ ៧៣៦ ០៩០,៨ | ៩០,៣% |
| ២. ចំណាយមូលធន | ៥៤៣ ៨១៣,៤ | ៥០៧ ៩៨៥,០ | ៩៣,៤% |

**<u>កំណត់សម្គាល់៖</u>** កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២៤ ដកស្រង់ចេញពីច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

## ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៤ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **សរុបចំណូល** | **២ ២៧១ ៤៨៨,៥** | **២ ២០៤ ៦០៧,៤** | **៩៧,១%** |
| **សរុបចំណាយ** | **២ ២៧១ ៤៨៨,៥** | **២ ១៨៦ ៩៥៣,៣** | **៩៦,៣%** |
| **អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ** | | **១៧ ៦៥៤,១** | |
| **I. ចំណូលថវិកា** | **២ ២៧១ ៤៨៨,៥** | **២ ២០៤ ៦០៧,៤** | **៩៧,១%** |
| ១. ចំណូលមិនមែនសារពើពន្ធ | ១៤ ៩៦៣,០ | ៧ ៨៤៣,១ | ៥២,៤% |
| ២. ចំណូលផ្សេងៗ | ២ ២៥៦ ៥២៥,៥ | ២ ១៩៦ ៧៦៤,៣ | ៩៧,៤% |
| - ឧបត្ថម្ភពីថ្នាក់ជាតិ | ២ ២២៧ ៧៧៥,៥ | ២ ១៧៣ ៥៩៩,៦ | ៩៧,៦% |
| • ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក | ៥៦១ ០០៧,០ | ៥៦០ ៥១៤,៣ | ៩៩,៩% |
| • ការប្រគល់មុខងារអប់រំ | ១ ៦៦៦ ៧៦៨,៥ | ១ ៦១៣ ០៨៥,៣ | ៩៦,៨% |
| - ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០ ៣៤០,០ | ១៤ ៧៤៨,៧ | ៧២,៥% |
| - ឧបត្ថម្ភធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៨ ០០០,០ | ៧ ៩៩៨,០ | ១០០,០% |
| - ចំណូលផ្សេងៗដទៃទៀត | ៤១០,០ | ៤១៨,០ | ១០១,៩% |
| **II. ចំណាយថវិកា** | **២ ២៧១ ៤៨៨,៥** | **២ ១៨៦ ៩៥៣,៣** | **៩៦,៣%** |
| ១. ចំណាយចរន្ត | ២ ២៧១ ៤៨៨,៥ | ២ ១៨៦ ៩៥៣,៣ | ៩៦,៣% |

***កំណត់សម្គាល់៖*** កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២៤ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

## ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៤ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **សរុបចំណូល** (I.១+I.២) | **១ ៣២៩ ៨០៧,៨** | **១ ៣៣៤ ៣៨២,១** | **១០០,៤%** |
| **សរុបចំណាយ** (II) | **១ ៣២៩ ៨០៧,៨** | **១ ១៣១ ៣១៨,៣** | **៨៥,១%** |
| **អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ** | | **+២០៣ ០៦៣,៩** | |
| **I.១ ចំណូលថវិកា** (**កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់**) | **១ ១៥០ ៣៩៩,០** | **១ ១៥៤ ៩៧៣,៣** | **១០០,៤%** |
| -ចំណូលមិនមែនសារពើពន្ធ | ០ | ៣ ៦០២,៣ | |
| -ចំណូលផ្សេងៗ | ១ ១៥០ ៣៩៩,០ | ១ ១៥១ ៣៧១,០ | ១០០,១% |
| **I.២ ហិរញ្ញប្បទានដោយប្រភពអតិរេក** | **១៧៩ ៤០៨,៨** | **១៧៩ ៤០៨,៨** | **១០០,០%** |
| **II. ចំណាយថវិកា** | **១ ៣២៩ ៨០៧,៨** | **១ ១៣១ ៣១៨,៣** | **៨៥,១%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៧២ ២៣៥,៥ | ៦៣ ០៣៧,៤ | ៨៧,៣% |
| - ចំណាយសង្កាត់ចំណុះក្រុង | ១៣៦ ៨៨០,០ | ១០០ ៧៤៦,៦ | ៧៣,៦% |
| -ចំណាយឃុំ | ១ ១២០ ៦៩២,៣ | ៩៦៧ ៥៣៤,៣ | ៨៦,៣% |

<u>**កំណត់សម្គាល់៖**</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២៤ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. ការប្រកាសតម្លៃគិតពន្ធលើម៉ូតូនាំចូលមួយចំនួនមានលក្ខណៈពុំទាន់សមស្រប

អនុក្រឹត្យរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់ថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានភារកិច្ច៖ លើកសំណើគោលនយោបាយដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ និងរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារគ្រប់គ្រងប្រមូលពន្ធ និងអាករនាំចេញ នាំចូលលើទំនិញគ្រប់ប្រភេទ ជាពិសេសពិនិត្យពិចារណាក្នុងការកសាង និងអនុវត្តតារាងពន្ធគយ និងនីតិវិធីទាំងឡាយដែលទាក់ទងនឹងការងារគយ និងរដ្ឋាករឱ្យបានសមស្របទៅតាមដំណាក់កាលនីមួយៗ នៃការវិវត្តសេដ្ឋកិច្ចជាតិនិងអន្តរជាតិ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រង់ជំពូកទី៥ នាយកដ្ឋានផែនការ និងបច្ចេកទេសប្រការ១៧ បានបញ្ជាក់ថា នាយកដ្ឋានផែនការ និងបច្ចេកទេសបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា លើផែនការ និងបច្ចេកទេស មានភារកិច្ច ស្រាវជ្រាវ និងចងក្រងនូវទិន្នន័យតម្លៃគិតពន្ធគយលើទំនិញនាំចេញនាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាមភាពជាក់ស្តែងសម្រាប់ជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានចេញលិខិតស្តីពីការកែសម្រួលជាបណ្តោះអាសន្ននូវតារាងតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញនាំចូលម៉ូតូដែលមានឆ្នាំម៉ូដែលមុនឆ្នាំ២០១៨ និងម៉ូតូអគ្គិសនីនាំចូលសម្រាប់អនុវត្តចំពោះមុខទំនិញដែលផ្ទុកចូលមធ្យោបាយដឹកជញ្ជូននៅឯបរទេស (ម៉ូតូ) ដើម្បីនាំចូលមកព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ តទៅ រហូតដល់មានការកំណត់ថ្មី។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៤ នាយកដ្ឋានផែនការ និងបច្ចេកទេស បានធ្វើការកំណត់តម្លៃគិតពន្ធនាំចូលលើម៉ូតូប្រើប្រាស់រួចមួយចំនួនតូច នៅមានលក្ខណៈពុំទាន់បានសមស្រប និងត្រឹមត្រូវទៅតាមតម្លៃជាក់ស្តែង និងតម្លៃចម្លងការសម្រាប់អនុវត្តនៅឡើយ ដូចជាការប្រកាសតម្លៃគិតពន្ធនាំចូលម៉ូតូប្រើប្រាស់រួចម៉ាក USED VESPA SPRINT 125cc ផលិតឆ្នាំ២០១៧ តម្លៃគិតពន្ធនាំចូល ៨៥០ដុល្លារក្នុង១គ្រឿង ដោយពុំបានបូកបន្ថែម៣០%នៃតម្លៃគិតពន្ធនាំចូល និងម៉ូតូម៉ាក USED VESPA SPRINT 125cc ផលិតឆ្នាំ២០១៥ ចំនួន ០៥គ្រឿង ប្រកាសតម្លៃគិតពន្ធនាំចូល ៦៧០ដុល្លារក្នុង១គ្រឿង ដោយពុំបានបូកបន្ថែម៣០%នៃតម្លៃគិតពន្ធនាំចូលនៅឡើយ។ កត្តានេះ នាំឱ្យការប្រកាសតម្លៃគិតពន្ធនាំចូលលើម៉ូតូមួយចំនួនតូច មានលក្ខណៈពុំទាន់បានសមស្រប និងត្រឹមត្រូវដែលនាំឱ្យប៉ះពាល់ដល់ចំណូលពន្ធគយដែលត្រូវប្រមូល។

ឆ្លើយតបនឹងបញ្ហានេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា ចំពោះការប្រកាសតម្លៃគិតពន្ធលើទំនិញនាំចូលម៉ូតូប្រើប្រាស់រួចម៉ាក Vespa មិនទាន់បានត្រឹមត្រូវដោយពុំបានបូកបន្ថែម៣០% ជាការឆកល្វែងក្នុងការផ្ទៀងផ្ទាត់ឯកសាររបស់មន្ត្រី ជាពិសេសឯកសារដែលមានទំនិញច្រើនមុខ ហើយទំនិញដែលប្រកាសខុសមានចំនួនតិចតួច ក្នុងចំណោមបញ្ជីម៉ូតូសរុបពី ៦៣ ទៅ ១៤៧ គ្រឿង។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឱ្យចាត់វិធានការរកដំណោះស្រាយសមស្របចំពោះករណីនេះ។

**៣.១.២. ការពុំបានគ្រោងចំណូលពីការជួលអគារ ឬសំណង់ផ្សេងៗនៅក្នុងផែនការចំណូល**

អនុក្រឹត្យរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ជាក់ថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានភារកិច្ច៖ ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រង់ចំណុចការគ្រោងចំណូលថវិកាឆ្នាំ២០២៤ បានបញ្ជាក់ថា ការគ្រោងគិតចំណូលថវិកាចរន្តអាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចមានលើកឡើងខាងលើ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចជា៖ ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានលទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបានដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។ ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ដែលនាំឱ្យមានផលទុនដូចជា៖ កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹង និងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

តាមការចុះធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៤៖

- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ កម្ពុជាមានចំណូលកម្រៃប្រតិការផ្សេងៗទៀត ចំណូលពីការជួលអគារ ឬសំណង់ផ្សេងៗ ប៉ុន្តែការប្រមូលចំណូលពីការជួលអគារពុំត្រូវបានគ្រោងក្នុងផែនការចំណូលត្រូវប្រមូលក្នុងឆ្នាំ២០២៤។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើការប្រមូលចំណូលពីការជួលការិយាល័យពុំបានគ្រោងចំណូលថវិកាខាងលើនៅក្នុងគម្រោងចំណូលថវិកាសម្រាប់ឆ្នាំ២០២៤ ដែរ។

កត្តានេះនាំឱ្យការរៀបចំផែនការចំណូលមានភាពពុំទាន់ច្បាស់លាស់នៅឡើយ។

ឆ្លើយតបនឹងបញ្ហានេះ៖

- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានរៀបចំនិងគ្រោងចំណូលមិនមែនសារពើពន្ធពីការជួលអគារ ឬសំណង់ផ្សេងៗសម្រាប់ឆ្នាំ២០២៦ រួចហើយ។ និង

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានគ្រោងចំណូលពីការជួលបន្ទប់ការិយាល័យនេះរួចរាល់ហើយ។ ក្រសួងក៏ទើបតែទទួលបានការពិនិត្យ និងសម្រេចលើកិច្ចសន្យាជួលបន្ទប់ការិយាល័យថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៥ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.១.៣. វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់សមស្រប

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រង់ជំពូកទី៥ នាយកដ្ឋានផែនការ និងបច្ចេកទេស ប្រការ១៧ បានបញ្ជាក់ថា នាយកដ្ឋានផែនការ និងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើផែនការ និងបច្ចេកទេស មានភារកិច្ចស្រាវជ្រាវ និងចងក្រងនូវទិន្នន័យតម្លៃគិតពន្ធគយលើទំនិញនាំចេញ នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាមភាពជាក់ស្តែងសម្រាប់ជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធ។ លិខិតរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាស្តីពីការកែសម្រួលតារាងតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញចម្រុះនាំចូល នាំចេញមួយចំនួន បានបញ្ជាក់ថា តារាងតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណានេះ នឹងត្រូវដាក់ឱ្យអនុវត្តចំពោះទំនិញដែលចូលមកបំពេញបែបបទផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយចាប់ពីថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ ដល់ចុងឆ្នាំ២០២៤។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នាយកដ្ឋានផែនការ និងបច្ចេកទេស បានអនុញ្ញាតឱ្យក្រុមហ៊ុនជើងសារ និងក្រុមហ៊ុននាំចូលមួយចំនួនភ្ជាប់ឯកសារសម្រាប់កំណត់តម្លៃគិតពន្ធនាំចូលដូចជា៖ វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណមួយចំនួនមានលក្ខណៈពុំទាន់សមស្រប និងត្រឹមត្រូវនៅឡើយ ១. New Motorcycle GTR GINIO 2024 ប្រកាសទម្ងន់ ៣១២គីឡូក្រាម ប៉ុន្តែម៉ូតូម៉ាកដូចគ្នាផ្សេងៗទៀតប្រកាសទម្ងន់តែ ១០២គីឡូក្រាម ២.Frozen Chicken ក្នុងវិក្កយបត្រមាន ១ ៦០០កាតុង ប៉ុន្តែបញ្ជីវេចខ្ចប់មានតែ ១ ៤៩៦កាតុង ៣. ENGINE OIL 0៦មុខទំនិញបញ្ជីវេចខ្ចប់មាន ២១ Pallets ក្នុងអញ្ញត្តិបណ្ណមានតែ ១៧ Pallets ៤. USED Bicycles ក្នុងវិក្កយបត្រមានចំនួន៦៣២គ្រឿង ប៉ុន្តែបញ្ជីវេចខ្ចប់មានតែ

៥៦០គ្រឿង ៥. CLEAR float glass ចំនួន ១៨ប្រភេទ វិក្កយបត្រប្រកាសទំហំជាម៉ែត្រការ៉េ មិនទាន់ត្រឹមត្រូវ។ កត្តានេះ នាំឱ្យការប្រកាសយថាប្រភេទទំនិញនាំចូលមានលក្ខណៈពុំទាន់បានសមស្រប និងអាចនាំឱ្យប៉ះពាល់ដល់ចំណូលប្រាក់ពន្ធដែលត្រូវប្រមូល។

ឆ្លើយតបនឹងបញ្ហានេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺបន្ថែមថា៖ ១. ម៉ូតូ New Motorcycle GTR GINIO 2024 ប្រកាសទម្ងន់ ៣១២ គីឡូក្រាម ប៉ុន្តែម៉ូតូម៉ាកដូចគ្នាប្រកាសតែ ១០២គីឡូក្រាម ករណីនេះជាការប្រកាសទម្ងន់ម៉ូតូច្រឡំ ប៉ុន្តែទម្ងន់សរុបត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ បើផ្ទៀងផ្ទាត់ជាមួយទម្ងន់សរុប ករណីនេះមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ពន្ធអាករឡើយ ដោយហេតុថា ការប្រកាសតម្លៃគិតពន្ធគយផ្អែកលើឯកតា ចំនួនម៉ូតូ ២. Frozen Chicken ក្នុងវិក្កយបត្រមាន ១ ៦០០ កាតុង ប៉ុន្តែបញ្ជីវេចខ្ចប់មានតែ ១ ៤៩៦ កាតុង ករណីនេះជាការប្រកាសក្នុងបញ្ជីវេចខ្ចប់ច្រឡំ ប៉ុន្តែទម្ងន់សរុបត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ បើផ្ទៀងផ្ទាត់ជាមួយទម្ងន់សរុប ករណីនេះមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ពន្ធអាករឡើយ ដោយហេតុថាការប្រកាសតម្លៃគិតពន្ធគយផ្អែកលើឯកតាគីឡូក្រាម ៣. ENGINE OIL ៦មុខទំនិញ ក្នុងបញ្ជីវេចខ្ចប់មាន ២១ Pallets តែក្នុងអញ្ញត្តិប័ណ្ណមានតែ ១៧ Pallets: ករណីនេះជាការប្រកាសក្នុងបញ្ជីវេចខ្ចប់ច្រឡំ ប៉ុន្តែទម្ងន់សរុបត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ពន្ធអាករឡើយ ដោយហេតុថាការប្រកាសតម្លៃគិតពន្ធគយផ្អែកលើឯកតាចំនួនធុង ៤. USED Bicycles ក្នុងវិក្កយបត្រមាន ៦៣២គ្រឿង ប៉ុន្តែបញ្ជីវេចខ្ចប់មានតែ ៥៦០គ្រឿង : ករណីនេះជាការប្រកាសក្នុងបញ្ជីវេចខ្ចប់ច្រឡំ ប៉ុន្តែទម្ងន់សរុបត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ពន្ធអាករឡើយ ដោយហេតុថាការប្រកាសតម្លៃគិតពន្ធគយផ្អែកលើឯកតាចំនួនកង់ ៦៣២ គ្រឿង ៥. CLEAR Float GLASS ចំនួន ១៨ ប្រភេទ វិក្កយបត្រប្រកាសទំហំជាម៉ែត្រការ៉េ មិនទាន់ត្រឹមត្រូវៈ ករណីនេះជាការប្រកាសជាម៉ែត្រការ៉េមិនមានភាពស៊ីសង្វាក់គ្នា ប៉ុន្តែទម្ងន់សរុបត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកតាមមូលដ្ឋានទម្ងន់ តម្លៃប្រកាស គឺសមស្របតាមតារាងតម្លៃគិតពន្ធគយជាមូលដ្ឋានពិចារណាជាធរមាននាពេលនោះ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ឱ្យបន្តពង្រឹងការងារត្រួតពិនិត្យឯកសារបន្ថែមទៀត។

### ៣.១.៤. វិធានការលើក្រុមហ៊ុនដែលជំពាក់ថ្លៃឈ្នួលអចលនទ្រព្យ

អនុក្រឹត្យលេខ ៧២ អនក្រ បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែកទី៣ មាត្រា៤២ ត្រេទី២ បានចែងថា " ៦០ថ្ងៃគិតចាប់ពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់៖ ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវចាត់វិធានការលើបំណុលដែលត្រូវតឹងទារ និងត្រូវពិន័យយ៉ាងតិច ២% ក្នុងមួយខែលើចំនួនទឹកប្រាក់បំណុលដើម និងទឹកប្រាក់ពិន័យកន្លងមកដែលមិនបានបំពេញ

កាតព្វកិច្ចបង់សងជូនភាគីរដ្ឋ ដោយគិតចាប់ពីថ្ងៃដំបូងដែលបានកត់ត្រាជាបំណុលមិនមែនសារពើពន្ធ...”។

តាមការចុះធ្វើសវនកម្មនៅក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមខែមិថុនា ឆ្នាំ២០២៥ មានក្រុមហ៊ុនមួយចំនួនដែលបានជួលទីតាំងដីទំនេររបស់ក្រសួងខាងលើដោយនៅពុំទាន់បានបង់ថ្លៃឈ្នួលដី និងប្រាក់ពិន័យ២% ស្របតាមកិច្ចសន្យាជួលនៅឡើយ។ ដោយឡែក ទីតាំងអចលនទ្រព្យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនដែលបានជួលចំនួន ០៤កន្លែង ក៏ពុំបានកត់ត្រា និងតាមដានការប្រមូលចំណូល ឱ្យបានត្រឹមត្រូវផងដែរ។

អាស្រ័យហេតុនេះ ដើម្បីឱ្យការប្រមូលចំណូល និងការតាមដានបំណុលឱ្យបានត្រឹមត្រូវ ក្រសួងខាងលើ ត្រូវជំរុញក្រុមហ៊ុនបង់ថ្លៃឈ្នួលទីតាំងឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងករណីនេះ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណការ និងដឹកជញ្ជូនបានឯកភាព និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់ទៀត។

### ៣.១.៥. ភាពយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពកិច្ចសន្យាជួលទីតាំង

ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់មាត្រា៣៩ បានចែងថា "ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការជួលតាមរយៈកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលមានរយៈពេលមិនលើសពី ៥០ (ហាសិប) ឆ្នាំ”។ តាមការពិនិត្យលើខ្លឹមសារនៃកិច្ចសន្យាស្តីពីការជួលដី និងអាគារមណ្ឌលឃ្លាំងចំនួន ៩ទីតាំង របស់ក្រសួងពាណិជ្ជកម្ម,កិច្ចសន្យាជួលទីតាំងចំនួន ៣ទីតាំង របស់ក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពាណិជ្ជកម្មនៅពុំទាន់បានធ្វើបច្ចុប្បន្នភាពលើខ្លឹមសារដែលមានចែងក្នុងកិច្ចសន្យាជួលចំនួន ២ទីតាំង ដោយកិច្ចសន្យាទាំង២នេះ មានរយៈពេលលើសពី ៥០ឆ្នាំ និងក្រសួងអប់រំ យុវជន និងកីឡានៅមិនទាន់បានធ្វើបច្ចុប្បន្នភាពរយៈពេលជួលនៃកិច្ចសន្យាជួលទាំង ៣ទីតាំង។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងពាណិជ្ជកម្មបានស្រាយបំភ្លឺដូចតទៅ៖ យោងតាមលិខិតលេខ ៤៤០ សជណ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាលយល់ព្រមដូចខាងក្រោម៖

- បន្ថែមរយៈពេលនៃការអនុវត្តមាត្រា៩៩ នៃច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងការធ្វើនិត្យានុកូលកម្មឡើងវិញនូវលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធរហូតដល់ដំណាច់ឆ្នាំ២០២៦

- ពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាពថ្លៃឈ្នួលទីតាំងទ្រព្យឡើងវិញនោះ អនុញ្ញាតពន្យារយៈពេលនៃការធ្វើនីត្យានុកូលកម្មឡើងវិញនៃលិខិតគតិយុត្តទាំងនោះ រហូតដល់ដំណាច់ឆ្នាំ២០២៦ ឬរហូតដល់ស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេស និងសកលមានលក្ខណៈល្អប្រសើរឡើងវិញ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្ម នឹងរៀបចំធ្វើនីត្យានុកូលកម្មកិច្ចសន្យាជួលទីតាំងរបស់ក្រសួងនៅក្រោយឆ្នាំ២០២៦ តាមការណែនាំរបស់រាជរដ្ឋាភិបាល និងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងសំណង់នៃក្រសួងអប់រំ យុវជន និងកីឡាបានបញ្ជាក់ថា៖

- តាមរយៈលិខិតឧទ្ទេសនាមលេខ ២០៨៦ សហវ.អទច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចាត់ក្រុមការងារចុះសហការជាមួយក្រសួង ស្ថាប័ន ដើម្បីពិនិត្យការងារអនុវត្តកិច្ចសន្យាជួលទីតាំងរបស់រដ្ឋស្ថិតក្រោមការកាន់កាប់របស់ក្រសួង ស្ថាប័ន ដែលត្រូវធ្វើបច្ចុប្បន្នភាព ផ្អែកតាមការកំណត់ជាអាទិភាពសំខាន់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរបស់រដ្ឋាភិបាលឆ្នាំ២០១៩-២០២៣ តាមកម្មវិធីប្រតិភូត្រូវចុះមកក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ តែមិនបានអញ្ជើញមកតាមកាលបរិច្ឆេទឡើយ នាំឱ្យអង្គប្រជុំត្រូវលុបចោល។
- ក្រសួងអប់រំ យុវជន និងកីឡា ក៏បានរៀបចំកិច្ចប្រជុំពិនិត្យ ពិគ្រោះយោបល់ និងធ្វើបច្ចុប្បន្នភាពលើកិច្ចសន្យាជួលនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តម រដ្ឋលេខាធិការប្រចាំការ តែដោយអវត្តមានតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ទើបកិច្ចប្រជុំនេះពុំទទួលបានលទ្ធផល (លិខិតលេខ ៧០១៧ អយក.សទរ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា) ។
- ជាបន្តក្រសួងបានធ្វើលិខិតស្នើសុំតំណាងក្រសួងពាក់ព័ន្ធ ដើម្បីបង្កើតជាគណៈកម្មការអន្តរក្រសួងពិនិត្យ ពិគ្រោះយោបល់ និងធ្វើបច្ចុប្បន្នភាពកិច្ចសន្យាជួល (លិខិតលេខ ៣៤២ អយក.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១) ដើម្បីពិនិត្យតម្លៃឈ្នួលដែលទាបជាងតម្លៃទីផ្សារខ្លាំងឡើងវិញ ប៉ុន្តែដោយមានបញ្ហារាតត្បាតនៃជំងឺកូវីដ-១៩ (ទាំងពីរលើក) ទើបការងារអនុវត្តត្រូវអូសបន្លាយ។
- ក្រោយមកក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែសម្រួលប្រកាសស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ ពិគ្រោះយោបល់ និងធ្វើបច្ចុប្បន្នភាពកិច្ចសន្យាជួលសារជាថ្មី (លិខិតលេខ ៨៥៣ អយក.ប្រក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២)។
- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ក្រសួងអប់រំ យុវជន និងកីឡា បានប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ ពិគ្រោះយោបល់ និងធ្វើបច្ចុប្បន្នភាពកិច្ចសន្យាជួលក្រោយពីកិច្ចពិភាក្សារួចមក អង្គប្រជុំទាំងមូលបានឯកភាពគ្នាទាំងស្រុង ដោយរង់ចាំ

ប្រកាសស្តីពីវិធាន និងនីតិវិធីនៃការធ្វើនីត្យានុកូលកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញផ្សព្វផ្សាយជាផ្លូវការ ដើម្បីអាចអនុវត្តនីតិវិធីបន្តលើការកែសម្រួលកិច្ចសន្យាក្រុមហ៊ុនទាំងបីឡើងវិញទៅតាមគោលការណ៍ និងនីតិវិធីច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលបានកំណត់ ដើម្បីឆ្លើយតបនឹងអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

- តបតាមប្រកាសលេខ ៣៤០ សហវ.ប្រក.អទច ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មការអន្តរក្រសួង ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការពិនិត្យ និងធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ។ ឆ្លើយតបនឹងការងារនេះ ក្រសួងអប់រំ យុវជន និងកីឡា បានចាត់តាំងថ្នាក់ដឹកនាំចំនួន០២រូប ដើម្បីចូលរួមជាអនុប្រធាន និងជាសមាជិកនៃគណៈកម្មការធ្វើនីត្យានុកូលកម្មលិខិត គតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញរួចហើយ (លិខិតលេខ ៤១៣៦ អយក.អគរហ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣)។

តបតាមលិខិតលេខ ១៤១០១ សហវ.ល.ស.អទច ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងលិខិតលេខ ១៤៥ សហវ.ល.ស.អទច ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចាត់តាំងតំណាង ដើម្បីចុះពិនិត្យទីតាំងជាក់ស្តែងលើការបំបែកទំហំក្បាលដីជួលបន្តរយៈពេលវែងឱ្យបានច្បាស់លាស់ក្នុងការរៀបចំកិច្ចសន្យា ឬធ្វើនីត្យានុកូលកម្មឱ្យស្របតាមនីតិវិធីច្បាប់លើករណី ស្នើសុំផ្ទេរសិទ្ធិជួលរយៈពេលវែងលើដីទំហំ ៨២៨ ម៉ែត្រក្រឡា និងដីទំហំ ៤ ៤៤០ ម៉ែត្រក្រឡា។ ឆ្លើយតបនឹងការងារនេះ ក្រសួងអប់រំ យុវជន និងកីឡាបានចាត់ក្រុមការងារ ដើម្បីចូលរួមសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពិនិត្យរៀបចំធ្វើនីត្យានុកូលកម្មកិច្ចសន្យាជួលរបស់ក្រុមហ៊ុនទាំងបីឡើងវិញឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨។

### ៣.១.៦. ការពុំទាន់បញ្ចប់នីតិវិធីនៃការដោះដូរដីជាថ្នូរនឹងការសាងសង់អគាររដ្ឋបាលថ្មីរបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ

សារាចរណែនាំលេខ ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុចទី២ បានចែងថា "អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវកត់ត្រាទ្រព្យសម្បត្តិទាំងអស់ ដែលស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួននូវអចលនទ្រព្យ និងចលនទ្រព្យទាំងអស់....។ ទ្រព្យសម្បត្តិរដ្ឋទាំងអស់នេះត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយមានការចូលរួម និងត្រួតពិនិត្យក្នុងការប្រគល់ទទួលពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ"។

តាមការត្រួតពិនិត្យលើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋាននេះពុំទាន់បានកត់ត្រាបញ្ចូលអគាររដ្ឋបាល ដែលជាថ្នូរនឹងការសាងសង់អគាររដ្ឋបាលនេះ ដែលកំពុងប្រើប្រាស់បច្ចុប្បន្ននៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរពន្លឿននីតិវិធីពិនិត្យ និងវាយតម្លៃលើការដោះដូរឱ្យបានចប់សព្វគ្រប់ ដើម្បីឱ្យការកត់ត្រាទ្រព្យសម្បត្តិរដ្ឋបានត្រឹមត្រូវតាមអត្ថិភាពជាក់ស្តែងស្របតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងពាណិជ្ជកម្មបានស្រាយបំភ្លឺដូចតទៅ៖ ករណីនេះ ក្រសួងពាណិជ្ជកម្មបានបញ្ចប់នីតិវិធីនៃការធ្វើឯកជនភាវូបនីយកម្ម តាមរយៈប្រកាសអន្តរក្រសួងលេខ ០៩៥ ព.ណ.គន.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៥ ស្តីពីការផ្ទេរទីតាំងដីអតីតអគ្គនាយកដ្ឋានកាំកុងត្រូលចំនួន ២កន្លែង របស់ក្រសួងពាណិជ្ជកម្ម ជូនលោកស្រី សុង ធីតា ដើម្បីធ្វើបណ្ណកម្មសិទ្ធិកាន់កាប់ប្រើប្រាស់ស្របតាមច្បាប់។

### ៣.១.៧. ការកត់ត្រាបញ្ជីគណនេយ្យ (គណនីបេឡា) ពុំស្របតាមប្រព្រឹត្តិកម្មគណនី

ប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ៣ ឧបសម្ព័ន្ធទី២ ប្រព្រឹត្តិកម្មគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់គណនីចរន្តជារូបិយប័ណ្ណនៅធនាគារជាតិនៃកម្ពុជា។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៤ វិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូនបានកត់ត្រាគណនីបេឡា ចំណូលថ្លៃសិក្សា និងចំណូលផ្សេងៗ តែខាងផ្នែកឥណទាន ដែលមានទឹកប្រាក់សរុបចំនួន ២៦០ ៨៨៧ដុល្លារអាម៉េរិក ពុំត្រឹមត្រូវតាមប្រព្រឹត្តិកម្មគណនីនៃប្លង់គណនេយ្យសាធារណៈនៅឡើយ។

កត្តានេះ នាំឱ្យការអនុវត្តកិច្ចបញ្ជិកាគណនេយ្យទ្វេភាគពុំទាន់ត្រឹមត្រូវ និងមានប្រសិទ្ធភាពនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរណែនាំវិទ្យាស្ថានជាតិតេជោសែនសាធារណការ និងដឹកជញ្ជូនកត់ត្រាកិច្ចបញ្ជិកាគណនេយ្យទ្វេភាគឱ្យបានត្រឹមត្រូវតាមប្រព្រឹត្តិកម្មគណនេយ្យសាធារណៈ។

ក្រសួងសាធារណការ និងដឹកជញ្ជូនបានធ្វើការបំភ្លឺថា ក្រសួងនឹងអនុវត្តតាមអនុសាសន៍ខាងលើ និងជំរុញឱ្យវិទ្យាស្ថានជាតិតេជោសែនសាធារណការ និងដឹកជញ្ជូនអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃប្រកាស ។

### ៣.១.៨. កង្វះខាតក្នុងការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃការបង់ចំណូលបែងចែក

យោងតាមកិច្ចសន្យាស្តីពីការប្រគល់កិច្ចការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តរបស់ក្រុមហ៊ុនចំនួន៣ ត្រង់ប្រការ៣ បានចែងពីការបែងចែក (Revenue Sharing) លើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តដូចមានបង្ហាញក្នុងតារាង។ ចំណែកឯប្រការ៦ នៃកិច្ចសន្យាទាំង៣ខាងលើ ក៏បានចែងអំពីការត្រួតពិនិត្យ ចំពោះការអនុវត្តកិច្ចសន្យាដោយតម្រូវឱ្យក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែងរបស់ភាគី «ខ» ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃការបង់ចំណូល បែងចែក និងការអនុវត្តប្រមូលចំណូលស្របតាមការកំណត់ក្នុងប្រការ៣ និងប្រការ៤ នៃកិច្ចសន្យា។ ការត្រួតពិនិត្យនេះអាចធ្វើឡើងប្រចាំខែ ឬប្រចាំត្រីមាសតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទាំងពីរ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកពុំមានរបាយការណ៍ចំណូលដុលសម្រាប់ធ្វើការបែងចែកចំណូល (Revenue sharing) លើសេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជាមួយក្រុមហ៊ុនដូចមានចែងក្នុងកិច្ចសន្យារវាងក្រសួងនិងក្រុមហ៊ុននៅឡើយ។ ម្យ៉ាងទៀត ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏នៅពុំទាន់បានត្រួតពិនិត្យផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃការបង់ចំណូលបែងចែក (Revenue sharing) ប្រចាំខែ ឬប្រចាំត្រីមាសនៅឡើយ។

កត្តានេះអាចនាំឱ្យការបង់ចំណូលបែងចែក (Revenue Sharing) ពុំត្រឹមត្រូវតាមកិច្ចសន្យា។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការបែងចែកចំណូល (Revenue Sharing) ឱ្យមានប្រសិទ្ធភាពដូចមានចែងក្នុងកិច្ចសន្យា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូនធ្វើការបែងចែកចំណូល (Revenue sharing) ពីការផ្តល់សេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជូនបណ្តាក្រុមហ៊ុនផ្អែកតាមកិច្ចសន្យា។

### ៣.១.៩. ភាពយឺតយ៉ាវក្នុងការប្រមូលចំណូលសេវាសាធារណៈ

ប្រកាសអន្តរក្រសួងលេខ ១៤៦០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការផ្តល់សេវាសាធារណៈ ត្រង់ប្រការ២ បានចែងថា "សេវាសាធារណៈដែលផ្តល់ដោយក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវបានរៀបចំជាកម្រងសេវាសាធារណៈដែលមានតារាងលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២នៃប្រកាសអន្តរក្រសួង"។

បទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច វិធានស្តីពីការលើកទឹកចិត្ត ការពិន័យ និងទណ្ឌវាទ ត្រង់ចំណុច១៧ បានចែងថា "ការរៀបចំថវិកាប្រចាំឆ្នាំ ត្រូវគ្រោងចំណូលមិនមែនសារពើពន្ធ ដោយផ្អែកទៅលើមុខសញ្ញាចំណូលដែលបានពីប្រភពធនធានមានស្រាប់ ឬមុខសញ្ញាចំណូលដទៃទៀត ដែលរំពឹងថាអាចប្រមូលបានក្នុងឆ្នាំដែលប្រតិបត្តិថវិកា"។

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ជំពូកទី៤ មាត្រា៣៣ បន្ទាត់ទី៦ បានចែងថា "ការគ្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ត្រូវមានមូលដ្ឋានគ្រោងគិតចំណូលទៅតាមមុខចំណូលនីមួយៗឱ្យបានច្បាស់លាស់ ដោយផ្អែកលើបញ្ជីស្ថិតិបច្ចុប្បន្នភាព បញ្ជីសម្រង់ទិន្នន័យ និងស្ថានភាពនៃការអនុវត្តចំណូល និងបំណុលនាឆ្នាំកន្លងមក ការរំពឹងលើប្រភពចំណូលថ្មី តម្លៃសេវាសាធារណៈ ..."។

អាជ្ញាធរសវនកម្មសង្កេតឃើញថា មានក្រសួងចំនួន២ មានបញ្ហាកត់សម្គាល់៖

**១. ក្រសួងសាធារណការ និងដឹកជញ្ជូន**

តាមការពិនិត្យស្ថិតិស្ថានីយចំណតយានយន្តទូទាំងប្រទេសឆ្នាំ២០២៤ របស់នាយកដ្ឋានសាធារណៈក្រុងនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកមានចំនួនសរុប៩០ទីតាំង មានភាពយឺតយ៉ាវក្នុងការប្រមូលចំណូលសេវាសាធារណៈពីស្ថានីយចំណតយានយន្តខាងលើ ដើម្បីបង់ចូលថវិការដ្ឋឱ្យស្របតាមប្រកាសអន្តរក្រសួងខាងលើ។

**២. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

តាមការធ្វើសវនកម្មនៅអង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជា និងវិទ្យាស្ថានស្តង់ដារកម្ពុជា នៅពុំទាន់អាចប្រមូលចំណូលពីការផ្តល់សេវាសាធារណៈរបស់ខ្លួនឱ្យស្របតាមប្រកាសអន្តរក្រសួងលេខ ៨៣៦ សហវ.ប្រក.អទច ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានដូចជា៖ I.មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិលើឧបករណ៍បែងចែកវត្ថុរាវ(ហ្គាស), ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់ (កុងទ័រទឹក) និងឧបករណ៍វាស់អគ្គិសនី II.អគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជាលើការផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ លើកដំបូងដល់មន្ទីរពិសោធន៍ អនុលោម និងវិញ្ញាបនបត្រទទួលស្គាល់ដែលភ្ជាប់ជាមួយទំនិញនាំចេញ នាំចូលមួយលើក និង III. វិទ្យាស្ថានស្តង់ដារកម្ពុជាលើការពិគ្រោះផ្តល់យោបល់សម្រាប់ផលិតផល និងការអនុគ្រោះប្រព័ន្ធ(សម្រាប់១នាក់/១ថ្ងៃ/តាមការស្នើសុំ) និងការបណ្តុះបណ្តាលអំពីអនុលោមភាពស្តង់ដារនៅវិទ្យាស្ថាន(សម្រាប់អតិថិជន១នាក់/១ថ្ងៃ)។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គួរណែនាំអង្គភាពក្រោមឱវាទឱ្យខិតខំប្រមូលចំណូលពីការផ្តល់សេវាសាធារណៈបន្ថែមទៀត និងអនុវត្តប្រកាសអន្តរក្រសួងឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ៖

- ក្រសួងសាធារណការ និងដឹកជញ្ជូននឹងរៀបចំបទដ្ឋានគតិយុត្តបន្ថែមដើម្បីប្រមូលចំណូលនេះ។
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានឯកភាពលើខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ ហើយនឹងព្យាយាមកែលម្អនូវចំណុចខ្វះខាតដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

### ៣.១.១០. កង្វះខាតក្នុងការផ្ទៀងផ្ទាត់ចំណូលចំណាយសម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

សារាចរលេខ ០១១ សហវ.សរ.អថ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ ត្រង់ចំណុចIII.ក. ហើយត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយវិនិយោគប្រចាំឆ្នាំ២០២៤ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៤ ក្រសួងសាធារណការ និងដឹកជញ្ជូនបានអនុវត្តចំនួន២៨គម្រោង ហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ និងបានធ្វើរបាយការណ៍ចំនួន០៤ប្រភេទ តាមរយៈដីកាបញ្ជូន លេខ ០២០ សក.ហវ និងលេខ ០២១ សក.ហវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ជូនទៅអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប៉ុន្តែក្នុងចំណោមរបាយការណ៍នៃគម្រោងហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន០៤ប្រភេទនោះ មានតែមួយប្រភេទបានបំពេញត្រឹមត្រូវតាមគំរូឧបសម្ព័ន្ធនៃរបាយការណ៍ (របាយការណ៍ចំណាយសង្ខេបសរុបរួមសម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងក្រសួង ស្ថាប័នពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)។ ដោយឡែករបាយការណ៍ចំនួន៣ប្រភេទទៀត ក្រសួងសាធារណការ និងដឹកជញ្ជូននៅមិនទាន់បានរៀបចំ និងផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវតាមគំរូឧបសម្ព័ន្ធនៃសារាចរខាងលើនៅឡើយដូចជា កង្វះខាតហត្ថលេខាប្រធានទទួលបន្ទុកហិរញ្ញវត្ថុ និងកង្វះខាតហត្ថលេខារបស់រដ្ឋមន្ត្រី និងត្រាក្រសួង។

កត្តានេះនាំឱ្យការអនុវត្តតាមសារាចរខាងលើនៅពុំទាន់មានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរជំរុញការធ្វើរបាយការណ៍ផ្ទៀងផ្ទាត់ចំណូល ចំណាយគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ឱ្យបានត្រឹមត្រូវនិងសមស្របតាមសារាចរខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូននឹងអនុវត្តតាមអនុសាសន៍សវនកម្ម។

### ៣.១.១១. ភាពយឺតយ៉ាវក្នុងការបង់ចំណូលចូលថវិកាជាតិ

ក្នុងបរិបទនៃការអនុវត្តថវិកាកម្មវិធី និងថវិកាសមិទ្ធកម្មឱ្យទទួលបានជោគជ័យតម្រូវឱ្យអង្គភាពថវិកាទទួលបានថវិកាគាំទ្រកម្មវិធីឱ្យបានទាន់ពេលវេលា ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញបទបញ្ញត្តិ ដើម្បីគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធដោយតម្រូវឱ្យអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ ថ្នាក់ក្រោមជាតិដែលជាសក្ខីបត្រមូលដ្ឋាន សម្រាប់គណនេយ្យករសាធារណៈនៅរតនាគារ ដើម្បីបំពេញនីតិវិធីកត់ត្រាជាចំណូលថវិកាជាតិនៅរៀងរាល់ចុងខែនីមួយៗ ដើម្បីប្រមូលផ្តុំធនធាន និងបែងចែកជូនអង្គភាពថវិកាអនុវត្តកម្មវិធី និងសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។ តាមការពិនិត្យរបាយការណ៍ធនាគារអំពីគណនីទទួលចំណូលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅខែធ្នូ ឆ្នាំ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គណនីទទួលចំណូលចំនួន០៤ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ពុំទាន់បានផ្ទេរសមតុល្យទៅគណនីទោលរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីបង់ចំណូលថវិកាឆ្នាំ២០២៤។

ការខកខានក្នុងផ្ទេរសមតុល្យគណនីទទួលចំណូលនៅធនាគារដៃគូទៅគណនីទោលរបស់រតនាគារឱ្យបានទាន់ពេលវេលានាំឱ្យរបាយការណ៍ចំណូលមានកំហុសនូវទឹកប្រាក់ដែលពុំទាន់បានផ្ទេរ និងថែមទាំងពន្យាពេលដល់ការប្រមូលផ្តុំធនធានសម្រាប់ការបែងចែកដល់អង្គភាពថវិកា។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍គួរផ្ទេរសមតុល្យគណនីទទួលចំណូលទៅគណនីទោលរបស់អគ្គនាយកដ្ឋានរតនាគារជាតិឱ្យបានទាន់ពេលវេលា។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកឡើងថា សមតុល្យគណនីទទួលចំណូល (ត្រឹមខែធ្នូ ឆ្នាំ២០២៤) សរុបចំនួន ២ ៥២៦ ០០៩.០៨ដុល្លារអាម៉េរិក និងចំនួន៥៧ ៨៣៩ ២៧២.៧៨រៀល គឺជាចំណូលដែលបាននៅចុងខែធ្នូ ក្រោយពេលបិទចំណូលប្រចាំឆ្នាំ ដូចនេះជាសន្យានុម័តមិនអាចបង្វែរទាន់សម្រាប់ចាត់ជាចំណូលក្នុងឆ្នាំ២០២៤បានឡើយ។ ប៉ុន្តែត្រូវបានបង្វែរចូលថវិកាជាតិនៅដើមខែមករា ឆ្នាំ២០២៥ និងកត់ត្រាជាចំណូលឆ្នាំ២០២៥។

ដើម្បីបង់ចំណូលចូលថវិកាជាតិឱ្យបានទាន់ពេលវេលា អាជ្ញាធរសវនកម្មជាតិសូមស្នើឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផ្ទេរសមតុល្យគណនីទទួលចំណូលទៅគណនីទោលរបស់អគ្គនាយកដ្ឋានរតនាគារជាតិមុនដំណាច់ឆ្នាំ២០២៤ ជាមុនសិន រួចរៀបចំសលាកបត្របង់ ឬបង្វែរប្រាក់ចំណូលចូលគណនីចំណូលថវិកាជាតិសម្រាប់ការិយបរិច្ឆេទ២០២៤នៅក្នុងកំឡុង ខែមករា នៃឆ្នាំបន្ទាប់ ដើម្បីកត់ត្រាប្រាក់ចំណូលឱ្យត្រឹមត្រូវតាមឆ្នាំថវិកា។

### ៣.១.១២. ការពុំបានផ្ទេរចំណូលពីការប្រាក់ចូលថវិកាជាតិ

ដើម្បីកៀគរចំណូលថវិកា និងពង្រឹងវិន័យចំពោះការអនុវត្តថវិកាជាតិ សភាជាតិបានអនុម័តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/ ០០១ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ ត្រង់មាត្រា២៦ បានចែងថា "...ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវបង់ចំណូលមិនមែនសារពើពន្ធទាំងអស់ចូលក្នុងគណនីទោលរតនាគារ ដោយមិនត្រូវប្រើប្រាស់ចំណែកណាមួយនៃប្រាក់ចំណូលយកទៅកាត់កងដោយត្រង់ជាមួយនឹងចំណាយ ឬរក្សាទុកសម្រាប់ចំណាយពិសេសណាមួយឡើយ..."។ តាមការពិនិត្យរបាយការណ៍ធនាគារគណនីទទួលចំណូលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅខែមករា ឆ្នាំ២០២៥ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គណនីទទួលចំណូលចំនួន៤ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានទទួលការប្រាក់ពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០២៤ សរុបចំនួន ៣១ ៥៨៨.៩៧ដុល្លារអាម៉េរិក និងចំនួន ៤៦ ៧០០ ៩២៨.៧៨រៀល ដែលត្រូវបង់ចូលជាចំណូលថវិកាជាតិគណនី ៧៦០១៣ ការប្រាក់នៃប្រាក់បញ្ញើ (ចំណូលបានមកពីការប្រាក់នៃគណនីប្រាក់បញ្ញើនៅធនាគារ) ប៉ុន្តែក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បែរជាបង្វែរប្រាក់ចំណូលពីការប្រាក់ខាងលើចូលគណនីប្រាក់រង្វាន់របស់ក្រសួង (គណនីប្រាក់រៀលលេខ ០០៣២៦៣៣៣១ និងគណនីប្រាក់ដុល្លារអាម៉េរិកលេខ ០០៣២៦៣៣៣២)។

ការពុំបានផ្ទេរចំណូលបានមកពីការប្រាក់នៃគណនីប្រាក់បញ្ញើនៅធនាគារទៅគណនីចំណូលថវិកាជាតិនាំឱ្យរបាយការណ៍ចំណូលត្រូវបានធ្វើឱ្យមានកំហុសនូវទឹកប្រាក់ខាងលើ។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍គួរផ្ទេរចំណូលពីការប្រាក់នៃគណនីប្រាក់បញ្ញើ (គណនីទទួលចំណូលទាំងបួនខាងលើ) នៅធនាគារទៅគណនីចំណូលថវិកាជាតិ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានឆ្លើយបំភ្លឺថា គណនីទទួលចំណូលខាងលើរបស់ក្រសួងត្រូវបានបង្កើតឡើងតាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបើកគណនីចរន្ត (មិនមែនជាគណនីប្រាក់បញ្ញើឡើយ) ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្តត្រឹមត្រូវតាមគោលការណ៍។ ក្នុងការបើកគណនីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានជ្រើសរើសយកប្រភេទគណនីចរន្តបូក ឬហៅថា Current Plus ដែលជាប្រភេទគណនីមានការប្រាក់តិចតួច ខុសពីគណនីប្រាក់បញ្ញើ។ ក្នុងកិច្ចប្រតិបត្តិការចំណូល សមតុល្យចុងខែនីមួយៗនៃគណនីនេះ ត្រូវបានបង្វែរចូលថវិកាជាតិ ប្រាក់រង្វាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិភាគទានមូលនិធិកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើកលែងតែចំណូលនៅចុងខែនីមួយៗ ដែលទទួលបានក្រោយពេលបិទបញ្ជីប្រចាំខែ (ប្រសិនបើមាន) ទើបត្រូវចាត់ជាចំណូល និងបង្វែរប្រាក់នៅខែបន្ទាប់។ ចំពោះចំណូលទទួលបាននូវចុងខែនីមួយៗក្រោយការបិទបញ្ជីប្រចាំខែអាចទទួលបានការប្រាក់តិចតួចគួបផ្សំនឹងការប្រាក់ពីចំណែកប្រាក់រង្វាន់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដែលនៅសល់ក្នុងគណនីទទួលចំណូលដែលពុំ

ទាន់បានបង្វែរប្រាក់ទៅគណនីប្រាក់រង្វាន់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដូចនេះទើបមានចំណូលការប្រាក់ខ្លះដូចសវនករបានលើកឡើង។ ចំពោះគណនី ៧៦០១៣ ការប្រាក់នៃប្រាក់បញ្ញើ (ចំណូលបានពីការប្រាក់នៃគណនីប្រាក់បញ្ញើនៅធនាគារ) គឺជាគណនីសម្រាប់កត់ត្រាចំណូលការប្រាក់ពីប្រាក់បញ្ញើ (Fixed Deposit) ដែលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ពុំមានឡើយ។ ដូចនេះ ចំណូលការប្រាក់ខាងលើគឺជាចំណែកនៃប្រាក់រង្វាន់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលត្រូវប្រើប្រាស់សម្រាប់លើកទឹកចិត្តមន្ត្រី។

អាជ្ញាធរសវនកម្មជាតិសូមបញ្ជាក់ថា ចំណូលពីការប្រាក់ស្ថិតក្នុងចំណាត់ថ្នាក់ចំណូលពីផលហិរញ្ញវត្ថុដែលជាកម្មវត្ថុនៃការបង់ចូលថវិការដ្ឋ។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍គួរបង្កើតគណនីចរន្តដែលត្រឹមត្រូវតាមគោលការណ៍កំណត់ និងមិនគួររក្សាទុកប្រាក់ចំណូលទទួលបានសម្រាប់ចំណាយលើកទឹកចិត្តមន្ត្រីដោយគ្មានគោលការណ៍អនុញ្ញាតដោយរាជរដ្ឋាភិបាលឡើយ។ ដូចនេះ អាជ្ញាធរសវនកម្មជាតិស្នើឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.១៣. ការបង្វែរចំណូលចូលថវិកាជាតិ និងការរៀបចំសលាកបត្រចំណូលថវិកាជាតិសម្រាប់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត

សារាចរលេខ ០១១ សហវអថ.សរ. ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ ត្រង់ផ្នែកទី១ ចំណុច ក បានកំណត់ថា "ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិដើម្បីទុកប្រើប្រាស់ជាប្រយោជន៍ណាមួយបានឡើយ (ជំពូកទី៤ ផ្នែកទី២ និងមាត្រា៣៦ នៃអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣)។ ដូចនេះប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ជាកំហិត"។

សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ ត្រង់ចំណុច៩ បានកំណត់ថា "ការកត់ត្រាតាមដានឆ្លុះបញ្ចាំងចំណូលចំណាយលើប្រាក់ចំណូលដែលប្រមូលបាន និងការចំណាយប្រាក់រង្វាន់លើកទឹកចិត្តរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ននីមួយៗ ក្នុងការអនុវត្តនីតិវិធីផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវបានកំណត់ដូចតទៅ៖ នៅពេលប្រមូល ឬទទួលប្រាក់ចំណូលពីការផ្តល់សេវាសាធារណៈ និងការផាកពិន័យ រដ្ឋទេយ្យករចំណូលត្រូវកត់ត្រាតាមដានប្រាក់ចំណូលចែកចេញជាពីរចំណែក ដោយចំណែកទី១ ជាប្រាក់ចំណូលដែលត្រូវបង់ចូលថវិកាជាតិជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ។ ចំណែកប្រាក់ចំណូលនេះ ជាចំណូលពិតដែលក្នុងខែនីមួយៗ រដ្ឋទេយ្យករចំណូលត្រូវបង់ប្រាក់ចំណូល និងធ្វើសលាកបត្រ ចំណូលថវិកាជាតិដែលជាសក្ខីបត្រយោងសម្រាប់កត់ត្រាជាចំណូលថវិកាជាតិ។ រីឯចំណែកទី២

ជាប្រាក់ចំណូលដែលចាត់ទុកថាជាប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តសម្រាប់ចំណាយលើប្រាក់រង្វាន់លើកទឹកចិត្ត។ ជារៀងរាល់ខែ រជ្ជទេយ្យករចំណូលត្រូវបូកសរុបប្រាក់ចំណូលចំណែកទី២នេះ និងធ្វើសលាកបត្រចំណូលថវិកាជាតិ ដើម្បីជាមូលដ្ឋានសម្រាប់កត់ត្រាជាចំណូលថវិកាជាតិ និងសម្រាប់ការអនុវត្តនីតិវិធីទូទាត់លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត៉។

អាជ្ញាធរសវនកម្មសង្កេតឃើញថា មានក្រសួងចំនួន២ មានបញ្ហាកត់សម្គាល់៖

**១. ក្រសួងសាធារណការ និងដឹកជញ្ជូន**

តាមរយៈការពិនិត្យរបាយការណ៍ស្ថានភាពចំណូលឆ្នាំ២០២៤ របស់ក្រសួងសាធារណការ និងដឹកជញ្ជូនបានអនុវត្តការប្រមូលចំណូលសរុបចំនួន ៨៧ ៥៤៤ ៤៦១ ២៦៧រៀល ប៉ុន្តែការបង់ចំណូលចូលថវិកាជាតិ និងការអនុវត្តនីតិវិធីទូទាត់បានកត់ត្រាសរុបចំនួន ៨៤ ៨៣៨ ៣៦៣ ៧៦៧ រៀល ដោយមានគម្លាតនៃការបង្វែរចំណូលសរុបចំនួន ២ ៧០៦ ០៩៧ ៥០០រៀល។ ដោយសារការបង្វែរចំណូលចូលថវិកាជាតិអាចឱ្យការទទួលស្គាល់ និងការកត់ត្រាប្រាក់ចំណូលថវិកាថ្នាក់ជាតិនៅក្នុងឆ្នាំមិនបានត្រឹមត្រូវ និងទាន់ពេលវេលា។

**២. ក្រសួងសុខាភិបាល**

តាមការពិនិត្យរបាយការណ៍ចំណូលប្រចាំខែ របាយការណ៍បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត និងសលាកបត្របង់ចំណូលថវិកាជាតិនៃប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តក្នុងឆ្នាំ២០២៤ របស់ក្រសួងសុខាភិបាល ក្រសួងពុំទាន់បានរៀបចំសលាកបត្របង់ចំណូលថវិកាជាតិសម្រាប់កត់ត្រាប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តរបស់ក្រសួងជារៀងរាល់ខែនៅឡើយ ដោយធ្វើការនេះបីខែធ្វើម្តងៗ។

ក្រសួងសាធារណការ និងដឹកជញ្ជូនគួរធ្វើការបង្វែរចំណូលដែលអនុវត្តបាននៅក្នុងឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា និងក្រសួងសុខាភិបាល គួរណែនាំរជ្ជទេយ្យករចំណូលឱ្យរៀបចំសលាកបត្រចំណូលថវិកាជាតិ ដើម្បីកត់ត្រាប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តឱ្យបានទៀងទាត់រៀងរាល់ខែស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើង របស់អាជ្ញាធរសវនកម្មជាតិ៖

- ក្រសួងសាធារណការ និងដឹកជញ្ជូនបានលើកឡើងថា ថវិកាទូទាត់ប្រាក់រង្វាន់ខែធ្នូ ឆ្នាំ២០២៤ គឺជាតួលេខលម្អៀងរវាងរបាយការណ៍ស្ថានភាពបឋមស្តីពីការអនុវត្តចំណូលឆ្នាំ២០២៤ និងតារាងផ្ទៀងផ្ទាត់បង់ចំណូលថវិកាជាតិឆ្នាំ២០២៤ ដែលមិនទាន់ទទួលបានសលាកបត្រកត់ត្រាចំណូលថវិកាជាតិពីអគ្គនាយកដ្ឋានរតនាគារជាតិ។

- ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងសូមទទួលយកនូវអនុសាសន៍ ដែលបានលើកឡើង និងខិតខំយកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យស្របតាមសារាចរណែនាំខាងលើ។

**៣.១.១៤. កង្វះខាតក្នុងការអនុវត្តនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូល**

ប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រង់ជំពូកទី៤ ប្រការ១៣ "រជ្ជទេយ្យករចំណូលត្រូវកាន់បញ្ជីបេឡាដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់ប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅពុំទាន់បានកាន់កាប់បញ្ជីគណនេយ្យដោយចុះបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃទៅតាមនីតិវិធីគ្រប់គ្រងរដ្ឋទេយ្យចំណូល។

កត្តានេះនាំឱ្យការអនុវត្តប្រកាសខាងលើពុំទាន់មានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរអនុវត្តឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូនបានឆ្លើយបំភ្លឺថា ការប្រមូលចំណូលពីសេវាសធារណៈមួយភាគធំត្រូវធ្វើឡើងតាមប្រព័ន្ធព័ត៌មានវិទ្យា ហើយក្រសួងបានស្នើសុំបង្កើតក្រុមការងារដើម្បីធ្វើសន្ទានកម្មប្រព័ន្ធ E-Payment។

### ៣.១.១៥. ការប្រមូលកម្រៃសេវាសាធារណៈរបស់រដ្ឋមិនស្ថិតនៅក្រោមអនុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាល

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រង់មាត្រា២១ និងមាត្រា២៣ បានចែងថា កម្រៃសេវាសាធារណៈរបស់រដ្ឋ ត្រូវស្ថិតនៅក្រោមអានុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាក្នុងឆ្នាំ២០២៤ ក្រសួងសាធារណការ និងដឹកជញ្ជូន បានប្រមូលចំណូលពីកម្រៃការបង់ថ្លៃ (សិស្ស) ដោយមិនស្ថិតនៅក្រោមអនុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួងនៅឡើយ។

កត្តានេះនាំការអនុវត្តតាមអនុក្រឹត្យខាងលើនៅពុំទាន់មានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន (វិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន) គួរអនុវត្តឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូនកំពុងរៀបចំសំណើសុំគោលការណ៍កំណត់កម្រងសេវានានារបស់វិទ្យាស្ថានតេជោសែន សាធារណការនិងដឹកជញ្ជូន ដើម្បីប្រមូលចំណូល។

### ៣.១.១៦. កង្វះខាតក្នុងការពង្រឹងយន្តការ និងវិធានការតឹងរ៉ឹងចំពោះយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

សេចក្តីជូនដំណឹងលេខ ០៤៩ សជណ.សក.គតលទ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូនស្តីពីការពង្រឹងវិធានការយ៉ាងតឹងរ៉ឹងបន្ថែមចំពោះយានយន្តដឹកជញ្ជូនធុនធ្ងន់ដែលបើកបរលើបណ្តាញផ្លូវថ្នល់ ត្រង់មាត្រា២៦នៃច្បាប់ស្តីពីផ្លូវថ្នល់ និងត្រង់ចំណុចទី២ ចែងថា ក្នុងករណីម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនម្ចាស់រថយន្តធុន

ធ្ងន់ និងអ្នកបើកបររថយន្តធុនធ្ងន់ណាមួយនៅតែបណ្តែតបណ្តោយឱ្យដឹកជញ្ជូន ឬផ្ទុកលើសពី២០ (ម្ភៃ) ភាគរយ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បានខិតខំត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដោយបានពិន័យអន្តរការណ៍លើទម្ងន់សរុបនៃយានយន្ត។ ប៉ុន្តែគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅមិនបានពិន័យអន្តរការណ៍លើអ័ក្ស (ភ្លៅរថយន្ត) នីមួយៗ និងទម្ងន់សរុបរួចបូកបញ្ចូលគ្នាឱ្យស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៦០ នៃច្បាប់ស្តីពីផ្លូវថ្នល់នៅឡើយ។

កត្តានេះនាំឱ្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងសេចក្តីជូនដំណឹងខាងលើអនុវត្តមិនទាន់មានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូនបានរឹតបន្តឹងការអនុវត្តច្បាប់ដោយត្រូវពិន័យទាំងការផ្ទុកលើសទម្ងន់សរុប និងការផ្ទុកលើសទម្ងន់នៃភ្លៅនីមួយៗ។

**៣.១.១៧. ការបំបែកបណ្ណចំណាយដោយពុំធ្វើនីតិវិធីលទ្ធកម្ម**

ប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ផ្នែកទី២ ប្រការ១៨ កថាខណ្ឌទី៣ បានបញ្ជាក់ថា "រជ្ជទេយ្យករបុរេប្រទាន ឬរជ្ជទេយ្យករបុរេប្រទានរង ត្រូវចៀសវាងដាច់ខាតនូវការបំបែកគោលការណ៍ចំណាយ ឬបណ្ណចំណាយទៅតាមទីកន្លែង គោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ"។ ប្រកាសលេខ ៨៣៣ សហវ.ប្រក.អលសា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម ត្រង់ប្រការ១ បានកំណត់ថា "ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្មនៅក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ក្នុងនោះលទ្ធកម្មទំនិញទឹកប្រាក់ក្រោម៤០លានរៀល ត្រូវអនុវត្តវិធីសាស្ត្រស្ទង់តម្លៃ (ស.ត) ទឹកប្រាក់ចាប់ពី៤០លានរៀល ដល់ក្រោម ២០០លានរៀល ត្រូវអនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ (ព.ថ) ទឹកប្រាក់ចាប់ពី ២០០លានរៀល ដល់ក្រោម ១០ ០០០លានរៀល ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (ដ.ប.ស) និងចាប់ពី ១០ ០០០លានរៀលឡើង ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ)"។

តាមការពិនិត្យអាណត្តិនិយ័តកម្ម របាយការណ៍ចំណាយរជ្ជទេយ្យបុរេប្រទាន និងសំណុំឯកសារចំណាយរជ្ជទេយ្យបុរេប្រទានរបស់នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុនៃក្រសួងអភិវឌ្ឍន៍ជនបទ និងតាមការពិនិត្យលើអាណត្តិបើកប្រាក់ និងសក្ខីបត្រទូទាត់ចំណាយថវិការជ្ជទេយ្យបុរេប្រទាន (ចំនួន២ជុំ) របស់ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងឆ្នាំ២០២៤។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុនៃក្រសួងអភិវឌ្ឍន៍ជនបទបានចេញបណ្ណចំណាយសរុបចំនួន២៨ប័ណ្ណចំណាយសម្រាប់ទិញសម្ភារការិយាល័យ ដែលមានទឹកប្រាក់សរុបចំនួន៦៧ ៦៩០ ០០០រៀល ដោយមិនបានធ្វើការប្រមូលផ្ដុំការចំណាយដើម្បីអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ហើយក្រសួងសាធារណការ និងដឹកជញ្ជូនបានធ្វើការចំណាយថវិការជ្ជទេយ្យបុរេប្រទានជាច្រើនលើសម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ ដែលមានសរុបទឹកប្រាក់ចំនួន ១៧៤ ៩២៩ ៨០០ រៀល ដោយពុំបានអនុវត្តនីតិវិធីលទ្ធកម្មដែរ។

កត្តានេះ អាចនាំឱ្យការចំណាយថវិការជ្ជទេយ្យបុរេប្រទានអនុវត្តមិនទាន់ស្រប តាមខ្លឹមសារនៃប្រកាសខាងលើ។ ក្រសួងអភិវឌ្ឍន៍ជនបទ គួរណែនាំដល់នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូនគួរណែនាំដល់រជ្ជទេយ្យករបុរេប្រទានរបស់ខ្លួនអនុវត្តការចំណាយថវិការជ្ជទេយ្យបុរេប្រទានឱ្យបានស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ចំពោះករណីនេះ ក្រសួងទាំងពីរខាងលើបានទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងបន្តខិតខំធ្វើការកែលម្អសម្រាប់ការអនុវត្តការងារនៅឆ្នាំបន្ទាប់។

**៣.១.១៨. ការមិនមានរបាយការណ៍ ឬកំណត់ហេតុក្នុងការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក**

ប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រង់ប្រការ២៣ បានចែងថា "ការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងដោយអាណាប័ក ឬដោយអ្នកតំណាង ត្រូវធ្វើឱ្យញឹកញាប់បំផុត។ ឯកសារទាំងនោះត្រូវផ្ដល់ឱ្យរជ្ជទេយ្យករចំណូលធ្វើការកត់សម្គាល់ និងផ្ដល់នូវចម្លើយ ហើយត្រូវផ្ញើត្រឡប់ទៅអ្នកត្រួតពិនិត្យវិញ"។

តាមការធ្វើសវនកម្មនៅក្រសួងសាធារណការ និងដឹកជញ្ជូនសម្រាប់ការិយបរិច្ឆេទ ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមខែឧសភា ឆ្នាំ២០២៥ ក្រសួងសាធារណការ និងដឹកជញ្ជូន ពុំទាន់មានរបាយការណ៍ ឬកំណត់ហេតុស្ដីពីការត្រួតពិនិត្យផ្ទាល់ដោយអាណាប័ក ឬអ្នកតំណាងម្ដងណាឡើយ ។

កត្តានេះនាំឱ្យការអនុវត្តតាមប្រកាសខាងលើនៅពុំទាន់មានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុវត្តឱ្យស្របតាមប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើង របស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូនបានរៀបចំលិខិតស្នើសុំគោលការណ៍ចុះត្រួតពិនិត្យតាមអង្គភាពអនុវត្តការប្រមូលចំណូលស្របតាមខ្លឹមសារនៃប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

**៣.១.១៩. ការអនុវត្តវិធីសាស្ត្រលទ្ធកម្មមិនស្របទៅនឹងវិធីសាស្ត្រក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ**

ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ២៣ បានចែងថា "វិធីសាស្ត្រលទ្ធកម្មដោយឡែកអាចអនុវត្តបានដរាបណាមានលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ១៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ វិធីសាស្ត្រលទ្ធកម្មដោយឡែកអាចកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ឬផែនការលទ្ធកម្មកែតម្រូវបានលុះត្រាតែមានគោលការណ៍អនុញ្ញាតឱ្យអនុវត្តវិធីសាស្ត្រនេះរួចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" និងមាត្រា៣២ បានចែងថា "គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមផែនការលទ្ធកម្មដែលបានអនុម័តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមលទ្ធកម្មអង្គភាពថវិកាអគ្គនាយកដ្ឋានយុវជន បានអនុវត្តវិធីសាស្ត្រលទ្ធកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈដែលមានទឹកប្រាក់ចំនួន ៩១ ៨៩០ ០០០រៀល និងគម្រោងជួសជុលអគារយុវជននៅខេត្តស្វាយរៀងមានទឹកប្រាក់ចំនួន ៥៤៦ ៥០០ ០០០រៀល មិនទាន់ស្របទៅនឹងវិធីសាស្ត្រនៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានទទួលការអនុម័តរួចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបានបង្វែរពីវិធីសាស្ត្រពិគ្រោះថ្លៃ និងដេញថ្លៃក្នុងស្រុកមកអនុវត្តវិធីសាស្ត្រចរចាថ្លៃផ្ទាល់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ ឬអ្នកទទួលការ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិកាអគ្គនាយកដ្ឋានយុវជនឱ្យអនុវត្តវិធីសាស្ត្រលទ្ធកម្មឱ្យបានត្រឹមត្រូវ និងស្របទៅនឹងវិធីសាស្ត្រដែលបានកំណត់ក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រុមលទ្ធកម្មរបស់អង្គភាពថវិកាអគ្គនាយកដ្ឋានយុវជន សូមធ្វើការបញ្ជាក់ថា៖

**១. ការផ្គត់ផ្គង់ប្រេងឥន្ធនៈ៖**

- បានអនុវត្តនីតិវិធីពិគ្រោះថ្លៃចំនួន២ដងរួចហើយ ប៉ុន្តែលទ្ធផលពុំទទួលបានជោគជ័យ
- បានស្នើសុំអនុវត្តនីតិវិធីចរចាថ្លៃផ្ទាល់ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអនុវត្តតាមនីតិវិធីចរចាថ្លៃផ្ទាល់ដោយយោងលិខិតលេខ ១១១៦៦ សហវ.ល.ស.អលស ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្របខណ្ឌពេលវេលា ពុំគ្រប់គ្រាន់ក្នុងការស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់កែតម្រូវផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤ បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**២.ការផ្គូសផ្គុលអគារយុវជននៅខេត្តស្វាយរៀង៖**

- បានស្នើសុំផ្លាស់ប្តូរនីតិវិធីពីការដេញថ្លៃក្នុងស្រុកមកនីតិវិធីចរចាថ្លៃផ្ទាល់ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអនុវត្តតាមនីតិវិធីចរចាថ្លៃផ្ទាល់ដោយយោងលិខិតលេខ ៨៦៥៥ សហវ.ល.ស.អលសា ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- នីតិវិធីលទ្ធកម្មសំណង់មានលក្ខណៈស្មុគស្មាញ នាំឱ្យក្របខណ្ឌពេលវេលាពុំគ្រប់គ្រាន់ក្នុងការស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់កែតម្រូវផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤ បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៣.១.២០. ការចំណាយប្រាក់បេសកកម្មក្រៅប្រទេស(ក្រៅអាស៊ាន)មុនគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ១៥ បានបញ្ជាក់ថា "នីតិវិធីចំណាយប្រាក់បេសកកម្មក្រៅប្រទេសក្រៅពីប្រទេសអាស៊ាន អាណាប័កត្រូវស្នើសុំធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធសម្រាប់បញ្ជាក់ពីភាពចាំបាច់នៃការធ្វើបេសកកម្ម។ ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិត្រូវរៀបចំផែនការសកម្មភាពសម្រាប់បំពេញបេសកកម្ម ដោយរៀបចំគម្រោងចំណាយឱ្យបានពីចំងាយសម្រាប់រៀបចំនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយ និងរៀបចំបោះផ្សាយអាណត្តិបើកប្រាក់" និងសារាចរណែនាំលេខ ០១៣ សហវ.សរអថ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រង់ចំណុចខ គ្រីសទី៣ បានកំណត់ថា "មិនអនុញ្ញាតឱ្យចំណាយមុនលើចំណាយបេសកកម្មក្រៅប្រទេស ដោយមិនមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និង/ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ក្នុងករណីនៅតែនៅបន្តមានក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធត្រូវទទួលខុសត្រូវដោះស្រាយចំណាយនេះដោយផ្ទាល់ក្នុងក្របខណ្ឌក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្ទាល់ខ្លួន"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មានបានអនុវត្តការចំណាយប្រតិបត្តិការប្រាក់បេសកកម្មក្រៅប្រទេស (ក្រៅតំបន់អាស៊ាន) មុនគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មានគួធ្វើណែនាំដល់អង្គភាពថវិការបស់ខ្លួនឱ្យធ្វើការចំណាយប្រាក់បេសកកម្មឱ្យបានត្រឹមត្រូវតាមវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មានបានទទួលយកនូវអនុសាសន៍ សន្យាពង្រឹងការអនុវត្ត និងកែលម្អនូវចំណុចខ្វះខាតនេះ។

### ៣.១.២១. ការពុំបានទូទាត់ប្រាក់បេសកកម្មចូលគណនីបៀវត្សតាមប្រព័ន្ធធនាគារ

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ ត្រង់មាត្រា៣ បានបញ្ជាក់ ថា "គណនីបៀវត្សរបស់មន្ត្រីសាធារណៈនៅធនាគារ ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់ប្រាក់ដែលជាអត្ថប្រយោជន៍របស់មន្ត្រីសាធារណៈជាអាទិ៍៖ បុព្វលាភ ប្រាក់បំណាច់ ប្រាក់បេសកកម្ម ប្រាក់សង្គមកិច្ច ប្រាក់ឧបត្ថម្ភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម និងប្រាក់ឧបត្ថម្ភផ្សេងៗ" និងត្រង់មាត្រា៤ វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី៣ បានបញ្ជាក់ថា "ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទូទាត់ជូនមន្ត្រីសាធារណៈនូវមុខសញ្ញាចំណាយដូចមានចែងក្នុងមាត្រា៣ ដោយធ្វើការបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈដោយផ្ទាល់តាមប្រព័ន្ធធនាគារ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានសាច់ប្រាក់មុនតាមរយៈការអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុននីតិវិធីបុរេប្រទាន នីតិវិធីរជ្ជទេយ្យបុរេប្រទាន ឬនីតិវិធីផ្សេងៗទៀត ត្រូវធ្វើការទូទាត់ប្រាក់គ្រប់ប្រភេទដែលបើកផ្តល់ជូនមន្ត្រីសាធារណៈ ដោយត្រូវបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈដោយផ្ទាល់តាមប្រព័ន្ធធនាគារ"។

តាមការពិនិត្យអាណត្តិបើកប្រាក់ របាយការណ៍ចំណាយប្រាក់បេសកកម្ម និងសំណុំឯកសារទូទាត់ប្រាក់បេសកកម្មរបស់អង្គភាពថវិកាមន្ទីរពេទ្យជាតិ តេជោសន្តិភាព និងមន្ទីរពេទ្យហ្លួងម៉ែ ក្នុងឆ្នាំ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រជ្ជទេយ្យករបុរេប្រទានរបស់អង្គភាពថវិកាទាំងពីរខាងលើ មិនបានធ្វើការទូទាត់ប្រាក់បេសកកម្មជូនមន្ត្រីចុះបេសកកម្មដោយបង្វែរចូលគណនីបៀវត្សផ្ទាល់របស់មន្ត្រីដែលចុះបេសកកម្មនោះឡើយ ដោយរជ្ជទេយ្យករបុរេប្រទានបានបើកប្រាក់បេសកកម្មជាសាច់ប្រាក់ផ្ទាល់ឱ្យដល់មន្ត្រីចុះបេសកកម្មទៅវិញ ដែលមានទឹកប្រាក់សរុបចំនួន ១០៦ ៥២៥ ៦០០ រៀល ក្នុងនោះការទូទាត់ចំណាយប្រាក់បេសកកម្មនៅមន្ទីរពេទ្យហ្លួងម៉ែមានទឹកប្រាក់ចំនួន ៤៧ ៣៣២ ២០០ រៀល និងមន្ទីរពេទ្យជាតិ តេជោសន្តិភាព មានទឹកប្រាក់ ចំនួន ៥៩ ១៩៣ ៦០០រៀល។

កត្តានេះ នាំឱ្យយន្តការតាមដាន និងត្រួតពិនិត្យផ្ទៃក្នុងនៅមានការខ្វះចន្លោះ។

ក្រសួងសុខាភិបាល គួរណែនាំមន្ទីរពេទ្យទាំងពីរខាងលើឱ្យពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យផ្ទៃក្នុង ដើម្បីពិនិត្យតាមដាន និងជំរុញការទូទាត់ត្រង់នូវប្រាក់បេសកកម្មដែលត្រូវបើកផ្តល់ជូនមន្ត្រីសាធារណៈក្នុងការធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

ត្រង់ចំណុចនេះក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងសូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងជំរុញឱ្យមន្ទីរពេទ្យជាតិ តេជោសន្តិភាព និងមន្ទីរពេទ្យ ហ្លួងម៉ែ យកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យស្របតាមអនុក្រឹត្យខាងលើ។

### ៣.១.២២. ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃតាមសារព័ត៌មានពុំបានពេញលេញ

សារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច៧ បានបញ្ជាក់ថា "ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ត្រូវធ្វើឡើងជាចំហ និងទូលំទូលាយ។ ការផ្សព្វផ្សាយតាមរយៈសារព័ត៌មានត្រូវធ្វើឡើងឱ្យបានយ៉ាងតិចចំនួនពីរលើក"។

តាមការពិនិត្យការផ្សព្វផ្សាយសេចក្តីជូនដំណឹងដេញថ្លៃគម្រោងលទ្ធកម្មតាមកាសែតក្នុងឆ្នាំ២០២៤ របស់អង្គភាពលទ្ធកម្មនៃមន្ទីរពេទ្យជាតិ តេជោសន្តិភាព មន្ទីរពេទ្យ ហ្លួងម៉ែ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល និងក្រុមលទ្ធកម្មនៃសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្ម និងក្រុមលទ្ធកម្មខាងលើបានធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃគម្រោងលទ្ធកម្មមួយចំនួនតាមកាសែតបានតែមួយលើកប៉ុណ្ណោះ។

ក្រសួងសុខាភិបាល គួរណែនាំដល់អង្គភាពលទ្ធកម្ម និងក្រុមលទ្ធកម្មខាងលើឱ្យអនុវត្តការផ្សព្វផ្សាយសេចក្តីជូនដំណឹងដេញថ្លៃគម្រោងលទ្ធកម្មតាមសារព័ត៌មានឱ្យបានត្រឹមត្រូវតាមសារាចរណែនាំខាងលើ។

ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងសូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តជំរុញឱ្យមន្ទីរពេទ្យជាតិ តេជោសន្តិភាព មន្ទីរពេទ្យ ហ្លួងម៉ែ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង យកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យស្របតាមសារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែ មករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

### ៣.១.២៣. ភាពយឺតយ៉ាវក្នុងការស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង

ប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ជំពូកទី២ ផ្នែកទី១ ប្រការ៧ កថាខណ្ឌទី២ ត្រេទី៣ បានបញ្ជាក់ថា "ដើម្បីឱ្យការរៀបចំបង្កើតរជ្ជទេយ្យបុរេប្រទានបានឆាប់រហ័ស ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ត្រូវអនុវត្តតាមពេលវេលាកំណត់ ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវរៀបចំលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង រួចបញ្ជូនមក

អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ ដោយភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានដែលចុះហត្ថលេខា រួចដោយអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ នៃខែវិច្ឆិកា (មុនឆ្នាំអនុវត្តថវិកា)"។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ នៅមានភាពយឺតយ៉ាវក្នុងការស្នើសុំពិនិត្យលិខិតសំណើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង។ ចំណែកឯអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាលក៏មានភាពយឺតយ៉ាវក្នុងការស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងសំណើបង្កើតគម្រោងសម្រាប់បេសកកម្មក្នុងប្រទេស និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូងសម្រាប់ដំណើរការរបស់បណ្តាអង្គភាពនានាក្រោមឱវាទក្រសួង។ ទន្ទឹមគ្នានេះដែរ ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរៀបចំលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាននៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤។ ក្រសួងសុខាភិបាលទទួលបានប្រាក់រជ្ជទេយ្យបុរេប្រទានជុំដំបូងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤។

កត្តានេះ អាចនាំឱ្យមានផលប៉ះពាល់ដល់តម្រូវការប្រើប្រាស់ថវិកាជាប្រចាំ និងបន្ទាន់នៅចំពោះអង្គភាពថវិកានានាក្រោមឱវាទរបស់ក្រសួងខាងលើ។ ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ គួរណែនាំអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ឱ្យរួសរាន់ក្នុងការរៀបចំ និងបញ្ជូនលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលាស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ចំពោះករណីនេះ ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ សូមទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងបន្តកែលម្អសម្រាប់ការអនុវត្តការងារនៅឆ្នាំបន្ទាប់។

### ៣.១.២៤. ការមិនទាន់ស្កេន ឬទាញបញ្ចូលឯកសារភ្ជាប់ចូលក្នុងប្រព័ន្ធFMISសម្រាប់មុខងារលទ្ធកម្មពេញលេញ

សេចក្តីណែនាំលេខ ០០៦ សហវ. ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS សម្រាប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ បានកំណត់ពីមុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធ FMIS ដូចតទៅ៖ ១. ផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ ២. ផ្នែកគ្រប់គ្រងផែនការលទ្ធកម្ម ៣.ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃ ផ្នែកគ្រប់គ្រងកិច្ចសន្យា និងសេចក្តីណែនាំលេខ ០២៩ សហវ.សណន.បគហ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីអនុវត្តការងារសម្រាប់គ្រប់មុខសញ្ញាកិច្ចលទ្ធកម្មសាធារណៈក្នុងក្របខណ្ឌក្រសួង ស្ថាប័នតាមប្រព័ន្ធFMISទាំងស្រុង ត្រង់តារាងឧបសម្ព័ន្ធភ្ជាប់តាមសេចក្តីណែនាំត្រង់ចំណុច ក បាន

បញ្ជាក់ថា ការស្កេន ឬទាញបញ្ចូលក្នុងប្រព័ន្ធនៅឯកសារ ដូចជា៖ ១. សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ ២. សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ៣. សេចក្តីព្រាងកិច្ចសន្យា ៤. ពាក្យសុំដេញថ្លៃ (ឧបសម្ព័ន្ធ) ៥. សេចក្តីព្រាងកិច្ចសន្យា ៦. ប៉ាន់គំរូ កាតាឡុ/បញ្ជីប៉ាន់តម្លៃ ៧. ប្រតិទិនការងារសាងសង់/ជួសជុល ៨. សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ ៩. គំនូសប្លង់ (សំណង់) ១០. លក្ខណៈលម្អិតបច្ចេកទេស ១១. ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ និង១២. ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការអនុវត្តមុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធFMISរបស់អង្គភាពលទ្ធកម្មនៃក្រសួងព័ត៌មានពុំទាន់អនុលោមតាមសេចក្តីណែនាំខាងលើនៅឡើយ ដោយមន្ត្រីទទួលបន្ទុកលទ្ធកម្មមិនទាន់បានធ្វើការស្កេន ឬទាញឯកសារភ្ជាប់នៃសំណុំឯកសារលទ្ធកម្មបញ្ចូលក្នុងប្រព័ន្ធឱ្យស្របតាមសេចក្តីណែនាំខាងលើនៅឡើយ។ ជាមួយគ្នានេះ អង្គភាពលទ្ធកម្មរបស់ក្រសួងក៏មិនទាន់បានអនុវត្តទៅតាមលំហូរនៃការប្រើប្រាស់មុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធ FMIS ស្របតាមសេចក្តីណែនាំខាងលើនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មាន គួរធ្វើការណែនាំដល់អង្គភាពលទ្ធកម្មឱ្យធ្វើការអនុវត្តមុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធ FMIS ឱ្យបានពេញលេញស្របតាមសេចក្តីណែនាំខាងលើ។

ក្រសួងព័ត៌មានសូមធ្វើការបញ្ជាក់ថា៖ ទោះបីកន្លងមក ការអនុវត្តមុខងារលទ្ធកម្មពេញលេញនៃប្រព័ន្ធFMIS របស់អង្គភាពលទ្ធកម្មក្រសួងព័ត៌មានបានអនុវត្តសមស្របរួចរាល់នូវគម្រោងតាមផែនការលទ្ធកម្មដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុម័តក៏ដោយ ក៏យើងខ្ញុំនឹងខិតខំអនុវត្តកិច្ចលទ្ធកម្មឱ្យបានកាន់តែប្រសើរថែមទៀត។

### ៣.១.២៥. ភាពយឺតយ៉ាវក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនទទួលការ

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈប្រកាសឱ្យប្រើដោយព្រះរាជក្រមនស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ត្រង់មាត្រា៦២ បានចែងថា "...អ្នកដេញថ្លៃឈ្នះត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ចសន្យាចូលជាធរមាន..." និងប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រង់ប្រការ៩ បានកំណត់ថា "ក្នុងរយៈពេល០៧ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវផ្តល់លិខិតប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ដើម្បីដំណើការចុះកិច្ចសន្យា។ ការខកខានរបស់អ្នកដេញថ្លៃក្នុងការផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាគឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការចាត់ទុកជាមោឃៈនៃការសម្រេចប្រគល់កិច្ចសន្យា ហើយអ្នកដេញថ្លៃឈ្នះនោះត្រូវបានកត់ត្រាក្នុងបញ្ជីខ្មៅ" ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនទទួលការមួយចំនួនមានភាពយឺតយ៉ាវក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា (១០%) មុនកិច្ចសន្យាចូលជាធរមាន។

អាស្រ័យហេតុនេះក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំគណៈកម្មាធិការលទ្ធកម្មឱ្យអនុវត្តកិច្ចលទ្ធកម្មឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃច្បាប់ខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ គណៈកម្មាធិការនៃក្រសួងអប់រំ យុវជន និងកីឡាសូមបញ្ជាក់ថា៖

- ចំពោះគម្រោងទី១ និងទី២ គោលការណ៍ធានាចំណាយនៅជំហានទី២ (ឆមាសទី២) បណ្តាលឱ្យការអនុវត្តកិច្ចលទ្ធកម្មអនុវត្តឆ្លងឆ្នាំ។ ដោយហេតុថា ថវិកាចំណាយប្រើប្រាស់ជំពូក៦០ (ថវិកាចរន្ត) ដូចនេះ រាល់ឯកសារគឺចុះកាលបរិច្ឆេទក្នុងឆ្នាំអនុវត្តថវិកា។ ដោយឡែក ចំពោះប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ១០% គឺចេញតាមកាលបរិច្ឆេទជាក់ស្តែងក្នុងឆ្នាំ២០២៥។
- គម្រោងទី៣ បណ្តាលមកពីការរងវិចារណកម្មចំណាយ និងនីតិវិធីលទ្ធកម្មប្រើពេលវេលាយូរ ដែលអនុវត្តចប់រួចរាល់រហូតដល់ឆ្លងឆ្នាំថវិកា។ ដោយឡែក ចំពោះប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ១០% គឺចេញតាមកាលបរិច្ឆេទជាក់ស្តែងក្នុងឆ្នាំ២០២៥។

ក្រសួងអប់រំ យុវជន និងកីឡា បានស្នើសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទូទាត់ឆ្លងឆ្នាំ២០២៥ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតជាគោលការណ៍ជូន។ តាមការពិនិត្យកាលបរិច្ឆេទលើលិខិតប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ១០% មិនមែនជាកំហុសរបស់ក្រុមហ៊ុនទេ។

### ៣.១.២៦. ការយកប្រតិបត្តិការចំណាយឆ្នាំ២០២៣មកទូទាត់ឥណទានថវិកាឆ្នាំ២០២៤

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣២៣/០០១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ត្រង់មាត្រា១១ បានចែងថា "កាលបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ" និងសារាចរ ០១៣ សហវ.សរអថ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រង់ចំណុចក គ្រីសទី៣ បានបញ្ជាក់ថា "ត្រូវអនុវត្តចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិ ត្រឹមឥណទានថវិកាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវទូទាត់ជម្រះចំណាយឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗដោយមិនអនុញ្ញាតឱ្យយោងទៅទូទាត់ និងប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់ឡើយ ព្រមទាំងត្រូវធានាការចូលរួមរបស់មន្ត្រីក្នុងចំនួនចាំបាច់ និងតិចបំផុតក្នុងការទ្រទ្រង់ដំណើរការរៀបចំ។ ក្នុងករណីមានត្រូវការចាំបាច់ជាក់ស្តែងក្នុងការអនុវត្តសកម្មភាពបន្ថែមដែលនាំឱ្យមានការចំណាយកើនឡើង ត្រូវលៃលកប្រើប្រាស់ឥណទានថវិកាផ្ទៃក្នុងដែលមានក្នុងឆ្នាំអនុវត្តថវិកា"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកានាយកដ្ឋានបឋមសិក្សា អង្គភាពថវិកាវិទ្យាស្ថានគរុកោសល្យរាធានីភ្នំពេញ និងអង្គភាពនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានបានយកប្រតិបត្តិការចំណាយឆ្នាំ២០២៣ ដែលមានទឹកប្រាក់ចំនួន ៥៤១ ៥៣៦ ០០០រៀល មកធ្វើការទូទាត់ឥណទានថវិកាសម្រាប់អនុវត្តសកម្មភាពឆ្នាំ២០២៤។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិកាខាងលើឱ្យធ្វើការទូទាត់ប្រតិបត្តិការចំណាយថវិកាឱ្យបានទាន់ពេលវេលានៃឆ្នាំថវិកា ដើម្បីជៀសវាងការយកប្រតិបត្តិការចំណាយឆ្នាំ២០២៣ មកធ្វើការទូទាត់ឥណទានថវិកាឆ្នាំ២០២៤។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការបញ្ជាក់ថា៖

១. នាយកដ្ឋានបឋមសិក្សាបានបញ្ជាក់ថា ចំពោះកញ្ចប់សម្ភារអំណានដំបូងថ្នាក់ទី១ លើកទី១នេះ បានគ្រោងចំណាយក្នុងផែនការថវិកាឆ្នាំ២០២៤ ហើយសកម្មភាពនេះសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ដែលត្រូវរៀបចំនៅពេលមហាវិស្សមកាលនាខែវិច្ឆិកា ឆ្នាំ ២០២៣ មុនឆ្នាំសិក្សា២០២៣-២០២៤ ដោយមិនប៉ះពាល់ដល់ការអនុវត្តថវិកាឆ្នាំ២០២៤ នោះទេ និងដោយយោងសារាចរណែនាំលេខ ០១០ សហវ.សរណ.អថ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣។ ត្រង់ចំណុចI.ខ. អំពីចំណាយថវិកាថ្នាក់ជាតិ ចំណុចទី៤ ដែលអាចទូទាត់សកម្មភាពឆ្លងឆ្នាំថវិកាបាន។ នាយកដ្ឋានបឋមសិក្សាសូមទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ នឹងមិនមានការទូទាត់ឆ្លងឆ្នាំថវិកានៅឆ្នាំបន្ទាប់ទៀតនោះទេ។

២. វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សិក្ខាសាលានេះ ធ្វើក្នុងខែធ្នូ ឆ្នាំ ២០២៣ ហើយកិច្ចការរៀបចំសិក្ខាសាលានេះជាការចាប់ផ្តើមដំបូង ដូចនេះការប្រមូលឯកសារសម្រាប់ទូទាត់មានការយឺតយ៉ាវមិនអាចស្នើសុំទូទាត់ទាន់ក្នុងថវិកាឆ្នាំ២០២៣បាន។

៣. នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន៖ ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលព័ត៌មាន និងស្រាវជ្រាវអប់រំប៊ូសាន (BMCoE) នៃសាធារណៈរដ្ឋកូរ៉េខាងត្បូង បានចុះអនុស្សរណៈយោគយល់គ្នាចំនួន២លើកមកហើយ គឺនៅអំឡុងឆ្នាំ២០០៤ និងឆ្នាំ ២០១៧កន្លងទៅនេះ។ កិច្ចសហប្រតិបត្តិការនេះ កម្មវិធីចុះទស្សនកិច្ចរបស់គណៈប្រតិភូសាធារណៈកូរ៉េខាងត្បូងបានកំណត់ចុះនៅរៀងរាល់ចុងឆ្នាំនីមួយៗ ដែលអង្គភាពត្រូវការប្រើប្រាស់ការចំណាយ និងធ្វើការទូទាត់ការចំណាយនៅឆ្នាំបន្ទាប់។ ដោយយោងសារាចរណែនាំលេខ ០១០ សហវ.សរណ.អថ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ត្រង់ចំណុចI.ខ. អំពីចំណាយថវិកាថ្នាក់ជាតិ ចំណុចទី៤ ដែលអាចទូទាត់សកម្មភាពឆ្លងឆ្នាំថវិកាបាន។ នៅឆ្នាំបន្តបន្ទាប់ខាងមុខទៀត

នាយកដ្ឋាននឹងខិតខំអនុវត្តថវិកា និងគ្រប់គ្រងការចំណាយថវិកាដោយអនុវត្តតាមនីតិវិធីឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួង។

**៣.១.២៧. ភាពយឺតយ៉ាវក្នុងការបង់ប្រាក់ ឬបង្វែរសាច់ប្រាក់បុរេប្រទានដែលនៅសល់**

សារាចរលេខ ០១១ សហវ.សរអថ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាជាតិឆ្នាំ២០២៤ ត្រង់ចំណុចគ ចុចពីរ បានបញ្ជាក់ថា "បុរេប្រទានរតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្តត្រូវបញ្ឈប់ការទទួលលិខិតបុរេប្រទានសម្រាប់ការបើកផ្តល់ប្រាក់បុរេប្រទានចុងក្រោយនៅវេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤ ហើយការទូទាត់ប្រាក់បុរេប្រទាននេះត្រូវរួតរះប្រមូលឯកសារសុំទូទាត់យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ចំពោះប្រាក់បុរេប្រទានដែលនៅសល់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលកណ្តាល ឬរតនាគាររាជធានី ខេត្តនៅធនាគារយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤" ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាបានបង្វែរសាច់ប្រាក់បុរេប្រទានដែលនៅសល់ពីការទូទាត់បុរេប្រទានចំនួន ៣ ២៦៨ ៥១១ ៦០០រៀលចូលថវិកាជាតិ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវធ្វើការបង់ប្រាក់ថវិកាបុរេប្រទានដែលនៅសល់បន្ទាប់ពីការទូទាត់ចំណាយឱ្យបានទាន់ពេលវេលា និងស្របតាមខ្លឹមសារនៃសារាចរខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុសូមធ្វើការបញ្ជាក់ថា ករណីនេះ គឺជាថវិកាសម្រាប់គាំទ្រការអនុវត្តស្តង់ដារសាលារៀនគំរូឆ្នាំ២០២៤។ ផ្អែកតាមលិខិតលេខ ១៩៥៧ អយក.ហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំបង្វែរឥណទានថវិកាពីសកម្មភាពផ្សេងៗទៅជួយគាំទ្រការអនុវត្តស្តង់ដារសាលារៀនគំរូ ដែលជាសកម្មភាពអាទិភាពស្របតាមកំណែទម្រង់សាលរៀនដែលជាចំណុចអាទិភាពរបស់រាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី៧នេះ។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ តាមរយៈលិខិតលេខ ៧២២៨ សហវ.លស.អថ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាពឱ្យក្រសួងអប់រំ យុវជន និងកីឡាបង្វែរឥណទានថវិកាពីសកម្មភាពផ្សេងៗ មកចំណាយគាំទ្រការអនុវត្តស្តង់ដារសាលារៀនគំរូឆ្នាំ២០២៤។ នៅពាក់កណ្តាលខែសីហា ឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡាបានទទួលថវិកាបុរេប្រទានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយសារក្របខណ្ឌពេលវេលាអង្គភាពស្នូល និងអង្គភាពគាំទ្រស្តង់ដារសាលារៀនគំរូចំនួន១៧ ក្នុងចំណោម ២៣អង្គភាពបានអនុវត្តសកម្មភាព។

ហេតុនេះ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤ តាមរយៈលិខិតលេខ ៧៤៤៩ អយក.ហវ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពន្យារពេលនៃការបិទបញ្ជីចំណាយថវិកាបុរេប្រទានសម្រាប់ចំណាយលើសកម្មភាពគាំទ្រស្តង់ដាសាលារៀនគំរូឆ្នាំ២០២៤។ ដោយសារក្រសួងអប់រំ យុវជន និងកីឡានៅរង់ចាំការឆ្លើយតបពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបធ្វើឱ្យការបង់ប្រាក់បុរេប្រទានដែលនៅសល់ចូលថវិកាជាតិវិញ មិនទាន់ពេលស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។ អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលយក និងពង្រឹងបន្ថែមស្របតាមខ្លឹមសារនៃសារាចរណែនាំពីការបិទបញ្ជីចំណូល ចំណាយថវិកាជាតិប្រចាំឆ្នាំ។

### ៣.១.២៨. ការប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដែលមានប៉ាតង់ពុំស្របតាមកម្មវត្ថុនៃដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីវិធាន និងនីតិវិធីគ្រប់គ្រងការប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៨ បានបញ្ជាក់ថា "ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ ដើម្បីផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះ" និងប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ ៧ បានតម្រូវឱ្យការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាអ្នកជាប់ពន្ធត្រូវមានប័ណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងនោះ។

តាមការចុះធ្វើសវនកម្ម ចំពោះការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន បានធ្វើការវាយតម្លៃ និងប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់គ្រឿងសង្ហារិមជូនក្រុមហ៊ុនដែលមានប៉ាតង់ពុំស្របនឹងកម្មវត្ថុនៃការស្ទង់តម្លៃ។

- អង្គភាពលទ្ធកម្មនៃក្រសួងសុខាភិបាលបានធ្វើការជ្រើសរើសក្រុមហ៊ុនដេញថ្លៃ និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដែលមានសកម្មភាពអាជីវកម្ម (ប័ណ្ណប៉ាតង់) ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ។

- អង្គភាពលទ្ធកម្មនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃលើគម្រោងលទ្ធកម្មផ្គត់ផ្គង់ទំនិញ និងសេវាមួយចំនួន ដែលក្រុមហ៊ុនទាំងនោះមានប័ណ្ណប៉ាតង់បញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ។

- មន្ទីររ៉ែ និងថាមពលខេត្តកំពង់ចាម និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានវាយតម្លៃ និងទទួលយកសំណុំឯកសារដេញថ្លៃ ឬពិគ្រោះថ្លៃនៃគម្រោងនីមួយៗដែលមានអ្នកផ្គត់ផ្គង់ចំនួន៣ ចូលរួម ក្នុងនោះមានក្រុមហ៊ុន ឬសហគ្រាសចំនួន ១ បានភ្ជាប់ប័ណ្ណប៉ាតង់ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ ឬពិគ្រោះថ្លៃ។

ឆ្លើយតបនៅការលើកឡើងខាងលើ អង្គភាពលទ្ធកម្មនៃអង្គភាពខាងលើ បានទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អ និងបន្តជំរុញអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

**៣.១.២៩. ភាពយឺតយ៉ាវក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង**

អនុក្រឹត្យ ១១៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យជាស៊ីមកំចាយមារជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់ជំពូក៤ មាត្រា៣៦ បានចែងថា "សាកលវិទ្យាល័យជាស៊ីមកំចាយមារត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេសតាមសំណើរបស់ក្រុមប្រឹក្សាភិបាល" ។ អនុក្រឹត្យ ២៨៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យជាតិបាត់ដំបងជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ អនុក្រឹត្យ ២៨៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យជាតិស្វាយរៀងជាគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រង់ជំពូក៤ មាត្រា៣៦ បានចែងថា " សាកលវិទ្យាល័យជាស៊ីមកំចាយមារ សាកលវិទ្យាល័យជាតិបាត់ដំបង និងសាកលវិទ្យាល័យជាតិស្វាយរៀងត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេសតាមសំណើរបស់ក្រុមប្រឹក្សាភិបាល"។ អនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃអង្គភាពសវនកម្មផ្ទៃក្នុង ត្រង់ជំពូក២ មាត្រា៤ បានចែង ថា "ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ព្រមទាំងបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាកលវិទ្យាល័យទាំង៣ខាងលើ នៅពុំទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការជំរុញសាកលវិទ្យាជាស៊ីមកំចាយមារ សាកលវិទ្យាល័យជាតិស្វាយរៀង និងសាកលវិទ្យាល័យជាតិបាត់ដំបងឱ្យពន្លឿនការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការបញ្ជាក់ថា៖

**១. សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ**

- ការរៀបចំ និងការប្រព្រឹត្តទៅ និងវិភាគមុខងាររបស់ក្រសួងអប់រំ យុវជន និងកីឡា មានការយឺតយ៉ាវ

- មន្ត្រីជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានតួនាទី និងភារកិច្ចជួយរៀបចំការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារឱ្យរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា
- សាកលវិទ្យាល័យបានផ្ញើឯកសារការរៀបចំការប្រព្រឹត្តទៅជាច្រើនលើកច្រើនសារទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យ និងសម្រេចពីអន្តរក្រសួង គឺក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

**២. សាកលវិទ្យាល័យស្វាយរៀង** ករណីគ្រឹះស្ថានយើងខ្ញុំមិនទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនោះ ដោយរង់ចាំនូវអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យស្វាយរៀង ដែលសេចក្តីព្រាងអនុក្រឹត្យនេះបានបញ្ជូនដល់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមុខងារសាធារណៈរួចរាល់ហើយ តែរហូតមកដល់ពេលនេះមិនទាន់បានការសម្រេចយ៉ាងណានៅឡើយទេ ដូចនេះហើយបានជាគ្រឹះស្ថានយើងខ្ញុំមិនទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅឡើយ។ ករណីខាងលើនេះ គ្រឹះស្ថានយើងខ្ញុំនឹងរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងនៅពេលមានអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យស្វាយរៀង យើងខ្ញុំនឹងរៀបចំតាមគោលការណ៍ដែលមានស្រាប់។

**៣. សាកលវិទ្យាល័យជាតិបាត់ដំបង** ទទួលស្គាល់នូវភាពយឺតយ៉ាវក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ដូចការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ហើយមកដល់ពេលនេះសាកលវិទ្យាល័យបានបញ្ជូនអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ និងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យជាតិបាត់ដំបង ដែលមានបញ្ចូលអង្គភាពសវកម្មផ្ទៃក្នុងទៅក្នុងរចនាសម្ព័ន្ធនៃប្រកាសអន្តរក្រសួងរបស់សាកលវិទ្យាល័យជាតិបាត់ដំបង និងបានបញ្ជូនទៅនាយកដ្ឋាននីតិកម្មរួចរាល់ហើយដែរ។

### ៣.១.៣០. កង្វះខាតក្នុងការទុកពេលវេលាសម្រាប់បណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ត្រង់មាត្រា៥១ ចែងថា "បន្ទាប់ពីការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវទុករយៈពេល១០(ដប់) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាដើម្បីអ្នកដេញថ្លៃចាញ់អាចស្នើសុំការបំភ្លឺ ឬបណ្តឹងតវ៉ាអំពីលទ្ធផលនៃការដេញថ្លៃ"។

តាមការចុះធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ និងអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាននៃក្រសួងបរិស្ថាន ពុំបានទុករយៈពេលបន្ទាប់ពីការចេញលិខិតសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាសម្រាប់បណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្មឱ្យស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ខាងលើ។ អង្គភាពលទ្ធកម្មនៃក្រសួងធនធានទឹក និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាបបានអនុវត្តកិច្ចលទ្ធកម្មស្តីពីការទិញគ្រឿងសង្ហារិម និងទិញសម្ភារការិយាល័យដោយពុំបានទុករយៈពេលគ្រប់១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការចេញលិខិតសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដែលឈ្នះដើម្បីឱ្យអ្នកដេញថ្លៃចាញ់សុំការបំភ្លឺ ឬប្តឹងតវ៉ាអំពីលទ្ធផលនៃការដេញថ្លៃនោះទេ។

ក្រសួងបរិស្ថាន និងក្រសួងធនធានទឹកនិងឧតុនិយម គួរណែនាំអង្គភាពលទ្ធកម្មរបស់ខ្លួនឱ្យអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃច្បាប់ខាងលើ។

ឆ្លើយតបលើករណីនេះ អង្គភាពលទ្ធកម្មនៃក្រសួងបរិស្ថាន និងក្រសួងធនធានទឹក និងឧតុនិយម សូមទទួលយក និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

**៣.១.៣១. ការប្រគល់ទទួលទំនិញពុំបានត្រឹមត្រូវស្របតាមនីតិវិធីនៃកិច្ចលទ្ធកម្ម**

សារាចរណែនាំលេខ ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១៩ បានបញ្ជាក់ថា "ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណ ទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានកំណត់ក្នុងកិច្ចសន្យា។ លទ្ធផលនៃការប្រគល់ទទួលឬការវាយតម្លៃលទ្ធផលការងារត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុប្រគល់ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងារ ហើយត្រូវមានការចុះហត្ថលេខាទទួលខុសត្រូវពីគ្រប់សមាជិកគណៈកម្មការប្រគល់ទទួល និងអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ។ ការប្រគល់ ទទួល ឬការវាយតម្លៃលទ្ធផលការងារ "ខ្យល់" (គ្មានទំនិញ សំណង់ ឬសេវា) ឬមានបរិមាណទំនិញ ទំហំការងារ ឬសេវាមិនគ្រប់ចំនួន និង/ឬមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គឺជាអំពើយុបយិតដែលត្រូវចៀសវាងឱ្យបានដាច់ខាត"។

តាមការចុះធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនផ្គត់ផ្គង់បានប្រគល់ទំនិញជូនអង្គភាពលទ្ធកម្មនៃក្រសួងបរិស្ថាន មុនគណៈកម្មការអន្តរក្រសួងចូលរួម ហើយក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន បានអនុវត្តកិច្ចលទ្ធកម្មស្នងតម្លៃនៃការទិញសម្ភារការិយាល័យ ដោយបានប្រគល់ទទួលទំនិញមួយមុខពុំស្របតាមយថាប្រភេទដែលមានចែងក្នុងកិច្ចសន្យា។ គណៈកម្មាធិការលទ្ធកម្មនៃក្រសួងធនធានទឹក និងឧតុនិយមបានធ្វើការទិញរថយន្តចំនួន១គ្រឿង ដែលមានទឹកប្រាក់ក្នុងកិច្ចសន្យាចំនួន ១៣៧ ៥០០ ០០០រៀល ដោយបានធ្វើការប្រគល់ទទួលរថយន្ត ជាមួយក្រុមហ៊ុននៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤

ប៉ុន្តែអ្នកកាន់ឃ្លាំងបានចុះកាលបរិច្ឆេទនៅក្នុងប័ណ្ណបញ្ចូលឃ្លាំងគឺនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ទៅវិញ។

ឆ្លើយតបនៅការលើកឡើងខាងលើ អង្គភាពលទ្ធកម្មរបស់ក្រសួងបរិស្ថាន និងគណៈកម្មាធិការលទ្ធកម្មនៃក្រសួងធនធានទឹក និងឧតុនិយម សូមទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

### ៣.១.៣២. កង្វះខាតក្នុងការប្រមូលសក្ខីបត្រគាំទ្រការចំណាយប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត

សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ ត្រង់ចំណុចលេខ៧.៥ វាក្យខណ្ឌទី១ បានកំណត់ថា "ការទូទាត់ប្រាក់បុរេប្រទាននេះ ជាការអនុវត្តនីតិវិធីដោយឡែក ដែលមិនតម្រូវចាំបាច់ឱ្យភ្ជាប់មកជាមួយនូវសក្ខីបត្រចំណាយជាក់ស្តែងពេញលេញឡើយ។ ប៉ុន្តែ រាល់ការចំណាយប្រាក់បុរេប្រទាន រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ននីមួយៗត្រូវមានសក្ខីបត្រចំណាយត្រឹមត្រូវ"។

តាមការពិនិត្យលើការចំណាយប្រាក់បុរេប្រទានពីរង្វាន់លើកទឹកចិត្តប្រចាំខែ ក្នុងឆ្នាំ២០២៤ របស់នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានខាងលើបានទទួលថវិការង្វាន់លើកទឹកចិត្តក្នុងឆ្នាំ២០២៤ ចំនួន ១៦៥ ៧៨០ ០០០ រៀល សម្រាប់ចំណាយលើការពិនិត្យ ដើម្បីផ្តល់លិខិតអនុញ្ញាត (ការបើកថ្មីបន្តការប្តូរទីតាំងនៃមន្ទីរពិសោធន៍ មន្ទីរសម្រាកព្យាបាល និងមន្ទីរពហុព្យាបាល)។ ប៉ុន្តែការចំណាយទឹកប្រាក់ខាងលើនេះមានសក្ខីបត្រគាំទ្រចំណាយពុំទាន់ពេញលេញនៅឡើយ។

ក្រសួងសុខាភិបាល គួរណែនាំនាយកដ្ឋានមន្ទីរពេទ្យអនុវត្តការចំណាយប្រាក់បុរេប្រទានពីរង្វាន់លើកទឹកចិត្តដោយមានភ្ជាប់នូវសក្ខីបត្រគាំទ្រចំណាយឱ្យបានត្រឹមត្រូវ។

ត្រង់ចំណុចនេះ ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងបានទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងជំរុញឱ្យនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលយកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យស្របតាមសារាចរណែនាំខាងលើ។

### ៣.១.៣៣. អង្គភាពអនុវត្តគម្រោងពុំមានឧបករណ៍បំពេញការងារគ្រប់គ្រាន់

អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា៦ ចំណុចទី២ បានបញ្ជាក់ថា "ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម «ក.អ.ជ» ត្រូវបានប្រើប្រាស់សម្រាប់ស្ថាប័នអនុវត្តលទ្ធកម្មណាដែលមានស្រាប់នូវបច្ចេកទេសជំនាញ កំលាំងពលកម្ម និងឧបករណ៍សម្រាប់បំពេញការងារក្នុងគម្រោងនោះ"។

តាមការពិនិត្យឯកសារគម្រោងកិច្ចលទ្ធកម្មសាធារណៈ (ការងារស្ថាបនាផ្លូវ ស្ពាន ការងារខួងអណ្តូង ការងារជីកស្រះ ការងារជួសជុលថែទាំផ្លូវខួប និងប្រចាំ) និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៤របស់នាយកដ្ឋានផ្លូវលំជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ១០ រួមមានៈ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម(អ្នកទទួលការ)នៃក្រសួងអភិវឌ្ឍន៍ជនបទ (អ្នកម្ចាស់ការ) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីរអភិវឌ្ឍន៍ជនបទទាំងខាងលើ ក្នុងនាមជាអ្នកទទួលការអនុវត្តគម្រោងនៃការងារខួងអណ្តូង ការងារជីកស្រះ ការងារថែទាំខួប និងប្រចាំផ្លូវជនបទ ពុំមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្តការងារទាំងនោះឡើយ។ ចំណែកឯ នាយកដ្ឋានផ្លូវលំជនបទក្នុងនាមជាអ្នកទទួលការអនុវត្តគម្រោងការងារស្ថាបនាផ្លូវ ស្ពាន ការងារថែទាំខួប និងប្រចាំផ្លូវជនបទបានអនុវត្តគម្រោងមួយចំនួនដោយមានគ្រឿងចក្រគ្រប់គ្រាន់ ប៉ុន្តែនាយកដ្ឋាននេះបានអនុវត្តគម្រោងមួយចំនួនទៀត ដោយពុំមានគ្រឿងចក្រគ្រប់គ្រាន់ឡើយ។

ករណីនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើការបំភ្លឺជូនថា ក្រសួងបានស្នើសុំដំឡើងថវិកាជារៀងរាល់ឆ្នាំ ដើម្បីយកថវិកាមួយផ្នែកសម្រាប់ទិញគ្រឿងចក្រ ប៉ុន្តែក្រសួងអភិវឌ្ឍន៍ជនបទមិនទាន់បានទទួលការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។ ថ្វីបើក្រសួងមិនមានគ្រឿងចក្រគ្រប់គ្រាន់ ប៉ុន្តែការស្ថាបនាស្ពាន ផ្លូវ នៅតែមានគុណភាពខ្ពស់ ដោយក្រសួងនិងមន្ទីរបានធ្វើការជួលគ្រឿងចក្របន្ថែមពីក្រុមហ៊ុនឯកជនទៅលើគ្រឿងចក្រដែលក្រសួងមានស្រាប់រួចហើយ។ ទោះបីជាយ៉ាងនេះក្តី ក្រសួងអភិវឌ្ឍន៍ជនបទនឹងបន្តស្នើសុំការគាំទ្រការទិញគ្រឿងចក្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានគ្រប់ចំនួន។

### ៣.១.៣៤. ការធ្វើបច្ចុប្បន្នភាពទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារពុំទាន់បានសមស្របតាមលិខិតបទដ្ឋានគតិយុត្ត

ដើម្បីគ្រប់គ្រងទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារឱ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសអន្តរក្រសួងលេខ ១៩៥ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាខាមូលនិធិជាតិជំនួយសង្គមរាជធានី ខេត្ត ត្រង់ប្រការ៣ ត្រេទី៣ បានចែងថា "សាខាមូលនិធិជាតិជំនួយសង្គមរាជធានី-ខេត្ត មានតួនាទីភារកិច្ចគ្រោងចំណាយរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍ផ្សេងៗប្រចាំខែប្រចាំឆ្នាំរបស់អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារ" និងត្រេទី៥ បានចែងថា "សាខាមូលនិធិជាតិជំនួយសង្គមរាជធានី-ខេត្ត មានតួនាទីភារកិច្ចធ្វើបច្ចុប្បន្នភាពដល់អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារនឹងត្រូវអនុវត្តនៅសាខា ម.ជ.ជ. រាជធានី ខេត្ត"។

តាមរយៈការចុះធ្វើសវនកម្មនៅសាខាមូលនិធិជាតិជំនួយសង្គមចំនួន៤ រួមមាន សាខា ម.ជ.ជ. ខេត្តកែប ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានគ្រប់គ្រងសេវា និងរបបឧបត្ថម្ភតាវកាលិកនៃមូលនិធិជាតិជំនួយសង្គមបានអនុវត្តការងារធ្វើបច្ចុប្បន្នភាពទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារ ជំនួសឱ្យសាខាមូលនិធិជាតិជំនួយសង្គមទាំង៤ខេត្តខាងលើទៅវិញ។ ទន្ទឹមនឹងនេះ តាមការសាកសួរថ្នាក់ដឹកនាំនាយកដ្ឋានគ្រប់គ្រងសេវា និងរបបឧបត្ថម្ភ តាវកាលិកបានបញ្ជាក់បន្ថែមថា ការងារធ្វើបច្ចុប្បន្នភាពទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារ នៅតាមបណ្ដាខេត្តផ្សេងៗទាំង២៥ រាជធានី ខេត្ត ក៏ត្រូវបានអនុវត្តដូចគ្នា។

ការធ្វើបច្ចុប្បន្នភាពទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងគ្រួសារពុំទាន់បានសមស្របតាមលិខិតបទដ្ឋានគតិយុត្ត អាចនាំឱ្យការអនុវត្តតួនាទី ភារកិច្ចពុំទាន់បានច្បាស់លាស់។ អាស្រ័យហេតុនេះ មូលនិធិជាតិជំនួយសង្គម គួរអនុវត្តឱ្យបានត្រឹមត្រូវតាមប្រកាសខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ មូលនិធិជាតិជំនួយសង្គម សូមទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ម.ជ.ជ. នឹងមិនអនុញ្ញាតជាគោលការណ៍ ឬចាត់តាំងនាយកដ្ឋានគ្រប់គ្រងសេវា និងរបបឧបត្ថម្ភតាវកាលិកឱ្យអនុវត្តការងារធ្វើបច្ចុប្បន្នភាពជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនជំនួសសាខា ម.ជ.ជ. រាជធានី ខេត្តទាំង ២៥ បន្តទៀតឡើយ។ ម.ជ.ជ. នឹងរៀបចំការបណ្តុះបណ្តាល និងគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាពជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដល់សាខា ម.ជ.ជ. រាជធានី ខេត្តទាំង២៥ ឱ្យបានចប់សព្វគ្រប់នៅដំណាច់ឆ្នាំ២០២៥។ ជាមួយគ្នានេះដែរ សម្រាប់តួនាទី និងភារកិច្ចរបស់សាខា ម.ជ.ជ. រាជធានី ខេត្តទាំង២៥ លើការទទួលខុសត្រូវក្នុងការធ្វើបច្ចុប្បន្នភាពជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន នឹងអនុវត្តពេញលេញទាំងស្រុងស្របតាមលិខិតបទដ្ឋានគតិយុត្តចាប់ពីដើមឆ្នាំ២០២៦ តទៅ។

### ៣.១.៣៥. កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ

ច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១១២០/៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់មាត្រា៧៣ បានចែងថា "អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិដែលកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារទ្រព្យសម្បត្តិរដ្ឋដោយត្រូវចាត់វិធានការគ្រប់រូបភាពដើម្បីទប់ស្កាត់ ឬបង្ក្រាបសកម្មភាពកេងប្រវ័ញ្ច ក្លែងបន្លំ រំលោភ កាន់កាប់ទ្រព្យសម្បត្តិដោយខុសច្បាប់ឬអំពើដែលបង្កអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ"។

តាមការពិនិត្យលើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង និងថយចុះឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសាធារណការ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋាននេះមានគ្រឿងចក្រចំនួន៩៥គ្រឿង ក្នុងនោះ នាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវមាន

ចំនួន ៥៥គ្រឿង និងនាយកដ្ឋានជួសជុល និងថែទាំផ្លូវមានគ្រឿងចក្រចំនួន ៤០គ្រឿង។ ប៉ុន្តែនាយកដ្ឋានខាងលើ នៅពុំទាន់មានទីកន្លែងសមស្របសម្រាប់រក្សាទុកគ្រឿងចក្រទាំងនោះដោយបច្ចុប្បន្នគ្រឿងចក្រមួយចំនួន ដែលកំពុងប្រើប្រាស់បាន ត្រូវបានរក្សាទុកនៅតាមការដ្ឋាន ហើយគ្រឿងចក្រមួយចំនួនទៀតត្រូវបានថែរក្សាទុកនៅខាងក្រោយទីស្តីការក្រសួង និងនៅគល់ស្ពានព្រែកតាម៉ាក់ និងព្រែកក្ដាម។

កត្តានេះអាចនាំឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋពុំទាន់មានប្រសិទ្ធភាព និងអាចឈានទៅរកការបាត់បង់ជាយថាហេតុ។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរពិចារណារៀបចំទីតាំងដែលមានទីធ្លាសមស្របសម្រាប់រក្សាទុកគ្រឿងចក្រ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

### ៣.១.៣៦. ការមិនទាន់បែងចែក និងវិភាជន៍ឥណទានថវិកាឱ្យបានពេញលេញទៅឱ្យអង្គភាពថវិកា

ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីត្រង់ចំណុចIII.២ កថាខណ្ឌទី២ ចែងថា "ដើម្បីឱ្យអង្គភាពថវិកាទទួលខុសត្រូវលើការអនុវត្តថវិកា និងការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ពិសេសដើម្បីបង្កើនគណនេយ្យភាពចំណាយឱ្យកាន់តែប្រសើររដ្ឋមន្ត្រីប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវវិភាជន៍ថវិកាឱ្យអង្គភាពថវិកាក្រោមឱវាទឱ្យបានទាន់ពេលវេលាសមស្របតាមការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនៃការអនុវត្តថវិកា"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រសួងសាធារណការ និងដឹកជញ្ជូននៅពុំទាន់បានបែងចែក ឬវិភាជន៍ថវិកាឱ្យបានពេញលេញទៅឱ្យនាយកដ្ឋាន និងអគ្គនាយកដ្ឋានដែលជាអង្គភាពថវិកា ដើម្បីទទួលខុសត្រូវលើការអនុវត្តថវិកាកម្មវិធីដោយប្រតិបត្តិការនៃការចំណាយថវិកាកម្មវិធីមួយចំនួននៅបន្តអនុវត្តក្នុងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ (អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ)។

អាស្រ័យហេតុនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរធ្វើការបែងចែក និងវិភាជន៍ឥណទានថវិកាទៅឱ្យអង្គភាពថវិការបស់ខ្លួនឱ្យបានពេញលេញ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូនបានធ្វើការវិភាជន៍ថវិកាលើអនុគណនីមួយចំនួន ហើយសម្រាប់ឆ្នាំ២០២៥ និងឆ្នាំ២០២៦ ការចរចាថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូនជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានធ្វើឡើងជាលក្ខណៈតាមអង្គភាពថវិកា។

### ៣.១.៣៧. ការយកសក្ខីបត្រចំណាយថវិការជ្ជទេយ្យបុរេប្រទានមកទូទាត់ពុំទាន់បានត្រឹមត្រូវ

ប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

ត្រង់ប្រការ១៧បានចែងថា "រាល់ប័ណ្ណចំណាយត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ វិក្កយបត្រ ឬសក្ខីបត្រចំណាយដែលរជ្ជទេយ្យករបុរេប្រទានបានធ្វើការទូទាត់ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក។ អនុញ្ញាតឱ្យរជ្ជទេយ្យករបុរេប្រទានយកវិក្កយបត្រ ឬសក្ខីបត្រចំណាយដែលបានចុះហត្ថលេខារយៈពេល៤៥ថ្ងៃមុនពេលមានប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទានមកធ្វើលិខិតយុត្តិការចំណាយ ដើម្បីបោះផ្សាយអាណត្តិនិយតកម្ម ប៉ុន្តែប័ណ្ណចំណាយត្រូវចុះកាលបរិច្ឆេទនៅក្រោយពេលបំពេញបេឡារជ្ជទេយ្យបុរេប្រទាន។ ក្នុងករណីវិក្កយបត្រ ឬសក្ខីបត្រចំណាយចុះកាលបរិច្ឆេទលើសពី៤៥ថ្ងៃមុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានត្រូវរាយការណ៍ជូនអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិដើម្បីស្នើសុំគោលការណ៍ដោយឡែកពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"។

តាមការចុះធ្វើសវនកម្មនៅនាយកដ្ឋានមូលនិធិតណទានលំនៅឋានរបស់អគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រជ្ជទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានខាងលើបានធ្វើការទូទាត់ចំណាយថវិការជ្ជទេយ្យបុរេប្រទានលើសក្ខីបត្រ ឬវិក្កយបត្រដែលបានកើតឡើងក្រោយរយៈពេល ៤៥ ថ្ងៃដែលមានទឹកប្រាក់ចំនួន ៧ ០៦២ ៥០០រៀល លើមុខចំណាយទិញសម្ភារសម្អាត សម្ភារការិយាល័យ ការជួសជុលសម្ភារបរិក្ខារ ស្បៀងរដ្ឋបាល ការជួសជុលឧបករណ៍បច្ចេកទេស និងជាវកាសែត ដោយមិនបានសុំគោលការណ៍ដាច់ដោយឡែកទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះទេ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គួរណែនាំដល់នាយកដ្ឋានខាងលើឱ្យអនុវត្តឱ្យបានត្រឹមត្រូវ និងប្រសិទ្ធភាពស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបតាមនូវការលើកឡើងខាងលើ នាយកដ្ឋានមូលនិធិតណទានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបំភ្លឺថា ចំពោះករណីនេះ គឺជាកំហុសបច្ចេកទេសក្នុងការរៀបចំឯកសារដែលបានទូទាត់ ប៉ុន្តែមុខសញ្ញាចំណាយខ្លះក៏មានលក្ខណៈបន្ទាន់ និងជាចាំបាច់។

### ៣.១.៣៨. កង្វះខាតក្នុងការរៀបចំរបាយការណ៍ចំណាយថវិការបស់អង្គភាពថវិកា

ប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា ត្រង់ផ្នែកទី១ ប្រការ១១ កថាខណ្ឌទី២ ចំណុចលេខ៣ បានបញ្ជាក់ថា "អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញមានភារកិច្ច និងការទទួលខុសត្រូវក្នុងការពិនិត្យ និងតាមដានការអនុវត្តថវិកា រួមមាន៖ ពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួនរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា (របាយការណ៍ចំណូល ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្ម) ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកា ក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន

និងផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន តាមកាលបរិច្ឆេទដែលបានកំណត់"។

តាមការចុះធ្វើសវនកម្មនៅអង្គភាពថវិកានាយកដ្ឋានផ្លូវលំជនបទ និងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមដើមខែសីហា ឆ្នាំ២០២៥ អង្គភាពថវិកាទាំងពីរខាងលើនៅមិនទាន់បានរៀបចំរបាយការណ៍ចំណាយថវិកាឆ្នាំ២០២៤របស់ខ្លួននៅឡើយ។

ក្រសួងអភិវឌ្ឍន៍ជនបទ គួរណែនាំដល់អង្គភាពថវិកាទាំងពីរខាងលើរៀបចំរបាយការណ៍ចំណាយថវិការបស់ខ្លួនឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ចំពោះករណីនេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងណែនាំអង្គភាពទាំងពីរខាងលើឱ្យអនុវត្តស្របតាមខ្លឹមសារនៃប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសូមធ្វើការបំភ្លឺបន្ថែមថា នាយកដ្ឋានផ្លូវលំជនបទ និងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទមិនទាន់បានបំពេញបន្ថែមទម្រង់របាយការណ៍ថ្មីសម្រាប់តាមដានការទូទាត់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស។ ដើម្បីបំពេញការអនុវត្តថវិកាឱ្យមានប្រសិទ្ធភាព នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុនឹងណែនាំអំពីការរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាសដល់នាយកដ្ឋាននានានៅក្នុងឆ្នាំអនុវត្ត២០២៥។

### ៣.១.៣៩. ការធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព និងគុណភាពការងារសំណង់ និងលិខិតបញ្ចប់ការងាររបស់វិស្វករ ឬអ្នកបច្ចេកទេស

ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ប្រការ ៨ បានចែងថា "ការអនុវត្តកិច្ចសន្យាលទ្ធកម្មសំណង់ ស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកាត្រូវមានវិស្វករ ឬអ្នកបច្ចេកទេស១ (មួយ) រូបយ៉ាងតិច។ វិស្វករ ឬអ្នកបច្ចេកទេសមានភារកិច្ចសំខាន់ៗជាអាទិ៍៖

- ត្រួតពិនិត្យលក្ខណៈបច្ចេកទេស គំនូសប្លង់ និងប្រតិទិនការងារឱ្យបានត្រឹមត្រូវ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃបច្ចេកទេសអំពីវឌ្ឍនភាព និងគុណភាពការងារ
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងគុណភាពការងារសំណង់ជូនគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម
- ផ្តល់ការណែនាំបច្ចេកទេសសំណង់ដល់អ្នកទទួលការឱ្យអនុវត្តការងារឱ្យបានត្រឹមត្រូវ
- ចុះហត្ថលេខាបញ្ជាក់លើលិខិតបញ្ចប់ការងារ។

តាមការពិនិត្យលើសុំណុំឯកសារកិច្ចលទ្ធកម្មស្តីពីការជួសជុលអគាររបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៤ គណៈកម្មាធិការលទ្ធកម្មនៃក្រសួង បានចុះកិច្ចសន្យាស្តីពីការងារជួសជុលដំបូល ពិដាន និងបន្ទប់ទឹកក្នុងវិទ្យាស្ថានស្តង់ដារកម្ពុជា មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និងមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ប៉ុន្តែគណៈកម្មាធិការលទ្ធកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានធ្វើការប្រគល់ទទួលការងារដោយពុំមានរបាយការណ៍ស្តីពីវឌ្ឍនភាព និងគុណភាពការងារសំណង់ និងលិខិតបញ្ចប់ការងារដែលចុះហត្ថលេខាបញ្ជាក់ពីវិស្វករ ឬអ្នកបច្ចេកទេស។

អាស្រ័យហេតុនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍គួរណែនាំគណៈកម្មធិការលទ្ធកម្មឱ្យស្របតាមប្រកាសខាងលើ។

ចំណុចនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុត្តន៍បានឯកភាពលើខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ ហើយនឹងព្យាយាមកែលម្អនូវចំណុចខ្វះខាតដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

## ៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. ការប្រមូលពន្ធមធ្យោបាយដឹកជញ្ជូន

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ទៅតាមប្រភេទនីមួយៗ ដោយមិនគិតថាជាកម្មសិទ្ធិរបស់រដ្ឋ ឬឯកជនឡើយ ហើយពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តលើមធ្យោបាយដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជារៀងរាល់ឆ្នាំ អគ្គនាយកដ្ឋានពន្ធដារតែងតែចេញសេចក្តីជូនដំណឹងស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន ដោយធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ឃុំ-សង្កាត់ បិទផ្សាយតាមទីតាំងសាធារណៈ និងចេញលិខិតរំលឹកជូនផ្ទាល់ទៅម្ចាស់យានយន្ត។ តាមរយៈការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានពន្ធដារសម្រាប់ការិយបរិច្ឆេទ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនសរុបចំនួន ៣៩៨ ៤០៧ ២៣៨ ៤៨៧រៀល ស្មើនឹង ៩៥% នៃផែនការឆ្នាំ។ តាមការធ្វើតេស្តលើអង្គភាពប្រមូលពន្ធមួយចំនួន និងការពិនិត្យលើវឌ្ឍនភាពស្តីពីការបោះពុម្ព ព្រមទាំងការចែកលិខិតជូនដំណឹងដល់លំនៅឋានអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ មានយានយន្តមួយចំនួនតូច ដែលម្ចាស់ពុំទាន់បានមកបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួននៅឡើយ។ ដោយសារម្ចាស់យានយន្តមួយចំនួនតូចពុំទាន់បានមកបំពេញកាតព្វកិច្ចសារពើពន្ធ អាចនាំឱ្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទពុំទាន់បានពេញលេញ។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ គួរសហការគ្នាជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ ក្នុងការពង្រឹងបន្ថែមទៀតលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនឱ្យបានពេញលេញ។

ឆ្លើយតបនឹងចំណុចខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការណែនាំ និងជំរុញអាជ្ញាធរមូលដ្ឋាននៃរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យធ្វើការពង្រឹងយន្តការនៃការប្រមូលចំណូលសារពើពន្ធ តាមរយៈសារាចរណែនាំស្ដីពីការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២៤ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានខ្លឹមសារជាអាទិ៍ "រដ្ឋបាលរាជធានី ខេត្តត្រូវសហការជាមួយមន្ត្រីពន្ធដារ ដើម្បីជំរុញ និងតាមដានការអនុវត្តគោលនយោបាយ និងនីតិវិធីប្រមូលចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតឱ្យប្រមូលសម្រាប់ជាគុណប្រយោជន៍នៃថវិការដ្ឋបាលរាជធានី ខេត្ត ឱ្យបានត្រឹមត្រូវតាមបទបញ្ញត្តិជាធរមាន និងត្រូវរួមចំណែកដាក់ចេញនូវវិធានការជាក់ស្ដែងសម្រាប់ប្រភេទពន្ធនីមួយៗ ដើម្បីតម្រូវឱ្យអ្នកជាប់ពន្ធបង់ពន្ធបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា។ ទន្ទឹមនឹងនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់មន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យស្ថិតិ និងកម្រងព័ត៌មានដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានតាមដានត្រួតពិនិត្យ និងជួយដល់មន្ត្រីពន្ធដារ ក្នុងការប្រមូលចំណូល និងធ្វើជាឯកសារបង្អែកក្នុងការរៀបចំគម្រោងចំណូលសារពើពន្ធប្រចាំឆ្នាំនីមួយៗ"។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានផ្ដល់ការណែនាំដល់អាជ្ញាធរមូលដ្ឋានរដ្ឋបាលរាជធានី ខេត្តសាមី ត្រូវចូលរួមចំណែកពង្រឹងយន្តការប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន ដើម្បីសម្រេចឱ្យបានទៅតាមគម្រោងផែនការប្រចាំឆ្នាំ ស្របតាមខ្លឹមសារនៃអនុសាសន៍របស់ អាជ្ញាធរសវនកម្មជាតិ។ ជាមួយគ្នានេះ នៅឆ្នាំ២០២៦ រដ្ឋបាលខេត្តចំនួន១២ នឹងបញ្ចូលកិច្ចការនេះទៅក្នុងផែនការសកម្មភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាល ខេត្ត ដើម្បីពង្រឹងបន្ថែមទៀតលើយន្តការប្រមូលចំណូលសារពើពន្ធ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំណូមពរដល់អាជ្ញាធរ សវនកម្មជាតិ ណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការផ្ដល់ទិន្នន័យឱ្យបានពេញលេញ ដើម្បីអគ្គនាយកដ្ឋានពន្ធដារអាចធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបានជោគជ័យ។

**៣.២.២. ការដាក់ផែនការសម្រាប់ការប្រមូលចំណូលពន្ធអចលនទ្រព្យ**

ប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់ជំពូកទី៥ នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ ប្រការ ២៨ ត្រេទី១៦ បានចែងថា "នាយកដ្ឋាននេះ មានភារកិច្ចដូចតទៅ៖...រៀបចំវិធីសាស្ត្រ និងកសាងផែនការសម្រាប់ព្យាករចំណូលសារពើពន្ធ"។

តាមរយៈការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានពន្ធដារសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធអចលនទ្រព្យសរុបចំនួន ១៥៣ ៦៩៥ ៩៩៦ ៥៣៧រៀល ស្មើនឹង

៨៤,១៩%នៃផែនការប្រចាំឆ្នាំ។ តាមការពិនិត្យរបាយការណ៍ស្តីពីការបូកសរុបលទ្ធផលការគ្រប់គ្រង និងការប្រមូលចំណូលពន្ធប្រចាំឆ្នាំ និងឯកសារពាក់ព័ន្ធរបស់សាខាពន្ធដារខណ្ឌ៩ និងខេត្ត១៤ ឃើញថា អគ្គនាយកដ្ឋានពន្ធដារបានដាក់ផែនការលើការប្រមូលពន្ធអចលនទ្រព្យដល់សាខាពន្ធដារខណ្ឌ និងខេត្តមួយចំនួនតូច មានកម្រិតខ្ពស់ បើធៀបនឹងសក្តានុពលនៃវិស័យអចលនទ្រព្យដែលខណ្ឌ និងខេត្តអាចមានលទ្ធភាពប្រមូលពន្ធអចលនទ្រព្យបាន។ ដោយសារការដាក់ផែនការលើការប្រមូលពន្ធអចលនទ្រព្យដល់សាខាពន្ធដារមួយចំនួនតូច មានកម្រិតខ្ពស់ អាចនាំឱ្យការប្រមូលពន្ធអចលនទ្រព្យពុំអាចគ្រប់តាមផែនការ។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគួរណែនាំដល់អគ្គនាយកដ្ឋានពន្ធដារពិនិត្យមើលបន្ថែមទៀត ក្នុងការដាក់ផែនការប្រមូលពន្ធអចលនទ្រព្យដល់សាខាពន្ធដារខណ្ឌ និងខេត្តមួយចំនួនតូច ដោយផ្អែកលើមូលដ្ឋានអចលនទ្រព្យដែលមានជាក់ស្តែង។

ឆ្លើយតបនឹងចំណុចខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍ និងធ្វើការពិនិត្យ និងកែសម្រួលការដាក់ផែនការលើការប្រមូលចំណូលពន្ធលើអចលនទ្រព្យឡើងវិញសម្រាប់ឆ្នាំបន្តបន្ទាប់។

### ៣.២.៣. ភាពយឺតយ៉ាវក្នុងការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ

ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រង់ប្រការ១១ បានបញ្ជាក់ថា "ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរបន្ទាប់ពីអ្នកដេញថ្លៃឈ្នះបានចុះកិច្ចសន្យា និងកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកដេញថ្លៃវិញ"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃខេត្តចំនួន៥ បានចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃទៅរតនាគារ ឬធនាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកដេញថ្លៃវិញ ហួសរយៈពេលកំណត់៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដូចមានខាងក្រោម៖

១. ខេត្តរតនគិរីមានចំនួន៣៥ កិច្ចសន្យា
២. ខេត្តក្រចេះមានចំនួន៣ កិច្ចសន្យា
៣. ខេត្តមណ្ឌលគិរីមានចំនួន៣ កិច្ចសន្យា
៤. ខេត្តស្វាយរៀងមានចំនួន ១ កិច្ចសន្យា
៥. ខេត្តសៀមរាបចំនួន២ កិច្ចសន្យា។

អង្គភាពលទ្ធកម្មនៃរដ្ឋបាលខេត្តខាងលើ គួរចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃឱ្យបានទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ បានឯកភាព និងទទួលយកអនុសាសន៍ ព្រមទាំងសន្យាថា នឹងចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃឱ្យបានទាន់ពេលវេលា។

### ៣.២.៤. ការរក្សាទុកសំណុំឯកសារដែលអង្គភាពរដ្ឋ ទទួលការមិនបានពេញលេញ

សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាវិនិយោគសាធារណៈ និងជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានអនុវត្តដោយអង្គភាពរដ្ឋ ត្រង់ចំណុច៥ ស្តីពីការទូទាត់ប្រាក់បុរេប្រទាន បានបញ្ជាក់ថា ឯកសារពាក់ព័ន្ធទាំងអស់នៃការអនុវត្តគម្រោងវិនិយោគសាធារណៈ គម្រោងជួសជុលនិងកម្មវិធីថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន ត្រូវរក្សាទុកនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអាណាប័ក និងនៅអង្គភាពរបស់ខ្លួនផ្ទាល់។ ឯកសារពាក់ព័ន្ធ រួមមាន៖ លិខិតស្នើសុំបើកផ្តល់ និងទូទាត់ប្រាក់បុរេប្រទាន កិច្ចសន្យាអនុវត្តគម្រោង របាយការណ៍ចំណាយប្រាក់បុរេប្រទាន (របាយការណ៍ហិរញ្ញវត្ថុ) របាយការណ៍វឌ្ឍនភាពការងារ ដែលបានពិនិត្យនិងបញ្ជាក់ពីអ្នកត្រួតពិនិត្យបច្ចេកទេសនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអាណាប័ក ឬពីគណៈកម្មការអន្តរក្រសួងប្រគល់ទទួល និងវាយតម្លៃការងារ សលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ សលាកប័ត្រគណនេយ្យភាពហិរញ្ញវត្ថុ និងលិខិតយុត្តិការពាក់ព័ន្ធផ្សេងៗ។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តចំនួន៨ ពុំបានរក្សារទុករបាយការណ៍ចំណាយប្រាក់បុរេប្រទាន (របាយការណ៍ហិរញ្ញវត្ថុ) និងសក្ខីបត្រចំណាយរបស់អ្នកទទួលការជាអង្គភាពរដ្ឋ ដូចមានខាងក្រោម៖

១. រដ្ឋបាលខេត្តត្បូងឃ្មុំមាន ចំនួន១កិច្ចសន្យា

២. រដ្ឋបាលខេត្តកំពង់ធំមាន ចំនួន១កិច្ចសន្យា

៣. រដ្ឋបាលខេត្តមណ្ឌលគិរីមាន ចំនួន២កិច្ចសន្យា

៤. រដ្ឋបាលខេត្តកំពង់ស្ពឺមាន ចំនួន៤កិច្ចសន្យា

៥. រដ្ឋបាលខេត្តព្រះសីហនុ មានចំនួន៤កិច្ចសន្យា

៦. រដ្ឋបាលខេត្តកោះកុងមាន ចំនួន៣កិច្ចសន្យា

៧. រដ្ឋបាលខេត្តកែបមាន ចំនួន៣កិច្ចសន្យា

៨. រដ្ឋបាលខេត្តកំពង់ឆ្នាំង មានចំនួន១កិច្ចសន្យា។

ដោយសារការរក្សាទុកសំណុំឯកសារពាក់ព័ន្ធនៃការអនុវត្តគម្រោងនៅរដ្ឋបាលខេត្ត ពុំបានពេញលេញ ធ្វើឱ្យប៉ះពាល់ដល់កម្មវត្ថុនៃការត្រួតពិនិត្យរបស់ស្ថាប័នមានសមត្ថកិច្ច។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តខាងលើ គួរណែនាំទីចាត់ការហិរញ្ញវត្ថុ ឱ្យប្រមូលសំណុំឯកសារពាក់ព័ន្ធនៃការអនុវត្តគម្រោងពីអ្នកទទួលការជាអង្គភាពរដ្ឋឱ្យបានគ្រប់ចំនួន។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្តខាងលើបានឯកភាព និងទទួលយកអនុសាសន៍ ព្រមទាំងសន្យាថា នឹងជំរុញឱ្យអ្នកទទួលការផ្តល់សំណុំឯកសារពាក់ព័ន្ធនៃការអនុវត្តគម្រោងឱ្យបានពេញលេញ។

### ៣.២.៥. កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង

ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ប្រការ៧ ស្តីពីកាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ និងអ្នកទទួលការមានភារកិច្ចអនុវត្តកិច្ចសន្យាលទ្ធកម្មសំខាន់ៗជាអាទិ៍៖ "រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ ទទួលចប់ជាស្ថាពរ ជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា"។ និងត្រង់ប្រការ៨ បានបញ្ជាក់ថា "ការអនុវត្តកិច្ចសន្យាលទ្ធកម្មសំណង់ ស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកាត្រូវមានវិស្វករ ឬអ្នកបច្ចេកទេស ០១ (មួយ)រូប យ៉ាងតិច។ វិស្វករ ឬអ្នកបច្ចេកទេសមានភារកិច្ចរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងគុណភាពការងារសំណង់ជូនគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តចំនួន៥ បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយពុំបានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង ដូចមានខាងក្រោម៖

១. ខេត្តស្ទឹងត្រែងមានចំនួន៤គម្រោង

២. ខេត្តកំពតមានចំនួន ១១គម្រោង

៣. ខេត្តតាកែវមានចំនួន៣គម្រោង

៤. ខេត្តកោះកុងមានចំនួន៨គម្រោង

៥. ខេត្តកណ្តាលមានចំនួន៧គម្រោង

កត្តានេះនាំឱ្យគណៈកម្មាធិការលទ្ធកម្ម និងក្រុមលទ្ធកម្មពុំមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការវាយតម្លៃប្រគល់ ទទួល។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធគួររៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ ទទួលចប់ជាស្ថាពរឱ្យបានត្រឹមត្រូវ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធបានឯកភាព និងទទួលយកអនុសាសន៍ ព្រមទាំងសន្យាថា នឹងអនុវត្តការងារឱ្យបានពេញលេញនៅពេលខាងមុខ។

### ៣.២.៦. ការទុករយៈពេលសម្រាប់ប្តឹងតវ៉ាលទ្ធកម្ម

អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ត្រង់មាត្រា ៩ បានបញ្ជាក់ថា "អ្នកដេញថ្លៃ ត្រូវបណ្តឹងតវ៉ាទៅសាមីប្រធានស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ក្នុងរយៈពេលនៃដំណាក់កាលលទ្ធកម្មនីមួយៗ ឬយ៉ាងយូរបំផុតត្រឹម ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីដំណាក់កាលនីមួយៗ នៃកិច្ចលទ្ធកម្មសាធារណៈត្រូវបានបញ្ចប់ លើកលែងតែការប្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលនៃការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ដែលអនុញ្ញាតឱ្យអ្នកដេញថ្លៃប្តឹងតវ៉ាក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានខេត្តចំនួន៤ បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយបានទុករយៈពេលប្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលនៃការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ មានរយៈពេលតិចជាង១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ដូចមានខាង ក្រោម៖

១. ខេត្តតាកែវមានចំនួន២ កិច្ចសន្យា

២. ខេត្តកណ្តាលមានចំនួន១កិច្ចសន្យា

៣. ខេត្តពោធិសាត់មានចំនួន១កិច្ចសន្យា

៤. ខេត្តសៀមរាបមានចំនួន៣កិច្ចសន្យា

កត្តានេះអាចនាំឱ្យមានហានិភ័យនៃការប្តឹងតវ៉ាកើតឡើងជាយថាហេតុ។

អាស្រ័យហេតុនេះ គណៈកម្មាធិការលទ្ធកម្ម និងក្រុមលទ្ធកម្មគួរទុករយៈពេលនៃការប្តឹងតវ៉ាឱ្យគ្រប់ចំនួនថ្ងៃបន្ទាប់ពីចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ បានឯកភាព និងទទួលយកអនុសាសន៍ ដោយសន្យាថានឹងទុករយៈពេលប្តឹងតវ៉ាឱ្យបានត្រឹមត្រូវ។

### ៣.២.៧. ភាពមិនទាន់ពេញលេញនៃការបង្កើតរបាយការណ៍ចេញពីប្រព័ន្ធ FMIS

សារាចរណែនាំលេខ ០១៤ ស.រ.អហក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៤ នៅត្រង់ចំណុចទី១០ "...រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលសាមីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១" និង "ខ១", "ក២" និង "ខ២", *ក៣" និង "ខ៣" ។

សេចក្តីព្រាងលើកទី៣នៃគោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានគូសបញ្ជាក់ថា ប្រព័ន្ធ FMIS ត្រូវបានរៀបចំក្នុងគោលបំណងជំនួសជាជំហានៗនូវការអនុវត្តដោយដៃក្នុងការរៀបចំគម្រោងថវិកាការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យ និងការធ្វើរបាយការណ៍។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តក្រចេះ និងរដ្ឋបាលខេត្តកំពង់ធំ បានរៀបចំរបាយការណ៍ចំណូលថវិកា និងចំណាយថវិការបស់រដ្ឋបាល ខេត្ត ក្នុងប្រពន្ធ FMIS ប៉ុន្តែរបាយការណ៍នេះ មានទម្រង់ពុំអាចទាញយកមកប្រើប្រាស់ជាផ្លូវការបាន។

ដោយសាររបាយការណ៍ដែលទាញចេញពីប្រព័ន្ធ FMIS សម្រាប់ប្រើប្រាស់មានទម្រង់មិនពេញលេញ នាំឱ្យអ្នករៀបចំបាយការណ៍ត្រូវការចំណាយពេលវេលាសម្រាប់កែសម្រួលទម្រង់របាយការណ៍បន្ថែម។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តខាងលើ គួរសហការជាមួយក្រុមការងារគ្រប់គ្រងគម្រោង FMIS ដើម្បីធ្វើការសិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធបង្កើតបាននូវរបាយការណ៍អាចយកមកប្រើប្រាស់ជាផ្លូវការបាន។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្តខាងលើបានទទួលយកអនុសាសន៍ ដោយសន្យាថា នឹងធ្វើការសហការជាមួយក្រុមការងារគ្រប់គ្រងគម្រោង FMIS ដើម្បីធ្វើការសិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធដែលនឹងអាចជួយបង្កើតបាននូវរបាយការណ៍ត្រឹមត្រូវ និងប្រើប្រាស់បាន។

**៣.២.៨. បំណុលភាស៊ីត្រូវទារ**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែកទី២ ស្តីពីយន្តការស្ថាប័នថ្នាក់ក្រោមជាតិ ត្រង់មាត្រា១០-១២ បានតម្រូវឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត បំពេញមុខងារធ្វើជាសេនាធិការជូនរដ្ឋបាលថ្នាក់ក្រោមជាតិ លើការអនុវត្តប្រមូលចំណូលមិនមែនសារពើពន្ធ ព្រមទាំងជំរុញការគៀរគរ និងការកត់ត្រានូវគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញនៃរាជធានី ខេត្ត។ ក្នុងករណីចាំបាច់ រដ្ឋបាលរាជធានី ខេត្ត អាចបង្កើតគណៈកម្មការ ឬក្រុមការងារជាសេនាធិការ ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុលចំណូលមិនមែនសារពើពន្ធ។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តចំនួន៦ នៅមានបំណុលភាស៊ីគ្រប់ប្រភេទត្រូវទារ មានដូចខាងក្រោម៖

១. ខេត្តក្រចេះមានចំនួន ៥៦ ៥៤២ ៤០០ រៀល

២. ខេត្តកែបមានចំនួន ៣៥ ២៥៩ ៩០០ រៀល

៣. ខេត្តកោះកុងមានចំនួន ៣៤ ៧០០ ៥១១ រៀល

៤. ខេត្តកណ្ដាលមានចំនួន ៣៣៩ ៩៦២ ០០០ រៀល

៥. ខេត្តកំពង់ឆ្នាំងមានចំនួន ៥៧ ៥០០ ០០០ រៀល

៦. ខេត្តបន្ទាយមានជ័យមាន ចំនួន ១ ០២១ ៩៨០ ០០០ រៀល

កត្តានេះអាចនាំឱ្យបាត់បង់ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត គួរណែនាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តជំរុញនិងចាត់វិធានការតឹងទារបំណុលភាស៊ីឱ្យបានទាន់ពេលវេលា និងគ្រប់ចំនួន។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្តបានឯកភាពនិងទទួលយកអនុសាសន៍ ដោយសន្យាថា នឹងណែនាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យធ្វើការសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីអនុវត្តយន្តការតឹងទារ និងប្រមូលបំណុលភាស៊ីបង់ចូលថវិការរដ្ឋឱ្យបានគ្រប់ចំនួននៅពេលខាងមុខ។

### ៣.២.៩. ភាពយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំគោល (ឆ្នាំ២០២៤)

អនុក្រឹត្យលេខ ៦៦ អនក.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់មាត្រា១៨ បានបញ្ជាក់ថា "អាជ្ញាធរកាន់កាប់ត្រូវរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដូចខាងក្រោម ៖

- សៀវភៅបញ្ជីសារពើភណ្ឌឆ្នាំគោល៖ កត់ត្រាលម្អិតនូវទ្រព្យសម្បត្តិរដ្ឋទាំងអស់ជាចលនទ្រព្យ និងអចលនទ្រព្យស្ថិតក្រោមការកាន់កាប់របស់ខ្លួន ដែលត្រូវធ្វើឡើងក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្ដង ហៅថា "ឆ្នាំគោល"។ ទ្រព្យសម្បត្តិនីមួយៗដែលកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយដោយអនុលោមតាមគំរូជាធរមាន។
- តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ៖ កត់ត្រានូវការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំក្នុងចន្លោះរយៈពេល ៥ (ប្រាំ) ឆ្នាំនៃឆ្នាំគោល ដោយអនុលោមតាមគំរូជាធរមាន"។

មាត្រា២៤ នៃអនុក្រឹត្យខាងលើ បានបញ្ជាក់ថា "អាជ្ញាធរកាន់កាប់ត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដូចមានកំណត់ក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ នូវគ្រប់ទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន និងបញ្ជូនមកអាជ្ញាធរគ្រប់គ្រងចំនួន២(ពីរ)ច្បាប់ យ៉ាងយូរត្រឹមត្រីមាសទី១ (មួយ)នៃឆ្នាំបន្ទាប់តាមនីតិវិធី"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ខេត្តចំនួន៧ ពុំទាន់បានរៀបចំបញ្ជីសារពើភណ្ឌឆ្នាំគោល (២០២៤) បញ្ចប់ត្រឹមបំណាច់ត្រីមាសទី១ នៅឡើយ ដូចមានខាងក្រោម៖

១. ខេត្តមណ្ឌលគិរីមានចំនួន១អង្គភាព

២. ខេត្តព្រះសីហនុមានចំនួន១អង្គភាព

៣. ខេត្តកោះកុងមានចំនួន២អង្គភាព

៤. ខេត្តកែបមានចំនួន១៣ អង្គភាព

៥. ខេត្តកំពង់ឆ្នាំងមានចំនួន១៣អង្គភាព

៦. ខេត្តព្រៃវែងមានចំនួន១៥ អង្គភាព

៧. ខេត្តកណ្ដាលមានចំនួន២៤អង្គភាព

កត្តាអាចធ្វើឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមិនច្បាស់លាស់ និងអាចបាត់បង់ជាយថាហេតុ។

អាស្រ័យហេតុនេះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ គួររួសរាន់រៀបចំបញ្ជីសារពើភណ្ឌឆ្នាំគោល (ឆ្នាំ២០២៤) ឱ្យបានទាន់ពេល។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្ត និងបណ្ដាមន្ទីរពាក់ព័ន្ធបានឆ្លើយបំភ្លឺថា ករណីយឺតយ៉ាវនេះដោយសារការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ SARMIS V.2 របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលខេត្តខ្លះទៀតនឹងណែនាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យរួសរាន់អញ្ជើញក្រុមការងាររបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមកពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ឱ្យបានទាន់ពេលវេលា។

### ៣.២.១០. ការពុំបានកត់ត្រាទ្រព្យសម្បត្តិចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជាស្ដីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់មាត្រា១៨ បានបញ្ជាក់ថា "អាជ្ញាធរកាន់កាប់ត្រូវរៀបចំតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ដោយត្រូវកត់ត្រានូវការកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំក្នុងចន្លោះរយៈពេល០៥ (ប្រាំ) ឆ្នាំ នៃឆ្នាំគោល ដោយអនុលោមតាមគំរូជាធរមាន។ និងត្រង់មាត្រា២៤ បានបញ្ជាក់បន្ថែមថា អាជ្ញាធរកាន់កាប់ត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដូចមានកំណត់ក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ នូវគ្រប់ទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន និងបញ្ជូនមកអាជ្ញាធរគ្រប់គ្រងចំនួន២ (ពីរ) ច្បាប់ យ៉ាងយូរត្រឹមត្រីមាសទី១ (មួយ) នៃឆ្នាំបន្ទាប់"។

សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ត្រង់ចំណុច ៥ ស្ដីពីវិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានបញ្ជាក់ថា "អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីគ្រប់ចំនួននូវទ្រព្យសម្បត្តិចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តចំនួន៩ និងមន្ទីរមួយចំនួនពុំទាន់បានកត់ត្រាទ្រព្យសម្បត្តិរដ្ឋមួយចំនួនបញ្ចូលទៅក្នុងបញ្ជីទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំនៅឡើយ ដូចមានខាងក្រោម៖

១. ខេត្តមណ្ឌលគិរីមានដី ចំនួន២ទីតាំង

២. ខេត្តក្រចេះមានដីចំនួន១ទីតាំង

៣. ខេត្តត្បូងឃ្មុំមានដីចំនួន១ទីតាំង

៤. ខេត្តកំពងធំមានដីចំនួន១ទីតាំង

៥. ខេត្តកែបមានដីចំនួន ៤ទីតាំង, ដីកោះចំនួន ៥ទីតាំង និងដីឆ្នេរចំនួន៣ទីតាំង

៦. ខេត្តកំពង់ឆ្នាំងមានដី ចំនួន៥០១ទីតាំង

៧. ខេត្តព្រៃវែងមានដីចំនួន៩ទីតាំង

កត្តានេះនាំឱ្យប៉ះពាល់ដល់គោលការណ៍នៃការគ្រប់គ្រងទ្រព្យ សម្បត្តិរដ្ឋ និងនាំឱ្យទ្រព្យសម្បត្តិរដ្ឋអាចបាត់បង់ជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធគួរអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃអនុក្រឹត្យ និងសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធបានឯកភាព និងសន្យាថាជំរុញការគ្រប់គ្រងអនុវត្តការងារនេះឱ្យបានល្អ។

### ៣.២.១១. ភាពយឺតយ៉ាវក្នុងការរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លិខិតលេខ ៣៨៤៤ សហវ.ទរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរំលឹកការធ្វើប្លង់កម្មសិទ្ធិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បណ្ដាក្រសួង ស្ថាប័ន និងខេត្ត-ក្រុង ដោយធ្វើការក្រើនរំលឹកដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ព្រមទាំងបណ្ដាមន្ទីរ និងសាលាខេត្ត ក្រុងទាំងអស់ត្រូវរៀបចំធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ដែលខ្លួនកំពុងកាន់កាប់ឱ្យបានឆាប់រហ័ស ដោយរួមសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុងទាំងអស់។ និងសារាចរណែនាំលេខ ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុច៥ បានចែងថា "អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ"។

តាមរយៈការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា ខេត្តចំនួន២១ មានដីធ្លីមួយចំនួនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត និងមន្ទីរមួយចំនួនពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅឡើយ ដូចខាងក្រោម៖

១. ខេត្តមណ្ឌលគិរីមានចំនួន ១២៨ទីតាំង
២. ខេត្តស្ទឹងត្រែងមានចំនួន ៤២ទីតាំង
៣. ខេត្តក្រចេះមានចំនួន ៣១០ទីតាំង
៤. ខេត្តត្បូងឃ្មុំមានចំនួន ១៦៩ទីតាំង
៥. ខេត្តកំពង់ធំមានចំនួន ៤៣៣ទីតាំង
៦. ខេត្តរតនគិរីមានចំនួន ១៩ទីតាំង
៧. ខេត្តកំពង់ស្ពឺមានចំនួន ២៩០ទីតាំង
៨. ខេត្តកំពតមានចំនួន ១៦៥ទីតាំង
៩. ខេត្តតាកែវមានចំនួន ៣៤៦ទីតាំង
១០. ខេត្តព្រះសីហនុមានចំនួន ៦៨ទីតាំង
១១. ខេត្តកោះកុងមានចំនួន ១៥៤ទីតាំង
១២. ខេត្តកែបមានចំនួន ២៤ទីតាំង
១៣. ខេត្តកណ្ដាលមានចំនួន ២៥២ទីតាំង
១៤. ខេត្តព្រៃវែងមានចំនួន ១១៦៧ទីតាំង
១៥. ខេត្តស្វាយរៀងមានចំនួន ១៣១ទីតាំង
១៦. ខេត្តកំពង់ឆ្នាំងមានចំនួន ១៤១ទីតាំង
១៧. ខេត្តពោធិសាត់មានចំនួន ២០៦ទីតាំង
១៨. ខេត្តបាត់ដំបងមានចំនួន ១៣ទីតាំង
១៩. ខេត្តបន្ទាយមានជ័យមានចំនួន ៣២៩ទីតាំង
២០. ខេត្តសៀមរាបមានចំនួន ៧ទីតាំង
២១. ខេត្តប៉ៃលិនមានចំនួន ១២ទីតាំង

កត្តានេះអាចឱ្យមានការរំលោភបំពាន និងការបាត់បង់ទ្រព្យសម្បត្តិរដ្ឋជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តខាងលើ និងមន្ទីរពាក់ព័ន្ធ គួររួសរាន់ធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យឱ្យបានឆាប់រហ័ស។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ រដ្ឋបាលខេត្តមួយចំនួនបានឯកភាព និងសន្យាជំរុញការងារនេះឱ្យបានល្អប្រសើរ ហើយរដ្ឋបាលខេត្តមួយចំនួនទៀតបំភ្លឺថា ដីមួយចំនួនបាននឹងកំពុងដំណើរការចុះបញ្ជី ហើយដីមួយចំនួនទៀត ពុំអាចដំណើរការចុះបញ្ជីបានទេដោយសារជាប់ពាក់ព័ន្ធនឹងទំនាស់ និងដីខ្លះទៀតមានការចុះបញ្ជីទ្រព្យសម្បត្តិស្ទួនគ្នា ដោយរង់ចាំការបង្កើតគណៈកម្មការចុះពិនិត្យ និងដោះស្រាយ។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

### ៤.១. ការចេញលិខិតរំលឹកប្រកាសពន្ធ

អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំបញ្ជីឈ្មោះអ្នកជាប់ពន្ធដែលដាក់លិខិតប្រកាសយឺតយ៉ាវ ឬដាក់លិខិតប្រកាសដោយពុំបង់ប្រាក់ពន្ធ និងមិនដាក់លិខិតប្រកាស ដើម្បីអនុវត្តតាមមុខងារ។

តាមការពិនិត្យលើប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំប្រព័ន្ធសម្រាប់គ្រប់គ្រងអ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធសម្រាប់គ្រប់អង្គភាពពន្ធដារ ដើម្បីតាមដាន និងអនុវត្ត។ តាមការធ្វើតេស្តលើសហគ្រាសនៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានសហគ្រាសមួយចំនួនតូច ដែលអង្គភាពពន្ធដារពុំទាន់បានធ្វើលិខិតរំលឹកដល់សហគ្រាសទាំងនោះនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា ចំពោះភាពយឺតយ៉ាវក្នុងការចេញលិខិតរំលឹកប្រកាសពន្ធនេះ គឺជាបញ្ហាដែលតែងតែកើតមានជាធម្មតា និងអ្នកជាប់ពន្ធភាគច្រើនដដែលៗ នៅតែមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធ ដែលនេះជាភាពខ្វះចន្លោះតិចតួចក្នុងការអនុវត្តការងារ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តពង្រឹងកិច្ចការនេះនៅគ្រប់អង្គភាពពន្ធដារពាក់ព័ន្ធបន្ថែមទៀតតាមរយៈការដាក់ចេញនូវវិធានការដាក់លាក់ដែលមានកំណត់នៅក្នុងមុខងាររបស់អង្គភាពនីមួយៗសម្រាប់ឆ្នាំបន្ទាប់។

### ៤.២. វឌ្ឍនភាពនៃការជំរុញការចុះបញ្ជីសហគ្រាសតាមលទ្ធផលអង្កេត

បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ (ដប់ប្រាំ) ថ្ងៃក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័នឬអង្គការនានា។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខណ្ឌចំនួន៩ បានខិតខំចេញលិខិតអញ្ជើញចុះបញ្ជីសហគ្រាស និងចាត់វិធានការនានា។ ប៉ុន្តែសហគ្រាសមួយចំនួនតូចពុំបានមកចុះបញ្ជីពន្ធនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.៣. ការផ្ទេរក្រុមហ៊ុន សហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម

ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម និងពាណិជ្ជកម្ម។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបែងចែកជាបីប្រភេទ៖ អ្នកជាប់ពន្ធតូច គឺជាសហគ្រាស ឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១ ០០០លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬមានផលរបរប្រចាំឆ្នាំចាប់ពី

២៥០ លានរៀល ដល់ ១ ៦០០លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត... អ្នកជាប់ពន្ធមធ្យម គឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ១ ០០០លានរៀល ដល់ ៤ ០០០លានរៀល..."។ នៅក្នុងឆ្នាំ ២០២៤ សាខាពន្ធដារខេត្ត ខណ្ឌបានព្យាយាមពិនិត្យមើលផលរបរសហគ្រាសដែលត្រូវផ្ទេរចំណាត់ថ្នាក់ពីសហគ្រាសតូច ទៅសហគ្រាសមធ្យម និងបានផ្ទេរសហគ្រាសមួយចំនួនផងដែរ។ តាមការពិនិត្យលិខិតប្រកាសពន្ធប្រចាំខែ និងសលាកបត្រអនុរក្សរបស់អ្នកជាប់ពន្ធតូចមួយចំនួននៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្ត១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុន សហគ្រាសមួយចំនួនតូចបានប្រកាសផលរបរលើសពី ១ ០០០លានរៀល ប៉ុន្តែសហគ្រាសទាំងនោះពុំទាន់ត្រូវបានផ្ទេរចំណាត់ថ្នាក់នៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.៤. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងក្រសួងមួយចំនួន ក៏បានផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារផងដែរ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារពុំទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្តាក្រសួងស្ថាប័នមួយចំនួនផ្សេងទៀតឱ្យបានពេញលេញ និងទាន់ពេលវេលានៅឡើយ ដោយសារក្រសួងមួយចំនួនពុំទាន់សហការ។ ចំពោះបញ្ហានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.៥. ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ត្រង់មាត្រា២០១ បានចែងថា "អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់..." មាត្រា២០១ នៃច្បាប់ខាងលើ ត្រង់ចំណុច៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធមិនកាន់ កត់ត្រា ឬកត់ត្រាមិនត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬកំណត់ត្រានានាតាមលក្ខខណ្ឌដែលបានកំណត់ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់នូវប្រាក់ចំណូល និងចំណាយផ្សេងៗ" និងមាត្រា២០៩ នៃច្បាប់ខាងលើ ត្រង់ចំណុចទី៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមិនបានដាក់លិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យ ឬឯកសារផ្សេងទៀតតាមការតម្រូវ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវក្នុងការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធឯកតោភាគី..."។

តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្ម សហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញ ថា អ្នកជាប់ពន្ធមួយចំនួនតូច ពុំទាន់បានកាន់កាប់កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និង លិខិតយុត្តិការឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.៦. ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ក្រុមហ៊ុន សហគ្រាសមួយចំនួន

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ត្រង់មាត្រា២០៦ ចំណុច១ បានចែងថា "អ្នកជាប់ពន្ធ ឬភ្នាក់ងារ កាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ ពេលវេលា និងទី កន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់"។ មាត្រា២២ នៃច្បាប់ខាងលើ អំពើរាំងស្ទះការអនុវត្តបទ ប្បញ្ញត្តិស្តីពីពន្ធដារ កថាខណ្ឌទី៣ "ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ" និងមាត្រា២៣៥ នៃ ច្បាប់ខាងលើ ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារបានចែង ថា "ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀល ដោយរដ្ឋបាលសារពើពន្ធដោយ ពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលធ្លាប់បានទទួលការព្រមានជា លាយលក្ខណ៍អក្សរពីរដ្ឋបាលសារពើពន្ធលើសពី២ (ពីរ)លើក ហើយនៅតែប្រព្រឹត្តនូវអំពើរាំងស្ទះ ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថា ខណ្ឌទី៣នៃមាត្រា២២៥"។ តាមការពិនិត្យស្ថិតិសហគ្រាសជាប់ពន្ធមធ្យម និងតូចប្រចាំខែក្នុងឆ្នាំ ២០២៤ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខណ្ឌ និងខេត្តទាំងនោះ បានរៀបចំសិក្ខាសាលា ដើម្បីបណ្តុះបណ្តាល និងផ្សព្វផ្សាយ កាតព្វកិច្ចសារពើពន្ធជូនអ្នកជាប់ពន្ធជារៀងរាល់ឆ្នាំ។ ជាងនេះទៀត សាខាពន្ធដារទាំងនោះ បាន ក្រើនរំលឹកដល់អ្នកជាប់ពន្ធដែលខកខានក្នុងការដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែផងដែរ។ ទោះជាយ៉ាងនេះក្តី ការបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែរបស់សហគ្រាសមួយចំនួន ពុំទាន់បានខ្ជាប់ខ្ជួននៅឡើយមាន ដូចជា៖ សហគ្រាសជាប់ពន្ធមធ្យមបានដាក់លិខិតប្រកាស ប្រចាំខែប្រមាណ៦៣,៤១%នៃសហគ្រាសត្រូវដាក់លិខិតប្រកាស និងសហគ្រាសជាប់ពន្ធតូច បានដាក់លិខិតប្រកាសប្រចាំខែប្រមាណ៥៦,៨៥%នៃសហគ្រាសត្រូវដាក់លិខិតប្រកាស។ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀត សម្រាប់ឆ្នាំបន្ទាប់។

### ៤.៧. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ

ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយ ភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុង ចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធ ជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធប្រចាំខែ និងលិខិតប្រកាសពន្ធលើ

ប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុនមួយចំនួននៅអង្គភាពពន្ធដារចំនួន ២៤ អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា ការត្រួតពិនិត្យលើភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធ ដើម្បីធានាថា លិខិតប្រកាសត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស គណនាឱ្យបានត្រឹមត្រូវ និងភាពមិនប្រក្រតីនៃលិខិតប្រកាសពុំទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ ដោយសារមន្ត្រីនៅការិយាល័យចាត់ចែងលិខិតប្រកាសមានចំនួនតិច ហើយអ្នកជាប់ពន្ធមានចំនួនច្រើន រួមទាំងប្រតិបត្តិការច្រើន ហើយសហគ្រាសអ្នកជាប់ពន្ធតូចមួយចំនួន ដែលបានដាក់លិខិតប្រកាសតាមប្រព័ន្ធ GDT Tax Pre-filing មន្ត្រីពន្ធដារអាចត្រួតពិនិត្យតួលេខប្រកាសប្រាក់ពន្ធ ប៉ុន្តែមន្ត្រីមិនអាចទាញលិខិតប្រកាសពន្ធទាំងនោះទេ។ ចំណែកឯលិខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនមួយចំនួន មានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ ពុំប្រកាសពន្ធកាត់ទុកលើមុខចំណាយមួយចំនួនក្នុងអត្រា ១០% និង ១៥% ប្រកាសរំលងវិក្កយបត្រ ចេញវិក្កយបត្រលក់គ្មានលេខ ចេញវិក្កយបត្រអាករមានទម្រង់ច្រើនផ្សេងៗគ្នា ប្រកាសថ្លៃជួលទីតាំងនៅមានកម្រិត ប្រកាសចំណូល និងចំណាយថេរ ពុំប្រកាសចំណូលជារៀងរាល់ខែ ចេញវិក្កយបត្រមិនត្រឹមត្រូវ (មិនបែងចែងប្រភេទអ្នកជាប់ពន្ធ) ប្រកាសអាករពិសេសខ្វះ កត់ត្រាបញ្ជីស្តុកមិនទាន់ត្រឹមត្រូវបង់ប្រាក់ពន្ធកាត់ទុកលើឈ្នួល (រូបវន្តបុគ្គល) ១០% ខុសអនុគណនី ប្រកាសបង់អាករលើតម្លៃបន្ថែមមិនត្រឹមត្រូវ ពុំបានប្រកាសបុគ្គលិកដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស និងពុំបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.៨. ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២៤

សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ជាកំហិត។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសមតុល្យសាច់ប្រាក់មួយចំនួននៅសល់ចុងឆ្នាំ២០២៤ ពុំបានកត់ត្រាចូលជាចំណូលក្នុងឆ្នាំនៅឡើយទេ ប៉ុន្តែចំណូលទាំងនេះបានធ្វើការបង្វែរចូលថវិកាជាតិនៅដើមឆ្នាំ២០២៥។ កត្តានេះអាចនាំឱ្យការកត់ត្រាចំណូលចំណាយថវិកាពុំបានឆ្លុះបញ្ចាំងតួលេខជាក់ស្តែងតាមឆ្នាំនៃថវិកា។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងសូមបញ្ជាក់បន្ថែម ដូចខាងក្រោម៖

- ថ្ងៃដំណាច់ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាត្រូវបិទបញ្ជី និងប្រតិបត្តិការទទួលប្រាក់ចំណូល, ចំណែកធនាគារពាណិជ្ជត្រូវបិទប្រតិបត្តិការផ្ទេរចំណូលទៅគណនីទោលរតនាគារនៅធនាគារជាតិនៃកម្ពុជាវេលាម៉ោង ១៥:០០នាទី នៃថ្ងៃធ្វើការស្របតាមអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារសម្រាប់ប្រតិបត្តិការចំណូល

ជាហេតុនាំឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មិនអាចបង្វែរចំណូល ដែលបានបំពេញបែបបទគយរួចនៅថ្ងៃដំណាច់ឆ្នាំទាំងនេះចូលថវិកាជាតិក្នុងឆ្នាំសារពើពន្ធបាន

- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចេញលិខិតលេខ ៥៤៧៧/២៤ អគរ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការបិទបញ្ជីចំណូល-ចំណាយថវិកាឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាជម្រាបជូនគ្រប់ប្រធាននាយកដ្ឋានសាខា និងការិយាល័យគយនិងរដ្ឋាករ ត្រូវជូនដំណឹងដល់ធុរជនដែលត្រូវបំពេញកាតព្វកិច្ចបង់ពន្ធអាករ និងកម្រៃគ្រប់ប្រភេទនៅចុងឆ្នាំ២០២៤ រូតរះធ្វើការបង់ចំណូលឱ្យបានត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ចំពោះចំណូលនៅសេសសល់ ត្រូវកត់ត្រាស្ថានភាពសល់ក្នុងបេឡា និងត្រូវរូតរះរៀបចំសលាកបត្របង់ចំណូលថវិកាជាតិដោយឡែក នៅថ្ងៃធ្វើការបន្ទាប់។

## ៤.៩. ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើមដែលទទួលបានការអនុគ្រោះព្ធ ឬលើកលែងពន្ធអាករនៅមានកម្រិត

ប្រកាសស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ជាក់ថា នាយកដ្ឋានរបបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររបបគយដោយមានតួនាទី និងភារកិច្ចដូចជា៖ ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតគយនាំចេញនាំចូលទំនិញតាមរបបគយអនុគ្រោះនានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យការប្រើប្រាស់សម្ភារបរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ នាយកដ្ឋានរបបគយបានអនុញ្ញាតឱ្យនាំចូលនូវពន្ធអាករជាបន្ទុករដ្ឋលើមុខទំនិញនាំចូលដូចជា៖ វត្ថុធាតុដើមគ្រឿងបន្សំ សារធាតុគីមី គ្រឿងម៉ាស៊ីន គ្រឿងបន្លាស់ សម្ភារសំណង់ សម្ភារបរិក្ខារផ្សេងៗ និងទំនិញនាំចូលគ្រប់ប្រភេទ ដែលមានលក្ខណៈ ជាវិនិយោគកាត់ដេរ និងវិនិយោគមិនមែនកាត់ដេរ ដោយទទួលបាននូវរបបអនុគ្រោះក្រោមរបបព្យួរពន្ធ ឬលើកលែងពន្ធអាករ។ ប៉ុន្តែ ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើទិសដៅនៃការប្រើប្រាស់សម្ភារ បរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទដែលនាំចូលជាលក្ខណៈវិនិយោគទុនកាត់ដេរ និងវិនិយោគទុនផ្សេងនៅមានកម្រិតនៅឡើយ។ កត្តានេះនាំឱ្យការគ្រប់គ្រងតាមដាន និងត្រួតពិនិត្យអនុលោមភាពពុំទាន់បានគ្រប់ជ្រុងជ្រោយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា កន្លងមកនាយកដ្ឋានរបបគយ បានបន្តសហការចូលរួមជាមួយនឹងគណៈកម្មការអន្តរស្ថាប័ននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចុះពិនិត្យលើសំណើសុំផ្ទេរ លក់ និងបោះបង់ចោលនូវគ្រឿងម៉ាស៊ីន សម្ភារ បរិក្ខារផលិតកម្ម និងវត្ថុធាតុដើមបម្រើឱ្យខ្សែច្រវ៉ាក់ផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាច្រើន

ករណី។ ក្នុងក្របខ័ណ្ឌអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មន្ត្រីនៃនាយកដ្ឋានរបបគយចុះដោយផ្ទាល់ និងសហការជាមួយមន្ត្រីនៃអង្គភាពពាក់ព័ន្ធផ្សេងទៀត ចុះត្រួតពិនិត្យអនុលោមភាពលើមុខទំនិញនាំចូលដោយពន្ធ និងអាករបន្ទុករដ្ឋបម្រើឱ្យផលិតកម្មរបស់គម្រោងវិនិយោគមួយចំនួនជាពិសេសលើការប្រើប្រាស់ខុសគោលដៅដែលបានអនុញ្ញាត និងរកឃើញបទល្មើសមួយចំនួនដែលបានជ្រកក្រោមរូបភាពគម្រោងវិនិយោគទាំងនោះ។

### ៤.១០. ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ

នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាលើការងារដូចជា៖ ពិនិត្យកំណត់ហេតុល្មើសគយ លើកសំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យលើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច។ ប្រកាសលេខ ៦១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះសម្រួលនូវបទល្មើសគយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានធ្វើសេចក្តីសម្រេចវិនិច្ឆ័យលើកំណត់ហេតុល្មើសច្បាប់គយចំនួន ១ ៦៤២ (កំណត់ហេតុឆ្នាំ២០២៤បូកនឹងកំណត់ហេតុនៅសល់ឆ្នាំកន្លងមក) ប៉ុន្តែនៅមានកំណត់ហេតុល្មើសច្បាប់គយមួយចំនួន ៣៥១ករណីផ្សេងទៀត នៅពុំទាន់បានចាត់វិធានការ និងដំណោះស្រាយឱ្យបានសមស្របនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងសូមបំភ្លឺបន្ថែមថា ពាក់ព័ន្ធនឹងកំណត់ហេតុល្មើសច្បាប់គយដែលនៅសល់ក្នុងឆ្នាំ២០២៤ ចំនួន ៣៥១ ជាវឌ្ឍនភាពគិតត្រឹមខែកក្កដា ឆ្នាំ២០២៥ កំណត់ហេតុដែលនៅសល់ឆ្នាំ២០២៤ មានចំនួន ៣៣៨ កំណត់ហេតុ ដោយបានដោះស្រាយបានចំនួន ១៣កំណត់ហេតុ។ កំណត់ហេតុដែលនៅសល់ចំនួន ៣៣៨នេះ មានដូចជា៖ កំណត់ហេតុដែលជារថយន្តល្មើសចំនួន ២២៦កំណត់ហេតុ ស្មើនឹង ២២៦គ្រឿង (៧៤គ្រឿង រង់ចាំការលក់ដេញថ្លៃជាសាធារណៈដោយគណៈកម្មការចំពោះកិច្ច។ ចំពោះរថយន្តនៅសល់ ១៥២គ្រឿងទៀត អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងស្នើសុំគោលការណ៍ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានវិធានការដាក់លក់ដេញថ្លៃ ឬធ្វើអំណោយដល់អង្គភាពរដ្ឋតាមការស្នើសុំ) និងមានម៉ូតូ ៤៣ គ្រឿង ស្មើនឹង ៨កំណត់ហេតុ រង់ចាំការស្នើសុំគោលការណ៍ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានវិធានការដាក់លក់ដេញថ្លៃ ឬធ្វើអំណោយ និងមានទំនិញចម្រុះ ចំនួន ១០៤កំណត់ហេតុ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ខិតខំជំរុញម្ចាស់ឱ្យចូលខ្លួនមកសម្របសម្រួលដោះស្រាយឱ្យអស់លទ្ធភាព និងពិនិត្យលទ្ធភាពស្នើសុំគោលការណ៍ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានវិធានការដាក់លក់ដេញថ្លៃ ឬធ្វើអំណោយ។

### ៤.១១. ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ

សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ ណាមួយបានឡើយ។ ដូចនេះប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ជាកំហិត។ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) នៅមានតួលេខសមតុល្យសល់ពីចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្ដាលក្រសួង ស្ថាប័ន) ចុងឆ្នាំ២០២៤ ចំនួន ៨០៦ លានរៀល ដោយមិនទាន់បានបង្វែរចូលថវិកាជាតិបានទាន់ពេលនៅឡើយ កត្តានេះអាចនាំឱ្យការកត់ត្រាចំណូលចំណាយថវិកាមិនឆ្លុះបញ្ចាំងតាមឆ្នាំថវិកា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងសូមបំភ្លឺបន្ថែមថា ការបង់ចំណូលថវិកាជាតិយឺតចំនួន ៨០៦ ៤០០ ០០០រៀល ដែលជាចំណូលប្រចាំខែធ្នូឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)។ ករណីនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការបង់រួចរាល់កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៥ យោងប្រកាសឥណទានរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៥។

### ៤.១២. ការប្រមូលពន្ធលើថ្លៃឈ្នួលចលន និងអចលនទ្រព្យ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវកំណត់តាមអត្រា១០ (ដប់) ភាគរយនៃថ្លៃឈ្នួលអចលនទ្រព្យ ហើយកម្មសិទ្ធិករ ឬសិទ្ធិវន្ត ឬអ្នកតំណាងដែលមានសិទ្ធិត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធក្នុងភូមិសាស្ត្រដែលអចលនទ្រព្យស្ថិតនៅ តាមកាលកំណត់ជារៀងរាល់ខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលត្រូវបង់ប្រាក់...”។ តាមការធ្វើតេស្តលើសំណុំឯកសារប្រមូលពន្ធឈ្នួលផ្ទះ និងដីចំនួន ៣១០ និងកិច្ចសន្យាជួលចំនួន៣២៨ របស់សហគ្រាសដែលបានចុះបញ្ជីថ្មីនៅក្នុងឆ្នាំ២០២៤ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ម្ចាស់ចលនទ្រព្យ ឬអចលនទ្រព្យចំនួន១២ យឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ និងសហគ្រាសដែលបានជួលចលនទ្រព្យ ឬអចលនទ្រព្យចំនួន៣៩ នៅពុំទាន់បានបង់ប្រាក់ពន្ធកាត់ទុកលើថ្លៃឈ្នួលចលន និងអចលនទ្រព្យនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.១៣. ការកត់ត្រាប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ

ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩បានផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត ចំពោះពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យរូបវន្តបុគ្គល (អនុគណនី ៧០០១៤) និងពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យនីតិបុគ្គល (អនុគណនី ៧០០១៥)” ។

ប្រកាសលេខ ១៤៣១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រគល់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ២ បានចែងថា "អគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារខេត្ត ខណ្ឌត្រូវប្រមូលចំណូលពីពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ និងរៀបចំសលាកបត្របង់ប្រាក់ចំណូលចូលទៅរតនាគាររាជធានី ខេត្ត ដើម្បីកត់ត្រាជាចំណូលថវិការដ្ឋបាលរាជធានី ខេត្តនីមួយៗ។ តាមការពិនិត្យស្ថិតិប្រាក់ពន្ធលើឈ្នួលចលន និងអចលនទ្រព្យរបស់រូបវន្តបុគ្គល និងនីតិបុគ្គលប្រចាំខែ និងសំណុំឯកសារផ្សេងៗ ក្នុងឆ្នាំ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រមូលចំណូលពន្ធលើឈ្នួលចលន និងអចលនទ្រព្យសរុបចំនួន ៣៨៨ ២៦៧ ០៥០ ៥៦៩ រៀល ស្មើនឹង ៩៧,២៧% នៃផែនការ។ ក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាល មួយចំនួនបានប្រកាស និងបង់ប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យទាំងនេះជូនដល់អង្គភាពពន្ធដែលក្រុមហ៊ុនទាំងនោះបានចុះបញ្ជី ប៉ុន្តែអង្គភាពពន្ធដែលទទួលបានចំណូលប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យទាំងនោះពុំទាន់បានបង្វែរប្រាក់ពន្ធខាងលើទៅអង្គភាពពន្ធដែលស្ថិតនៅតាមទីតាំងជួលជាក់ស្តែងនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

### ៤.១៤. ការប្រមូលពន្ធលើអចលនទ្រព្យ

អ្នកជាប់ពន្ធដែលមានអចលនទ្រព្យដែលមានតម្លៃលើសពី ១០០ ០០០ ០០០រៀល ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើអចលទ្រព្យជារៀងរាល់ឆ្នាំជូនរដ្ឋបាលសារពើពន្ធក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីជូនដំណឹងអំពីការសម្រេចរបស់រដ្ឋាភិបាលលើកទឹកចិត្តពន្ធដារ ចំពោះពន្ធអចលនទ្រព្យដោយអនុញ្ញាតបន្តការលើកលែងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និងការប្រាក់) បន្ថែមទៀតផង។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រឹងប្រែងចេញលិខិតជូនដំណឹងស្តីពីការប្រមូលពន្ធអចលនទ្រព្យប្រចាំឆ្នាំជារៀងរាល់ឆ្នាំ ដោយបានធ្វើការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ គេហទំព័រ បណ្តាញសង្គមរបស់អគ្គនាយកដ្ឋានពន្ធដារ និងជាខិតប័ណ្ណផ្សព្វផ្សាយ ឬលិខិតជូនដំណឹងដាក់តាមឃុំសង្កាត់ ដើម្បីជូនដំណឹងដល់អ្នកជាប់ពន្ធ។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធអចលនទ្រព្យ និងបានបង់ចូលថវិកាក្នុងឆ្នាំ២០២៤ សរុបចំនួន ១៥៣ ៦៩៥ ៩៩៦ ៥៣៧រៀល ស្មើនឹង ៨៤,១៩%នៃផែនការ ប៉ុន្តែតាមការធ្វើតេស្តនៅសាខាពន្ធដារខណ្ឌចំនួន៩ នៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអចលនទ្រព្យមួយចំនួនតូច ពុំទាន់ត្រូវបានបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំ២០២៤ នៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងសូមបញ្ជាក់បន្ថែមថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការណែនាំ និងជំរុញឱ្យអាជ្ញាធរមូលដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិរួមសហការជាមួយសមត្ថកិច្ចជំនាញក្នុងការកៀរគរប្រភពចំណូលពន្ធលើអចលនទ្រព្យនេះ ស្របតាមខ្លឹមសារ

អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ជាមួយគ្នានេះ នៅឆ្នាំ២០២៦ រដ្ឋបាលខេត្តចំនួន១២ នឹងបញ្ចូលកិច្ចការនេះ ទៅក្នុងផែនការសកម្មភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលខេត្ត ដើម្បីពង្រឹងបន្ថែមទៀតលើយន្តការប្រមូលចំណូលសារពើពន្ធសម្រាប់ឆ្នាំបន្តបន្ទាប់។

**៤.១៥. ការមិនទាន់បានប្រមូលចំណូលពីកម្រៃសេវាសាធារណៈមួយចំនួន**

តាមរយៈការពិនិត្យតារាងតាមដានចំណូលពីកម្រៃសេវាសាធារណៈរបស់ក្រសួងព័ត៌មានអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងព័ត៌មាននៅតែមិនទាន់បានអនុវត្តប្រមូលចំណូលពីកម្រៃផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ ផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ អាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ និងអាជីវកម្មរោងពុម្ពឱ្យបានពេញលេញទៅតាមប្រកាសរួមស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាននៅឡើយ។ ក្រសួងព័ត៌មានបានធ្វើការបញ្ជាក់ថា ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈដែលមានដូចជា៖ កម្រៃផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ ផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ អាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ និងអាជីវកម្មរោងពុម្ព យោងប្រកាសលេខ ៣៥១ ប្រក.ពម ស្ដីពីការធ្វើប្រតិភូកម្មផ្ទេរមុខងារការផ្ដល់សេវារដ្ឋបាលលើវិស័យព័ត៌មានជូនរដ្ឋបាលរាជធានី-ខេត្ត ហេតុនេះ សេវាដែលបានរៀបរាប់ខាងលើជាសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី-ខេត្តបានប្រតិភូទៅជាសេវាថ្នាក់ក្រោមជាតិតាមយន្តការច្រកចេញ-ចូលតែមួយ។

**៤.១៦. ការទូទាត់ និងការកត់ត្រាចំណាយ**

ជាគោលការណ៍ ការសន្យាដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅថ្ងៃទី៣១ ខែធ្នូ ត្រូវបានកត់ត្រាជាបន្តចូលក្នុងឥណទាននៃថវិកានៃឆ្នាំបន្ទាប់។ សារាចរណែនាំលេខ ០១១ សហវ.សរណ.អថ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ ត្រង់ចំណុចខ-អំពីចំណាយថវិកាថ្នាក់ជាតិ បានបញ្ជាក់ថា "...រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្តត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម (រួមទាំងអាណត្តិទូទាត់ប្រាក់រង្វាន់) និង/ឬប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS ឆ្នាំ២០២៤ ត្រឹមវេលាម៉ោង១៧ និង៣០នាទីនាថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៥..."។ សារាចរណែនាំបន្ថែមលេខ ០០៤ សហវ.សរណ.អរតន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៤ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ ត្រង់ចំណុច៣ នៃផ្នែក "ក" បានកំណត់ថា "ក្រោយកាលបរិច្ឆេទកំណត់វេលាម៉ោង១៧ និង៣០នាទី នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ រតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយ័តកម្មឆ្នាំ២០២៤ ហើយប្រតិបត្តិការចំណាយ

(Voucher) ក្នុងប្រព័ន្ធ FMIS ក៏មិនត្រូវបានអនុញ្ញាតឱ្យអនុម័តបញ្ជូនបន្តទៅរតនាគារថ្នាក់កណ្តាលទៀតទេ...”។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ (សម្រាប់រដ្ឋបាលកណ្តាល) ចំនួន១៧អាណត្តិបើកប្រាក់ ត្រូវបានបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់នៅក្រោយថ្ងៃកំណត់បិទបញ្ជី (ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៥) និងបានកត់ត្រាជាចំណាយថវិកាប្រចាំឆ្នាំ២០២៤។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា នៅរៀងរាល់ដំណាច់ឆ្នាំថវិកានីមួយៗ មានការបញ្ជូនអាណត្តិបើកប្រាក់ក្នុងចំនួនច្រើននាដើមឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានភាពយឺតយ៉ាវ ប៉ុន្តែសម្រាប់ឆ្នាំថវិកា២០២៤ មានវឌ្ឍនភាពល្អប្រសើរបានលឿនជាងឆ្នាំកន្លងទៅ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសារាចរណែនាំបន្ថែមលេខ ០០៤ សហវ.សរណ.អរតន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៥ ស្តីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយ័តកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៤ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)សម្រាប់ថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤។ ដោយឡែកបើពិនិត្យប្រភេទអាណត្តិទាំងនោះ មានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិបុរេប្រទាន នីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងរដ្ឋទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវទូទាត់ជម្រះបញ្ជីក្នុងឆ្នាំថវិកា ២០២៤ ដើម្បីបិទបញ្ជីចំណាយថវិកា។ ការទូទាត់ចំណាយខាងលើ គឺបានសម្រួលដល់ការទូទាត់ចំណាយចាំបាច់ និងបញ្ចៀសការបង្ករបន្ទុកចំណាយទៅឆ្នាំថវិកា២០២៥ និងឆ្នាំបន្តបន្ទាប់។ម្យ៉ាងទៀត រយៈពេលនេះគឺស្ថិតក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តជំរុញក្រសួង ស្ថាប័នឱ្យរួសរាន់រៀបចំលិខិតយុត្តិការចំណាយ និងបោះផ្សាយអាណត្តិបើកប្រាក់ រួចបញ្ជូនទៅអភិបាលថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីអាចទូទាត់បានទាន់ពេល ជាពិសេសការទូទាត់ជម្រះបញ្ជីបុរេប្រទាន ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងចំណាយតាមរដ្ឋទេយ្យបុរេប្រទានឱ្យទាន់ក្នុងឆ្នាំថវិកា ជៀសវាងការបង្ករបន្ទុកចំណាយថវិកាទៅឆ្នាំថវិកាបន្ទាប់។ ជាមួយគ្នានេះដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងការអនុវត្តការងារពិនិត្យ និងទូទាត់ចំណាយតាមនីតិវិធីថ្មីទាំងស្រុងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីចូលរួមជំរុញការអនុវត្តចំណាយថវិកាឱ្យបានទាន់ពេល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនផងដែរថា ដោយផ្អែកតាមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលបរិច្ឆេទបញ្ឈប់ការទូទាត់ និងអនុម័ត (POSTING) ប្រតិបត្តិការចំណាយថវិកានឹងរំកិល ១៥ថ្ងៃពី១ឆ្នាំ ទៅ១ឆ្នាំ គឺថវិកាឆ្នាំ២០២៤ ត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥, ថវិកាឆ្នាំ២០២៥ ត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៦ និងថវិកាឆ្នាំ ២០២៦ ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៧ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣។

## ៤.១៧. ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់

ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុងការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ការអនុវត្តតួនាទីនេះបានគត់មុត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ ចំណាយដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចជា កិច្ចសន្យាលទ្ធកម្មដែលមានពន្ធប្រថាប់ត្រា និងប័ណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។

តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់ឆ្នាំ២០២៤ ចំនួន ៩៥៩ របស់ក្រសួងមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ចំនួន ៦០ ក្នុងចំណោម ៩៥៩ អាណត្តិបើកប្រាក់ ពុំបានភ្ជាប់នូវឯកសារគាំទ្រឱ្យបានត្រឹមត្រូវដូចជា៖ ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់ពុំសមស្របតាមកម្មវត្ថុនៃការចំណាយ (ប្រភេទអាជីវកម្មពុំត្រូវតាមការផ្គត់ផ្គង់) ពុំបានប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្ម និងប្រថាប់ត្រាក្រោយការិយបរិច្ឆេទ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា អាស្រ័យដោយនៅកៀកដំណាច់ឆ្នាំថវិកា២០២៤ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយក្នុងនោះអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួនមានបញ្ហាខ្វះចន្លោះ មិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់។ ផ្អែកតាមសារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិ បានបន្តការយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកា ដោយផ្អែកលើកំណត់ហេតុប្រគល់ ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មការលទ្ធកម្មដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់ លើទំនិញ ឬសេវាដែលបានបំពេញរួច។ ប៉ុន្តែអាស្រ័យដោយសារកត្តាពេលវេលា និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី បញ្ហាខ្វះចន្លោះមួយចំនួន ដែលតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីសាមីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចាប់ពីដើមទីនៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្ម និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តណែនាំដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ឱ្យបំពេញបន្ថែមនូវសក្ខីបត្រចំណាយដូចជា ការបង់ពន្ធប៉ាតង់បន្ថែមឱ្យស្របតាមប្រភេទអាជីវកម្ម និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្មមួយចំនួន ទើបនាំឱ្យមានករណីហួសកាលបរិច្ឆេទឆ្នាំ២០២៤។ ករណីនេះ ក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងណែនាំអគ្គនាយកដ្ឋានរតនាគារជាតិឱ្យបន្តពង្រឹងការត្រួតពិនិត្យ

លិខិតយុត្តិការចំណាយ និងទូទាត់ចំណាយថវិកាឱ្យបានត្រឹមត្រូវនិងទាន់ពេល ជាពិសេសបន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងសាមីក្រសួង ស្ថាប័ន ដែលជាអង្គភាពពាក់ព័ន្ធពីដើមទី ឱ្យចូលរួមក្នុងការពង្រឹង និងដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈនិងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយមុនពេលបោះផ្សាយអាណត្តិបើកប្រាក់។

**៤.១៨. ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ**

អនុក្រឹត្យរាជរដ្ឋាភិបាលកម្ពុជាស្តីពីលទ្ធកម្មសាធារណៈបានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" និងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា ស្ថាប័នអនុវត្ត លទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១នៃខែមេសា ខែកក្កដា ខែតុលា និងខែមករា។ ការខកខានដោយមិនបានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មតាមកាលកំណត់នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិចារណាផ្អាកការផ្តល់ធានាចំណាយសម្រាប់គម្រោងលទ្ធកម្មបន្តបន្ទាប់។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទាន់ពេលវេលា ប៉ុន្តែមានស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនទៀតមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលានៅឡើយ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | ស្ថាប័នអនុវត្តលទ្ធកម្ម | ស្ថាប័នអនុវត្តលទ្ធកម្មឆ្នាំ២០២៤ | | |
|---|---|---|---|---|
| | | បានផ្ញើ | មិនបានផ្ញើ | សរុប |
| ១ | ក្រសួង ស្ថាប័ន ចំនួន៥២ | ៥១ | ១ | **៥២** |
| | អង្គភាពថវិកា ចំនួន៦៣៧ | ៥៦១ | ៧៦ | **៦៣៧** |
| ២ | រដ្ឋបាលរាជធានីខេត្តចំនួន២៥ | ២៤ | ១ | **២៥** |
| | រដ្ឋបាលក្រុង ស្រុក ខណ្ឌ (មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត) | ២២ | ៣ | **២៥** |
| ៣ | សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ ចំនួន៥៦ | ៥៥ | ១ | **៥៦** |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបញ្ជាក់បន្ថែមថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការណែនាំ និងក្រើនរំលឹកជាច្រើនលើកក្នុងឆ្នាំអនុវត្តថវិកានីមួយៗ ព្រមទាំងបានរៀបចំផ្ញើលិខិតជូនស្ថាប័នអនុវត្តលទ្ធកម្ម ដែលមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម

ប្រចាំឆ្នាំ២០២៤ តាមរយៈលិខិតលេខ ៦៥៤, ៦៥៧, ៦៥៨, ៦៥៩ សហវ.លស.អលសា ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៥។

**៤.១៩. ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម**

ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៧ បានចែងថា "មូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រូវមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ មានការទទួលខុសត្រូវ និងអាចជឿទុកចិត្តបាន... តម្រូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត ឬអង្គភាពថវិកា" និងប្រការ៣៣ បានចែងថា "រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយដែលមិនបានកត់ត្រាក្នុងផែនការលទ្ធកម្មមិនអនុញ្ញាតឱ្យស៊ុំ ឬផ្តល់ធានាចំណាយឡើយ"។ តាមរយៈការធ្វើសវនកម្មនៅអាជ្ញាធរជាតិសំបូរព្រៃគុកសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាជ្ញាធរជាតិសំបូរព្រៃគុក បានទូទាត់ចំណាយលើការជួសជុលអគារស្នាក់នៅ និងអគារអភិរក្ស ដោយពុំបានគ្រោងក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤។ អាជ្ញាធរជាតិសំបូរព្រៃគុកបានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

**៤.២០. ការកត់ត្រាចំណាយមិនទាន់បានត្រឹមត្រូវទៅនឹងអនុគណនីនៅក្នុងប្រកាសស្តីពីចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ**

ដើម្បីឱ្យការចំណាយ និងកត់ត្រាចំណាយឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់មាតិកាថវិកាទូទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញនៅប្រកាសស្តីពីចំណាត់ថ្នាក់មាតិកាថវិកាទូទៅរបស់រដ្ឋដើម្បីឱ្យក្រសួង ស្ថាប័នមានភាពងាយស្រួលអនុវត្ត ប៉ុន្តែទន្ទឹមនឹងនោះ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖ ក្រសួងព័ត៌មានបានធ្វើការកត់ត្រាចំណាយជាក់ស្តែងលើកិច្ចប្រតិបត្តិការចំណាយអនុគណនី៦១០៥៤ លើកកិច្ចលទ្ធកម្មជួសជុលបណ្តាញទរទឹកនៅទីស្តីការក្រសួង និងកត់ត្រាចំណាយអនុគណនី៦១០៥៨ ការជួសជុលម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនហ្វូតូកូពីរ ដែលការកត់ត្រាចំណាយទាំងពីរខាងតម្រូវឱ្យកត់ត្រាក្នុងអនុគណនី៦១០៥៤ និង៦១០៥៧ ដែលការកត់ត្រាប្រតិបត្តិការចំណាយទាំងពីរខាងលើនេះមិនទាន់ស្រមទៅនឹងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការកត់ត្រាចំណាយអនុគណនី៦១០៥៧ ចំណាយលើការជួសជុលប្រព័ន្ធទឹក ភ្លើង ចំណាយអនុគណនី៦០០៥៣ ចំណាយលើការការចំណាយទិញគ្រឿងបន្លាស់ និងសម្ភារបរិក្ខារសម្រាប់ម៉ាស៊ីនស្កេន (Paper pad portable Camera Scanner) និងការចំណាយទិញគ្រឿងបន្លាស់ និងបរិក្ខារសម្រាប់ម៉ាស៊ីនហ្វូតូកូពីម៉ាក Fuji xerox V-7080 ចំនួន ៤គ្រឿង និងការចំណាយទិញសម្ភារការិយាល័យ (ប៊ិចហ្វឺត ប្រដាប់កិបគ្រាប់កិប ស្កុត) និងការកត់ត្រាចំណាយអនុគណនី៦១០៤១ ចំណាយការចំណាយរៀបចំដំណើរការប្រឡងប្រជែងផ្ទៃក្នុងប្តូរប្រភេទក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះដែលការកត់ត្រាប្រតិបត្តិការចំណាយខាងលើតម្រូវឱ្យធ្វើការកត់ត្រាក្នុងអនុគណនី៦១០៥៤ អនុគណនី៦០០៥៨ អនុគណនី៦០០២១ និងអនុគណនី៦២០២១។ ក្រសួងអប់រំ យុវជន

និងកីឡាបានធ្វើការចំណាយ និងកត់ត្រាចំណាយប្រតិបត្តិការលើការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងមិនមានព័ត៌មានវិទ្យាមួយចំនួនរបស់អង្គភាពលទ្ធកម្ម និងគម្រោងជួសជុលប្រើប្រាស់(ជំពូក២១)របស់ក្រុមលទ្ធកម្មអង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុខាងលើមិនទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់អនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋបាលកណ្តាល ដូចជា៖ ការកត់ត្រាអនុគណនី៦០០៥១ លើការទិញម៉ាស៊ីនថត Canon EOS 90D និងឧបករណ៍ការទិញឈុតឧបករណ៍ជ្រូនថតរូប និងឧបករណ៍ការទិញម៉ាស៊ីនថតម៉ាក Sony a7R IV ដែលតម្រូវឱ្យកត់ត្រាក្នុងអនុគណនី៦០០៥៥ និងកត់ត្រាចំណាយវិនិយោគអនុគណនី២១០៣១លើការការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងការជួសជុលកែលម្អអគារនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានានៅវិទ្យាស្ថានជាតិអប់រំ ដែលតម្រូវឱ្យកត់ត្រាក្នុងអនុគណនី២១០៣២ស្របតាមចំណាត់ថ្នាក់មាតិថវិកាទូទៅរបស់រដ្ឋ។ អង្គភាពថវិកាមន្ទីរពេទ្យជាតិ តេជោសន្តិភាព បានកត់ត្រាចំណាយទិញអង្គធាតុប្រតិករគីមីទៅក្នុងគណនីលេខ ៦០០៧៨ ពុំទាន់ត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋនៅឡើយ ដែលកិច្ចបញ្ជិកានេះតម្រូវឱ្យធ្វើការកត់ត្រាក្នុងអនុគណនីលេខ៦០០៧២ ដែលមានទឹកប្រាក់សរុបចំនួន ៣ ២១៥ ៨៨៤ ៦៥០ រៀល។ ក្រសួងព័ត៌មានបានធ្វើការបញ្ជាក់ថា៖ អង្គភាពលទ្ធកម្មបានអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួនដោយយោងតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលក្រសួងបានរៀបចំពីដើមឆ្នាំ ហើយទទួលបានការសម្រេចយល់ព្រមឱ្យអនុវត្តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ សម្រាប់ការអនុវត្តសកម្មភាពឆ្នាំ២០២៤។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានទទួលយកអនុសាសន៍ដែលបានលើកឡើងខាងលើ និងខិតខំអនុវត្តឱ្យបានល្អប្រសើរនៅការិយបរិច្ឆេទក្រោយៗទៀត។ ក្រសួងអប់រំ យុវ ជន និងកីឡាបានធ្វើការបញ្ជាក់ថា៖ ១. អង្គភាពលទ្ធកម្មពុំមានភារកិច្ចរៀបចំធានាចំណាយទេ។ អង្គភាពលទ្ធកម្មទទួលអនុវត្តតាមធានាចំណាយប៉ុណ្ណោះ រីឯការកត់ត្រាចំណាយមិនទាន់ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជាការងាររបស់អង្គភាពទទួលបន្ទុក។ អង្គភាពថវិកាប្រើប្រាស់ និងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុគួរពិនិត្យតម្រូវការចំណាយឱ្យស្របតាមចំណាត់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ និង២.អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ករណីនេះ ដោយសារការគ្រោងថវិកាប្រចាំឆ្នាំដាក់តែក្នុងកញ្ចប់ថវិកាជំពូក២១ ដោយមិនបានបែងចែកទៅតាមអនុគណនី និងម្យ៉ាងទៀតដោយសារការមិនយល់ច្បាស់ពីអត្ថន័យនៃការចំណាយលើអនុគណនីនីមួយៗជាហេតុធ្វើឱ្យនៅពេលអនុវត្តខុសអនុគណនី។ អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលយករបកគំហើញនេះនឹងធ្វើការកែសម្រួលឱ្យកាន់តែប្រសើរឡើងស្របតាមច្បាប់គតិយុត្តជាធរមាន។ ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងសូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងជំរុញឱ្យមន្ទីរពេទ្យជាតិ តេជោសន្តិភាព យកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យស្របតាមប្រកាស។

## ៤.២១. កង្វះខាតក្នុងការប្រមូលផ្ដុំគម្រោងកិច្ចលទ្ធកម្មដាក់ជាឡូត៍លទ្ធកម្ម

តាមការពិនិត្យគម្រោងលទ្ធកម្មផ្គត់ផ្គង់ទំនិញក្នុងផែនការលទ្ធកម្ម ផែនការលទ្ធកម្មកែតម្រូវ របាយការណ៍អនុវត្តលទ្ធកម្ម កិច្ចសន្យាលទ្ធកម្មផ្គត់ផ្គង់ទំនិញ និងសេវាកម្មមួយចំនួនរបស់អង្គភាពលទ្ធកម្មនៃក្រសួងព័ត៌មាន និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម ផែនការលទ្ធកម្ម និងសំណុំឯកសារកិច្ចលទ្ធកម្មរបស់ក្រុមលទ្ធកម្មនៃសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃក្រសួងព័ត៌មាននៅមិនទាន់បានធ្វើការប្រមូលផ្ដុំគម្រោងលទ្ធកម្មដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ធ្វើការបញ្ចូលជាកញ្ចប់លទ្ធកម្មតែមួយសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើកដើម្បីបង្កើនកម្រិតគុណភាពប្រកួតប្រជែង និងចំណេញពេលវេលា ព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយផ្សេងៗ ដូចជាគម្រោងជួសជុលអគាររដ្ឋបាល ការជួសជុលអគារស្ទូឌីយោ ការថែទាំ និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនត្រជាក់ ការថែទាំ និងជួសជុលឧបករណ៍បច្ចេកទេសជាដើម និងក្រុមលទ្ធកម្មនៃសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបងបានលើកគ្រោងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួនលើការងារជួសជុលសំណង់ និងការផ្គត់ផ្គង់ទំនិញមួយចំនួន ដែលមានទីតាំងស្ថិតក្នុងបរិវេណសាលាតែមួយ និងបម្រើឱ្យការងារតែមួយដោយពុំបានធ្វើការប្រមូលផ្ដុំនូវគម្រោងលទ្ធកម្មទាំងនោះដាក់បញ្ចូលក្នុងគម្រោងលទ្ធកម្មតែមួយដើម្បីធ្វើការអនុវត្តតែមួយលើកនោះឡើយ។ អង្គភាពលទ្ធកម្មនៃក្រសួងព័ត៌មានបានឆ្លើយបំភ្លឺថា អង្គភាពលទ្ធកម្មបានអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួនដោយយោងតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលក្រសួងបានរៀបចំពីដើមឆ្នាំ ហើយទទួលបានការសម្រេចយល់ព្រមឱ្យអនុវត្តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ សម្រាប់ការអនុវត្តសកម្មភាពឆ្នាំ២០២៤ និងក្រសួងសុខាភិបាលបានទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តជំរុញសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង ត្រូវខិតខំយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

## ៤.២២. ភាពយឺតយ៉ាវក្នុងការកំណត់ទុនដំបូងនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

អនុក្រឹត្យលេខ ១៩៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតមន្ទីរពេទ្យ ហ្លួងម៉ែ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់ផ្នែកទី៤ មាត្រា១៥ បានបញ្ជាក់ថា "ធនធានគ្រាដំបូងទទួលបានពីរដ្ឋ ដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យបង្កើតមន្ទីរពេទ្យ ហ្លួងម៉ែ នេះ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាព និងចុះហត្ថលេខាពីក្រសួង ស្ថាប័នអាណាព្យាបាលទាំងពីរ។ តារាងតុល្យ ការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា"។

អនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតមន្ទីរពេទ្យ ព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់ផ្នែកទី៤

មាត្រា១៥ បានបញ្ជាក់ថា "ធនធានគ្រាដំបូងទទួលបានពីរដ្ឋដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យបង្កើតមន្ទីរពេទ្យ ព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹមនេះ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាព និងចុះហត្ថលេខាពីក្រសួងស្ថាប័នអាណាព្យាបាលទាំងពីរ។ តារាងតុល្យការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា"។

តាមការធ្វើសវនកម្មនៅអង្គភាពថវិកាមន្ទីរពេទ្យ ហ្លួងម៉ែ និងមន្ទីរពេទ្យ ព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹមសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាខាងលើនៅតែពុំទាន់អាចកំណត់ទុនគ្រាដំបូងរបស់ខ្លួនបាននៅឡើយ។ ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងសូមទទួលយកនូវអនុសាសន៍ ដែលបានលើកឡើង និងបន្តជំរុញមន្ទីរពេទ្យ ហ្លួងម៉ែ និងមន្ទីរពេទ្យ ព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម ត្រូវខិតខំយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតមន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអនុក្រឹត្យលេខ១៩៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតមន្ទីរពេទ្យ ហ្លួងម៉ែ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

### ៤.២៣. ការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាពុំទាន់ត្រឹមត្រូវ

ប្រកាសលេខ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រង់ប្រការ១១ វាក្យខណ្ឌទី២ បានបញ្ជាក់ថា "ក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរបន្ទាប់ពីការប្រគល់ទទួលទំនិញ សំណង់ ឬសេវាគ្រប់ចំនួន ឬបន្ទាប់ពីផុតសុពលភាពធានាគុណភាពទំនិញ សំណង់ ឬសេវា ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការវិញ"។

តាមការធ្វើសវនកម្មនៅក្រសួងសុខាភិបាលសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គណៈកម្មាធិការលទ្ធកម្មនៃក្រសួងសុខាភិបាលមានភាពយឺតយ៉ាវក្នុងការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាសម្រាប់គម្រោងលទ្ធកម្មមួយចំនួន។

ក្រសួងសុខាភិបាល បានទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តជំរុញឱ្យគណៈកម្មាធិការលទ្ធកម្មរបស់ខ្លួន ត្រូវខិតខំចេញលិខិតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនក្រុមហ៊ុនឱ្យបានទាន់ពេលវេលាស្របតាមប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

### ៤.២៤. ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មមិនស្របតាមផែនការលទ្ធកម្ម

តាមការពិនិត្យផែនការលទ្ធកម្ម ផែនការកែតម្រូវ របាយការណ៍ស្តីពីការអនុវត្តលទ្ធកម្ម និងឯកសារគម្រោងកិច្ចលទ្ធកម្មក្នុងឆ្នាំ២០២៤របស់គណៈកម្មាធិការលទ្ធកម្មនៃក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងធនធានទឹក និងឧតុនិយម និងអង្គភាពលទ្ធកម្មរបស់មន្ទីរពេទ្យ ហ្លួងម៉ែ មន្ទីរពេទ្យ ព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម ក្រុមលទ្ធកម្មនៃសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែងនៃក្រសួងសុខាភិបាល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មខាងលើបានអនុវត្តកិច្ចលទ្ធកម្មមួយចំនួនពុំទាន់សមស្របតាមប្រតិទិនការងារនៃផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤ និងផែនការលទ្ធកម្មកែតម្រូវប្រចាំឆ្នាំ២០២៤ នោះទេ។ ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើការបំភ្លឺជូនថា ករណីខាងលើ ក្រសួងបានកែលម្អប្រសើរជាងមុនហើយ ដោយការិយបរិច្ឆេទ២០២៤ កន្លងមកនេះ មានគម្រោងតែចំនួន៩/៥៩គម្រោង ឬស្មើនឹង១៥%ប៉ុណ្ណោះ ដែលមានភាពយឺតយ៉ាវ។ រីឯការិលបរិច្ឆេទ ២០២៥ មិនមានករណីយឺតយ៉ាវទៀតទេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បានឯកភាពលើខ្លឹមសារនៃរបាយការណ៍សវនកម្ម និងខិតខំព្យាយាមកែលម្អនូវចំណុចខ្វះខាតទាំងឡាយដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។ ក្រសួងសាធារណការ និងឧតុនិយម បានឆ្លើយតបថា ដោយសារការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភាពយឺតយ៉ាវ និងពុំស្របតាមផែនការលទ្ធកម្ម ដែលនាំឱ្យការអនុវត្តកិច្ចលទ្ធកម្មយឺតជាងកាលបរិច្ឆេទក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ និងក្រសួងសុខាភិបាលបានទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តជំរុញអង្គភាពលទ្ធកម្មនៃក្រសួងសុខាភិបាល មន្ទីរពេទ្យ ហ្លួងម៉ែ មន្ទីរពេទ្យ ព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម និងសាលាមធ្យមសិក្សាសុខាភិបាល ភូមិភាគស្ទឹងត្រែង ត្រូវខិតខំយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមសារាចរណែនាំ។

### ៤.២៥. ការវាយតម្លៃ និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដេញថ្លៃឈ្នះដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់លទ្ធកម្មសំណង់។ កម្រងគំរូឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈស្តីពីការងារសាងសង់ ជួសជុល បានកំណត់ពីលក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃមានដូចជា៖

- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្រប្រកបអាជីវកម្មចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)

- វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស និងបទពិសោធន៍ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)

តាមការធ្វើសវនកម្មនៅអង្គភាពថវិកាសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម សម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាមបានជ្រើសរើសចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ដើម្បីធ្វើការជួសជុលអគារបណ្តុះបណ្តាលឆ្មប និងរៀបចំបរិវេណសួនក្រាលម៉ាបសម្រាប់និស្សិតស្វ័យសិក្សា ដោយក្រុមហ៊ុនពុំមានភ្ជាប់មកជាមួយនូវឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស និងបទពិសោធន៍របស់ខ្លួននោះឡើយ។

ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺថា ក្រសួងសូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តជំរុញអង្គភាពលទ្ធកម្មសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម ត្រូវខិតខំយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តឱ្យស្របតាមប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់កិច្ចលទ្ធកម្មសំណង់។

### ៤.២៦.ការពុំទាន់បានផ្ញើរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋានជូនអាជ្ញាធរសវនកម្មជាតិ

តាមរយៈការពិនិត្យរបាយការណ៍សវនកម្មរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងអប់រំ យុវជន និងកីឡាពុំទាន់បានផ្ញើរបាយការណ៍សវនកម្មប្រចាំឆ្នាំជូនអាជ្ញាធរសវនកម្មជាតិនៅឡើយ។ ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានឯកភាពតាមការរកឃើញ និងកែលម្អតាមអនុសាសន៍។

### ៤.២៧.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាចំណាយប្រចាំឆ្នាំ

តាមការធ្វើសវនកម្មនៅក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា (ផ្នែកអប់រំ ផ្នែកឧត្តមសិក្សា និងផ្នែកយុវជន និងកីឡា) គិតត្រឹមចុងខែមេសា ឆ្នាំ២០២៥ ក្រសួងទាំងពីរនៅពុំទាន់បានបញ្ចប់ការរៀបចំផ្គូផ្គងបូកសរុបការអនុវត្តចំណាយថវិការបស់ខ្លួនរួចរាល់នៅឡើយ។ ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាបានទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តជំរុញការរៀបចំរបាយការណ៍សម្រេចទូទាត់ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិឱ្យបានទាន់ពេលវេលា។

### ៤.២៨. ការពុំបានរៀបចំតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់ទុកវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ

តាមការពិនិត្យអាណត្តិបើកប្រាក់ កិច្ចសន្យា និងសំណុំឯកសារគម្រោងកិច្ចលទ្ធកម្មទំនិញប្រចាំឆ្នាំ២០២៤ សរុបចំនួន៩គម្រោងរបស់អង្គភាពលទ្ធកម្មនៃក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មខាងលើនៅមិនទាន់បានរៀបចំតារាងទិន្នន័យតម្លៃ

ទីផ្សារសម្រាប់ទុកជាព័ត៌មានបន្ថែមនៅពេលធ្វើការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យានៅឡើយ។ ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងខិតខំព្យាយាមអនុវត្តនាឆ្នាំបន្តទៀត។ ដោយឡែកចំពោះការរៀបចំតារាងទិន្នន័យតម្លៃទីផ្សារ ក្រសួងអភិវឌ្ឍន៍ជនបទនឹងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៤.២៩. កង្វះខាតក្នុងការចាត់តាំងរដ្ឋទេយ្យករត្រួតពិនិត្យលើការចំណាយថវិកាបុរេប្រទាន និងពុំបានរក្សាទុកសក្ខីប័ត្រចំណាយថវិកា**

តាមការពិនិត្យលើឯកសារទូទាត់ចំណាយថវិកាបុរេប្រទាននៃការចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគ (ហេដ្ឋារចនាសម្ព័ន្ធ) របស់នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងឯកសារគម្រោងកិច្ចលទ្ធកម្មក្នុងឆ្នាំ២០២៤របស់ក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុរបស់ក្រសួងអភិវឌ្ឍន៍ជនបទនៅពុំទាន់បានចាត់តាំងរដ្ឋទេយ្យកររបស់ក្រសួងឱ្យទទួលបន្ទុកបន្ថែមក្នុងការតាមដានការចំណាយថវិកា និងទទួលខុសត្រូវក្នុងការប្រមូលលិខិតយុត្តិការចំណាយថវិកា (សក្ខីបត្រចំណាយ) និងមិនបានរក្សាទុក (ថតចម្លង) នូវសក្ខីបត្រចំណាយថវិកាវិនិយោគលើការងារស្ថាបនាផ្លូវ ស្ពាន ដែលអនុវត្តដោយអង្គភាពរដ្ឋដែលមិនស្ថិតក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទនៅឡើយ។ ករណីនេះ ក្រសួងសូមធ្វើការបំភ្លឺជូនថា ចំពោះការចំណាយបុរេប្រទានលើសិក្ខាសាលា ការប្រជុំសន្និសីទ (ចំណាយចរន្ត) រដ្ឋទេយ្យករបានត្រួតពិនិត្យ និងថតចម្លងទុកនូវសក្ខីបត្រគាំទ្រចំណាយទាំងនេះគ្រប់គ្រាន់។ ដោយឡែកការចំណាយវិនិយោគ ដែលអនុវត្តដោយអង្គភាពរដ្ឋទាំងអង្គភាពស្ថិតក្រោមឱវាទក្រសួង (នាយកដ្ឋានផ្លូវលំជនបទ និងបណ្តាមន្ទីរអភិវឌ្ឍន៍ជនបទតាមរាជធានី ខេត្ត) សុទ្ធតែមានភ្ជាប់ និងថតចម្លងសក្ខីបត្រគាំទ្រចំណាយគ្រប់គ្រាន់។ ចំពោះអង្គភាពរបស់រដ្ឋដែលអនុវត្តការងារទៅលើចំណាយវិនិយោគ ដែលមិនស្ថិតក្រោមឱវាទក្រសួង (កងវិស្វកម្ម) ក៏មានភ្ជាប់សក្ខីបត្រគាំទ្រចំណាយផងដែរ តែមិនទាន់បានពេញលេញ និងគ្រប់គ្រាន់។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងជំរុញឱ្យអង្គភាពពាក់ព័ន្ធចូលរួមសហការបន្ថែមទៀត ដើម្បីកែលម្អអនុសាសន៍ឱ្យបានពេញលេញស្របទៅតាមអនុក្រឹត្យខាងលើនៅឆ្នាំបន្ទាប់។

**៤.៣០. ការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅថ្ងៃដែលកិច្ចសន្យាចូលជាធរមាន**

តាមការចុះធ្វើសវនកម្មនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកដេញថ្លៃឈ្នះបានធ្វើការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាលើការផ្គត់ផ្គង់គ្រឿងសង្ហារឹម និងសម្ភារប្រើប្រាស់នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ ដែលកិច្ចសន្យានេះចូលជាធរមាន។ ឆ្លើយតបតាមការលើកឡើងខាងលើ អង្គភាពលទ្ធកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បំភ្លឺថា អ្នកដេញថ្លៃឈ្នះបានធ្វើការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ ដែលកិច្ចសន្យានេះចុះជាធរមាន ដោយក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អង្គភាពលទ្ធកម្មពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចលទ្ធកម្ម។ ហេតុនេះ អង្គភាពលទ្ធកម្មពុំមានពេលវេលាគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិ។

## ៤.៣១. ការចុះថ្ងៃខែលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មក្រោយថ្ងៃវាយតម្លៃប្រគល់កិច្ចសន្យា

តាមការចុះធ្វើសវនកម្មនៅអាជ្ញាធរទន្លេសាបនៃក្រសួងធនធានទឹក និងឧតុនិយមលើអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃអាជ្ញាធរទន្លេសាបបានធ្វើការវាយតម្លៃប្រគល់កិច្ចសន្យាស្តីពីការទិញសម្ភារបរិក្ខារព័ត៌មានវិទ្យាឆ្នាំ២០២៤ជូនក្រុមហ៊ុន មុនពេលដែលសមាជិកនៃអង្គភាពលទ្ធកម្មចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម។ ឆ្លើយតបការលើកឡើងខាងលើ អង្គភាពលទ្ធកម្មនៃក្រសួងធនធានទឹក និងឧតុនិយម បានទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

## ៤.៣២. បំណុលតឹងទារពីកម្រៃសេវាចេញលិខិតអនុញ្ញាតសាងសង់

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨របស់រាជរដ្ឋាភិបាលត្រង់ផ្នែកទី៣ មាត្រា៤២ ចំណុចត្រទី៣ បានចែងថា "ផុតរយៈពេល០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់៖ ក្នុងករណីអ្នកជាប់កាតព្វកិច្ចនៅតែមិនទូទាត់បំណុលរបស់ខ្លួន ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវបញ្ជូនសំណុំរឿង និងឯកសារភស្តុតាងទាំងអស់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្តល់កិច្ចសហការ ដើម្បីចាត់វិធានការតឹងទារបំណុលតាមរយៈយន្តការក្រុមការងារអន្តរក្រសួង ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" និងបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ ចែងថា "ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវដាក់ចេញវិធានការជាមួយក្រសួង ស្ថាប័នសាមី និងក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តការតឹងទារបំណុលដែលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋដូចជា៖ បញ្ឈប់ការអនុញ្ញាតនាំចូល នាំចេញ បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាប័ណ្ណ និងក្នុងករណីការអនុវត្ត តឹងទារបំណុលនេះមិនមានប្រសិទ្ធភាព ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ"។

តាមរយៈការពិនិត្យរបាយការណ៍តាមដានចំណូលពីសេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋទេយ្យករចំណូលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅមានបំណុលត្រូវទារពីកម្រៃចេញលិខិតអនុញ្ញាតសាងសង់ដែលម្ចាស់សំណង់នៅជំពាក់មិនទាន់បានបង់ប្រាក់គិតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩ សរុបទឹកប្រាក់ចំនួន ២៥៧ ៥៣០ ០០០រៀល។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានធ្វើលិខិតទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំលុបបំណុលតឹងទារពីចំណុលសេវាសាធារណៈតាមរយៈលិខិតលេខ ១២៤៥ ដនស/អរប/ផសហ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ ហើយក៏បានជួបប្រជុំដោះស្រាយបញ្ហាសំណើរបស់ក្រសួងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ និងបានធ្វើលិខិតជម្រាបជូនម្ចាស់បំណុលមកបង់កម្រៃសេវា។

## ៤.៣៣. កង្វះយន្តការចំពោះម្ចាស់សំណង់ដែលបានទទួលលិខិតអនុញ្ញាតសាងសង់រួច មិនព្រមមកធ្វើការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ច្បាប់ស្តីពីសំណង់ដែលប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ត្រង់មាត្រា៣៨ បានចែងថា "រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។ លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ"។ ប្រកាសលេខ៣២ ប្រក/សណ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ត្រង់ប្រការ៣ បានចែងថា "ការដ្ឋាននីមួយៗអាចដំណើរបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន។ លិខិតអនុញ្ញាតបើកការដ្ឋានត្រូវស្នើសុំនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុងក្នុងរយៈពេលមួយខែយ៉ាងយូរបន្ទាប់ពីបានទទួលលិខិតអនុញ្ញាតសាងសង់" និងប្រការ១៤ នៃប្រកាសខាងលើបានចែងថា "ការដ្ឋានដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិដូចមានចែងក្នុងប្រការ៣ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការងារការដ្ឋានជាបណ្តោះអាសន្ន។ ក្នុងករណីម្ចាស់ការដ្ឋានរឹងរូសនៅតែបន្តការសាងសង់ អាជ្ញាធរមានសមត្ថកិច្ចត្រូវមានវិធានការដកហូតសម្ភារសាងសង់ទាំងនោះហើយប្តឹងទៅតុលាការ"។

តាមការពិនិត្យរបាយការណ៍បូកសរុបលទ្ធផលប្រចាំឆ្នាំ២០២៤របស់ការិយាល័យច្រកចេញ ចូលតែមួយនៃអគ្គនាយកដ្ឋានរដ្ឋបាលរបស់ក្រសួងរៀបចំដែនដី នគរូបនីយ កម្ម និងសំណង់ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៤ ក្រសួងបានចេញលិខិតអនុញ្ញាតសាងសង់ក្នុងសមត្ថកិច្ចរបស់ក្រសួងសរុបចំនួន៤២០គម្រោង ក្នុងនោះក្រសួងបានចេញលិខិតអនុញ្ញាតបើកការដ្ឋានបានចំនួន៣៣២គម្រោង ប៉ុន្តែម្ចាស់គម្រោងចំនួន៨៨ទៀត មិនព្រមធ្វើការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ពីក្រសួង។ ជាមួយគ្នានេះ ក្រសួងក៏ពុំទាន់មានវិធានការចំពោះម្ចាស់សំណង់ដែលបានទទួលលិខិតអនុញ្ញាតសាងសង់រួច ប៉ុន្តែពុំព្រមមកធ្វើការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ពីក្រសួងនៅឡើយ។

ឆ្លើយតបតាមការលើកឡើង នាយកដ្ឋានសំណង់បំភ្លឺថា ដោយសារការដ្ឋានសំណង់មួយចំនួនដូចការដ្ឋានស្ថានីយប្រេង ពេលគាត់ស្នើសុំលិខិតអនុញ្ញាតសាងសង់ហើយ គាត់ចាប់ផ្តើមធ្វើការសាងសង់រួចប្រើប្រាស់តែម្តង និងមិនមកស្នើសុំអនុញ្ញាតបើកការដ្ឋានសំណង់ទេ។ សម្រាប់អគារឃ្លាំង ពេលស្នើសុំលិខិតអនុញ្ញាតសាងសង់ហើយ គាត់ចាប់ផ្តើមសាងសង់ប្រើប្រាស់តែម្តង។ ម្ចាស់សំណង់ខ្លះ បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ហើយ តែពុំបានដំណើរការសាងសង់ទេដោយខ្វះថវិការង់ចាំរកដៃគូសហការដើម្បីចូលរួមអនុវត្តគម្រោង។ មួយវិញទៀត ការដ្ឋានសំណង់មួយប្រភេទ សំណង់ជួលដីរយៈពេលខ្លីសម្រាប់សាងសង់។ ដោយចំពោះសំណង់ជាប្រភេទអគារស្នាក់នៅរួម ឬបុរី ម្ចាស់សំណង់ត្រូវការបំបែកក្បាលដី ឬជាយូនីតជូនអតិថិជនដែលតម្រូវឱ្យមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបិទការដ្ឋានសំណង់។ ដូច្នេះ គ្រប់សំណង់ប្រភេទនេះ

មានការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។ លើសពីនេះ ក្រសួងនឹងបន្តមានវិធានការចំពោះម្ចាស់សំណង់ដែលពុំបានមកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវចាត់វិធានការអញ្ជើញណែនាំ និងពិន័យអន្តរកាល។

## ៤.៣៤. ការអនុវត្តតួនាទីរបស់អង្គភាពថវិកាមិនទាន់ពេញលេញ

អនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់មាត្រា១ បានបញ្ជាក់ថា "អង្គភាពថវិកាគឺជាអង្គភាពដែលត្រូវបានទទួលស្គាល់អាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណង គោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន" និងប្រកាសអន្តរក្រសួងលេខ ១១២ ប្រក.ធទ.ឧ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងធនធានទឹក និងឧតុនិយម ស្ដីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់ប្រការ១ បានបញ្ជាក់ថា "ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន២៧ ដូចខាងក្រោម៖

- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល
- អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស
- មន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្តចំនួន២៥

តាមការពិនិត្យអាណត្តិទូទាត់របស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេសមិនទាន់មានអាណត្តិកិច្ចច្បាស់លាស់ (អាណាប័កផ្ទេរសិទ្ធិ) ក្នុងការអនុវត្តសកម្មភាពការងាររបស់ខ្លួន ដូចជាការទូទាត់ថវិកាចំណាយរជ្ជទេយ្យបុរេប្រទាននៅឡើយ។ ក្រសួងធនធានទឹក និងឧតុនិយមបានទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

## ៤.៣៥. ការស្នើសុំទូទាត់ប្រាក់បុរេប្រទានពុំមានសក្ខីបត្រភ្ជាប់មកជាមួយ

តាមការចុះធ្វើសវនកម្មនៅក្រសួងធនធានទឹកនិងឧតុនិយមសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងបានស្នើសុំទូទាត់ទឹកប្រាក់ក្នុងអាណត្តិនិយ័តកម្ម និងអាណត្តិបើកប្រាក់បង្គ្រប់នៃការចំណាយលើការងារគាំទ្រ ពង្រឹង និងបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកដែលមានទឹកប្រាក់សរុបចំនួន ៨ ០០០ លានរៀល ក្នុងនោះទឹកប្រាក់ចំនួន ៩៥៥ លានរៀល មានសក្ខីបត្រចំណាយ រីឯទឹកប្រាក់ចំនួន ៧ ០៤៥ លានរៀលផ្សេងទៀតនៃថវិការបស់មន្ទីរធនធានទឹក និងឧតុនិយម រាជធានី ខេត្តទាំង២៥ ពុំមានសក្ខីបត្រចំណាយនោះទេ។ ឆ្លើយតបការលើកឡើងខាងលើ ក្រសួងធនធានទឹក និងឧតុនិយម បានទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

## ៤.៣៦. ភាពយឺតយ៉ាវក្នុងការដោះស្រាយចុះបញ្ជីម៉ាក

តាមការត្រួតពិនិត្យរបាយការណ៍បូកសរុបការងារឆ្នាំ២០២៤ និងទិសដៅអនុវត្តការងារឆ្នាំ២០២៥របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានកម្មសិទ្ធិបញ្ញាមានភាពយឺតយ៉ាវក្នុងការដោះស្រាយពាក្យស្នើសុំលុបម៉ាក និងជំទាស់ការចុះបញ្ជីម៉ាកចំនួន១១៤ករណី។ ឆ្លើយតបនឹងចំណុចនេះ ក្រសួងពាណិជ្ជកម្មបានស្រាយបំភ្លឺដូចតទៅ៖

១- យោងតាមច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ចំពោះបណ្តឹងជំទាស់ការចុះបញ្ជីម៉ាក មិនមានកំណត់រយៈពេលជាក់លាក់នោះទេ ព្រោះការដោះស្រាយបណ្តឹង ត្រូវការផ្តល់លទ្ធភាពឱ្យគូភាគីវិវាទក្នុងការផ្តល់អំណះអំណាង និងឯកសារគាំទ្រដើម្បីដាក់ ឬដោះបន្ទុកលើបណ្តឹង។ យោងតាមមាត្រា១០(ង) នៃច្បាប់ខាងលើ និងមាត្រា២០(២) នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គឺបានផ្តល់រយៈពេល៩០ថ្ងៃ សម្រាប់ភាគីវិវាទ ដើម្បីផ្តល់អំណះអំណាង និងឯកសារគាំទ្រពាក់ព័ន្ធនានា។ ចំពោះរយៈពេលនេះ អាចពន្យាពេលបន្ថែមទៀត ក្នុងករណីមានការស្នើសុំពីភាគីវិវាទ ដោយមានមូលហេតុសមស្រប ហើយការស្នើសុំពន្យាពេលនេះ អាចស្នើបានលើសពីមួយដង។

២- ពាក់ព័ន្ធនឹងពាក្យបណ្តឹងចំនួន១១៤ករណី ជាវឌ្ឍនភាព នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានដោះស្រាយចំនួន៧៥ករណី។ ចំណែក ចំនួន៣៩ករណីទៀត នាយកដ្ឋាននឹងខិតខំពន្លឿនការដោះស្រាយបញ្ចប់ឱ្យបានឆាប់។

## ៤.៣៧. ការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានមិនអស់លទ្ធភាព

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រង់មាត្រា១២ បានកំណត់ថា "ម្ចាស់គម្រោងត្រូវបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថានសម្រាប់កិច្ចការពារបរិស្ថាន" ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

តាមរយៈការចុះធ្វើសវនកម្មនៅក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ២០២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រុមហ៊ុនមិនទាន់បង់មូលនិធិទាយជ្ជទានបរិស្ថាន តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២៤ មានចំនួន ៩៧០ក្រុមហ៊ុន ដែលមានទឹកប្រាក់សរុបចំនួន ៧៩៩ ២៥០ ដុល្លារអាម៉េរិក។ ក្រសួងបរិស្ថានគួរណែនាំឱ្យក្រុមហ៊ុនធ្វើការបង់បំណុលដែលមិនទាន់បានបង់ឱ្យបានត្រឹមត្រូវតាមច្បាប់។

ឆ្លើយតបករណីនេះ ក្រសួងសូមធ្វើការបំភ្លឺថា បំណុលមូលនិធិចាប់តាំងពីឆ្នាំ២០១៥-២០២៤ ជាការបំពេញកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាការពារបរិស្ថានរបស់ម្ចាស់គម្រោងជូនចំពោះក្រសួងបរិស្ថានមិនបានពេញលេញ ក្នុងបរិបទសេដ្ឋកិច្ចសកលប្រឈមនឹងការដាក់បន្ថែមពន្ធនាំចូលពីសំណាក់សហរដ្ឋអាមេរិក និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន រួមទាំងតំបន់មជ្ឈឹមបូព៌ា។

ទោះបីជាយ៉ាងនេះក្តី បញ្ហាបំណុលមូលនិធិនេះ តម្រូវឱ្យមានការអនុវត្តវិធានការរដ្ឋបាល និងច្បាប់តឹងទារបំណុលយ៉ាងម៉ឺងម៉ាត់។

## ៤.៣៨. ការទារបំណុលសារពើពន្ធនៅមានកម្រិត

ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងទារបំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តវិធានការទារបំណុលពន្ធចំពោះបុគ្គលពាក់ពន្ធនឹងបំណុលពន្ធដូចជា៖ ធ្វើការទំនាក់ទំនង ឬចុះដល់ទីតាំងដើម្បីជំរុញ ឬផ្តល់ដំណឹងបន្ថែមឱ្យមកទូទាត់បំណុលពន្ធ មិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬចលនទ្រព្យជាបណ្តោះអាសន្ន ដកហូតមកវិញនូវការលើកទឹកចិត្តផ្នែកសារពើពន្ធដែលបានផ្តល់ដោយរដ្ឋបាលសារពើពន្ធ ព្យួរទុក ឬទុកជាមោឃៈនូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណផ្សេងៗដែលចេញដោយរដ្ឋបាលសារពើពន្ធ មិនអនុញ្ញាតឱ្យចុះបញ្ជីពន្ធដារ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីបញ្ចៀសនូវចេតនាគេចវេះការទូទាត់បំណុលពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្មនៅមានអង្គភាពអនុវត្តប្រមូលបំណុលមួយចំនួនសម្រាប់ការិយបរិច្ឆេទ២០២៤ បានអនុវត្តវិធានការតឹងទារដូចបានលើកឡើងខាងនៅមានកម្រិតនៅឡើយ។ ការអនុវត្តវិធានការតឹងទារបំណុលពន្ធនៅមានកម្រិត អាចនាំឱ្យបាត់ចំណូលពន្ធជាយថាហេតុ។ ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពអនុវត្តប្រមូលបំណុល បានឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះ បន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់ និងបានបញ្ជាក់បន្ថែមថា៖

- អង្គភាពអនុវត្តប្រមូលបំណុលបានអនុវត្តវិធានការទាររួចហើយ មានដូចជា៖ ចុះទៅពិនិត្យស្រាវជ្រាវដល់ទីតាំងសហគ្រាស បានជ្រើសរើសសហគ្រាសជំពាក់បំណុលពន្ធសម្រាប់កម្មវិធីទារ និងតឹងទារបំណុលពន្ធដែលជាប្រភេទសហគ្រាសមានហានិភ័យខ្ពស់ រៀបចំជាលិខិតស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទប់ស្កាត់ការគេចវេះពន្ធរបស់សហគ្រាសជំពាក់បំណុលពន្ធ បានធ្វើលិខិតជូនដំណឹងទារបំណុលពន្ធ បានធ្វើលិខិតស្នើសុំកិច្ចអន្តរាគមន៍ និងសហការទៅកាន់រដ្ឋបាលខេត្ត។ល។ និង
- បំណុលចុងឆ្នាំមួយចំនួនដែលមាន និងត្រូវទារភាគច្រើនពាក់ព័ន្ធនឹងធុរជនអ្នកជាប់ពន្ធធំ ដែលធ្វើអាជីវកម្មនាំចូលផលិតផលតេលសិលា និងសម្ភារអគ្គិសនី (អគ្គិសនីកម្ពុជា) ដែលបំណុលមួយចំនួនមានការទូទាត់យឺតយ៉ាវនៅក្នុងអំឡុងឆ្នាំសារពើពន្ធចរន្ត ប៉ុន្តែបំណុលនេះត្រូវបានទូទាត់អស់នៅក្នុងត្រីមាសទី១ ឬយ៉ាងយូរត្រឹមត្រីមាសទី២នៃឆ្នាំបន្ទាប់យ៉ាងទៀងទាត់។ ម្យ៉ាងទៀត បំណុលនេះពុំមែនជាបំណុលតឹងទារនោះទេ គឺគ្រាន់តែជាចំណូលស្ថិតក្នុងដំណើរការទូទាត់តែប៉ុណ្ណោះ។ អង្គភាពអនុវត្តតែងតែចេញលិខិតជំរុញធុរជនពាក់ព័ន្ធឱ្យពន្លឿនការទូទាត់ជាប្រចាំ។ ជាក់ស្តែង បំណុលចុងឆ្នាំ២០២៤ មានការថយចុះធៀបនឹងបំណុលចុងឆ្នាំ២០២៣ និងបំណុលចុងឆ្នាំកន្លងមក។

## ៤.៣៩. ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល(ឆ្នាំ២០២៤)

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥ (ប្រាំ) ឆ្នាំ នៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ ដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំដែលរៀបចំរួច ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន០២ (ពីរ) ច្បាប់ យ៉ាងយូរនៅដំណាច់ត្រីមាសទី១ នៃឆ្នាំបន្ទាប់ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី។ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ ក្រសួង ស្ថាប័ន (ថ្នាក់កណ្ដាល) សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងមន្ទីជំនាញថ្នាក់មូលដ្ឋានមួយចំនួនបានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោលរួចបានផ្ញើមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ នៅមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនទៀតមិនទាន់បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោលមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឡើយ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | អង្គភាព | បញ្ជីសារពើភណ្ឌឆ្នាំគោល២០២៤ | | |
|---|---|---|---|---|
| | | បានផ្ញើ | មិនបានផ្ញើ | សរុប |
| ១ | ក្រសួង ស្ថាប័ន (ថ្នាក់កណ្ដាល) | ៣៨ | ៣៥៨ | ៣៩៦ |
| ២ | សហគ្រាសសាធារណៈ | ១៣ | ១៣ | ២៦ |
| ៣ | គ្រឹះស្ថានសាធារណៈរដ្ឋបាល | ១២ | ៤៣ | ៥៥ |
| ៤ | រាជធានី ខេត្ត ក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងមន្ទីរជំនាញ(ថ្នាក់មូលដ្ឋាន) | ២ ១៦៤ | ៥៤៦ | ២ ៧១០ |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងសូមបញ្ជាក់ថាកន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំជំរុញឱ្យគ្រប់អាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចមកហើយ តែអាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់មួយចំនួននៅមិនទាន់បានរៀបចំតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាអនុវត្តតាមខ្លឹមសារនៃសារាចរនៅឡើយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសំណូមពរដល់អាជ្ញាធរសវនកម្មជាតិពិនិត្យ និងផ្តល់អនុសាសន៍បន្ថែមលើអង្គភាពប្រើប្រាស់នៃអាជ្ញាធរកាន់កាប់ដែលរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋយឺតយ៉ាវដើម្បីពន្លឿន និងជាការជំរុញបន្ថែមលើកិច្ចការនេះ។

## ៤.៤០. ភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ

សារាចរណែនាំលេខ ០០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុចទី៥ បានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលរៀបចំរួច ទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា សម្រាប់ការិយបរិច្ឆេទ២០២៤ ក្រសួង ស្ថាប័នថ្នាក់កណ្តាលចំនួន៣៨ និងអង្គភាពថ្នាក់មូលដ្ឋានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ មានភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ | |
|---|---|---|---|
| | | មានប័ណ្ណ | គ្មានប័ណ្ណកម្មសិទ្ធិ |
| ១ | ក្រសួង ស្ថាប័នថ្នាក់កណ្តាល | ៥៩៦ | ៦៧៧ |
| ២ | អង្គភាពថ្នាក់មូលដ្ឋាន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំសង្កាត់ | ២៣ ៦៨៧ | ១១ ០៣៩ |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែងតែជំរុញទៅអាជ្ញាធរកាន់កាប់ដាក់ពាក្យស្នើសុំរៀបចំធ្វើប័ណ្ណកម្មសិទ្ធិបានកាន់តែច្រើន ហើយចំនួនដីដែលពុំទាន់មានប័ណ្ណកម្មសិទ្ធិកាន់តែនៅសល់ចំនួនតិចទៅៗ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីជំរុញការរៀបចំនិងធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋនៅក្របខណ្ឌទូទាំងប្រទេស។ កន្លងមក គណៈកម្មការអន្តរក្រសួងនេះ បានបើកយុទ្ធនាការចុះផ្សព្វផ្សាយ និងជំរុញការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋនៅទូទាំង២៥ រាជធានី ខេត្ត ដែលមានរយៈពេល ៤ខែ ចាប់ពីខែតុលា ឆ្នាំ២០២២ ដល់ខែមករា ឆ្នាំ២០២៣។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងសូមបញ្ជាក់ថា កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានណែនាំជំរុញឱ្យគ្រប់អាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់រៀបចំធ្វើប័ណ្ណកម្មសិទ្ធិអចលនទ្រព្យរបស់រដ្ឋរួចមកហើយតែអាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់មួយចំនួននៅមិនទាន់បានរៀបចំតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាអនុវត្តតាមខ្លឹមសារនៃសារាចរនៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសំណូមពរដល់អាជ្ញាធរសវនកម្មជាតិពិនិត្យ និង

ផ្តល់អនុសាសន៍បន្ថែមលើអង្គភាពប្រើប្រាស់នៃអាជ្ញាធរកាន់កាប់ ដែលមិនទាន់បានបំពេញនីតិវិធីធ្វើប័ណ្ណកម្មសិទ្ធិលើអចលនទ្រព្យរបស់រដ្ឋ ដើម្បីពន្លឿន និងជាការជំរុញបន្ថែមលើកិច្ចការនេះ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ បានបង្ហាញឱ្យឃើញថារាជរដ្ឋាភិបាលបានគិតគូរ និងរៀបចំឡើង ដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ ប្រាក់ចំណូលរបស់ប្រជាជន ក៏ដូចជាការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការគាំទ្រដល់ការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវគោលដៅសំខាន់នៃ **កម្មវិធីនយោបាយ** របស់រាជរដ្ឋាភិបាលដែលត្រូវបានកំណត់នៅក្នុង**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១**។ ថវិកាឆ្នាំ២០២៤ ក៏ត្រូវបានរៀបចំតម្រង់ទៅបំពេញតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ក្រសួង ស្ថាប័ន ជាពិសេសកិច្ចការកែទម្រង់លើគ្រប់វិស័យ សំដៅកសាងមូលដ្ឋានគ្រឹះបន្ថែម ក្នុងដំណើរការឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែង របស់ប្រជាជនកម្ពុជាដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទកភាពជាតិ មានអនាគតដ៏រុងរឿង ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងជារដ្ឋអធិបតេយ្យមួយដ៏រឹងមាំ ដែលគោរពបានយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ លើសពីនេះ ថវិកាឆ្នាំ២០២៤ក៏បានបន្តរក្សាការពារសមិទ្ធផលសង្គមជាតិទាំងឡាយដែលសម្រេចបានកន្លងមក ប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែង ដើម្បីជម្នះ និងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតមានឡើងនាពេលអនាគតក្នុងស្មារតីធានាឱ្យកម្ពុជាអាចឈរដ៏រឹងមាំ និងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួនក្នុងគ្រប់កាលៈទេសៈ។

លទ្ធផលទាំងនេះបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងឆន្ទៈនយោបាយមោះមុតអង់អាច ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកបដោយគតិបណ្ឌិតឈ្លាសវៃនិងស្វាហាប់ បានបន្តពូនជ្រុំសមិទ្ធផលដែលសម្រេចបានកន្លងមកកាន់តែមានភាពរឹងមាំល្អប្រសើរថែមទៀត។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យយ៉ាងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ និងអធិបតេយ្យភាព ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្ម

នានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗ ជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។